OLD VERSION

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 09-Feb-2016, 14:03
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី ជំនុំជម្រះក្តីនៅជំណាក់កាលពីរ

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៦**

**ម៉ោង ០៩:០៦នាទី**

**សវនាការលើកទី៣៦៨**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ម៉ាធូវ ម៉ាកាធី *(Mr.Matthew Mccarthy)*

កញ្ញា ជា ស៊ីវហ៊ាង

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក នីកូឡាស គូមជែន
*(Mr. Nicolas KOUMJIAN)*

លោក វាំងសង់ វ៉ាយឌ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*

លោក ស្រ៊ា រតនៈ

លោក ត្រាវីស ហ្វារ*(Mr. Travis FARR)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក លីវ សុវណ្ណា

លោក វ៉ិចទ័រ កូប៉េ*(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍

*(Mr. Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖**

លោកស្រី ម៉ារី ហ្គីរ៉ូដ៍*(Ms.Marie GUIRAUD)*

លោក ឡៅ ជុនធី

លោក វ៉ើន ពៅ

លោក ហុង គឹមសួន

លោកស្រី ស៊ីន សុវ៉ន

លោកស្រី ជេត វណ្ណាលី

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

លោកស្រី ស្វ សុទ្ធាវី

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| លោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល | បារាំង |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក រ៉ិចទ័រ កូប៉េ | អង់គ្លេស |
| លោក ឡោ ជុនធី | បារាំង |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោក ស្រ៊ា រតនៈ | ខ្មែរ |
| លោក គង់ សំអុន | ខ្មែរ |
| លោក នីកូឡាស គូមជែន | អង់គ្លេស |
| លោក មាស វឿន (2-TCW-1008) | ខ្មែរ |
| លោកស្រី អ៊ុន យឿង (2-TCW-849) | ខ្មែរ |

E1/387.1/Old-1

## ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក មាស វឿន** (2-TCW-1008)

សួរបន្តដោយលោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល ផ្ដើមពី................ ទំព័រ ៣

សួរដោយលោក ឡេា ជុនធី ផ្ដើមពី................ ទំព័រ ២៨

សួរដោយកញ្ញា អង់តា ហ្គីសសេ ផ្ដើមពី................ ទំព័រ ៣២

**ការសួរសំណួរទៅសាក្សី៖ លោកស្រី អ៊ិន យឿង** (2-TCW-849)

សួរបន្តដោយលោក ស្រ៊ា រតនៈ ផ្ដើមពី................ ទំព័រ ៤៤

សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល ផ្ដើមពី................ ទំព័រ ៥៤

សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍ ផ្ដើមពី................ ទំព័រ ៦១

សួរដោយលោក វ៉ិចទ័រ កូប៉េ ផ្ដើមពី................ ទំព័រ ៧០

សួរដោយកញ្ញា អង់តា ហ្គីសសេ ផ្ដើមពី................ ទំព័រ ៧៥

# **កិច្ចដំណើរការនីតិវិធី**

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៦:២១]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយសវនាការនៅថ្ងៃនេះអង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សក្ខីកម្ម មាស វឿន បញ្ចប់ នៅព្រឹកនេះ។ ហើយនៅរសៀលអង្គជំនុំជម្រះនឹងបន្តធ្វើសវនាការស្តាប់សក្ខីកម្មសាក្សី អ៊ុន យឿង ដែលបានអាក់ខានកាលពីសប្តាហ៍មុន ដោយសារគាត់មានបញ្ហាសុខភាព ដែលត្រូវសម្រាកទទួលការព្យាបាល។

ហើយមួយទៀត អង្គជំនុំជម្រះក៏សូមជម្រាបជូនភាគីផងដែរថា ដោយគម្រោងផែនការនៃការស្តាប់សក្ខីកម្មសាក្សី អ៊ុន យឿង ដែលអង្គជំនុំជម្រះកំណត់ធ្វើសវនាការ គឺរយៈពេលមួយថ្ងៃ។ ហើយតាមគណនាពេលវេលា នៅថ្ងៃនេះគឺអស់មួយព្រឹកក្នុងការបន្តស្តាប់សក្ខីកម្មសាក្សី មាស វឿន។ ដូច្នេះសាក្សី -- ការស្តាប់សក្ខីកម្ម អ៊ុន យឿង ដែលគាត់មានបញ្ហាសុខភាពផងនោះ អង្គជំនុំជម្រះនឹងបន្តធ្វើនៅព្រឹកថ្ងៃស្អែកមួយព្រឹកទៀត ដើម្បីបញ្ចប់ការស្តាប់សក្ខីកម្មរបស់គាត់ សូមភាគីជ្រាប។

ក្រឡាបញ្ជីសវនាការឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ!

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថាគ្រប់ភាគីទាំងអស់នៃរឿងក្តីនេះមានវត្តមាន លើកលែងតែលោក ពេជ អង្គ សហមេធាវីនាំជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណីអវត្តមានដោយមូលហេតុផ្ទាល់ខ្លួន។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។

សាក្សីដែលនឹងត្រូវមកផ្តល់សក្ខីកម្មបញ្ចប់នៅថ្ងៃនេះ គឺលោក មាស វឿន។ លោក និងមេធាវីប្រឹក្សាមានវត្តមានរួចហើយនៅក្នុងបន្ទប់សវនាការនេះ។ សាក្សីដែលត្រូវមកផ្តល់សក្ខីកម្មបន្តទៀត គឺលោកស្រី អ៊ុន យឿង ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោក។ ហើយជាដំបូងនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសូមលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ របស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៦ ដែលបានបញ្ជាក់ថាដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្ចង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនាថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសូមលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់នៅក្នុងបន្ទប់សវនាការ នៅថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ ២០១៦។

[០៩:០៩:០៤]

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការ ពិនិត្យព្យាបាលថែទាំសុខភាពជនជាប់ចោទនៅអ.វ.ត.ក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៦ បានកត់សម្គាល់ពីស្ថានភាពសុខភាពរបស់លោក នួន ជា នៅថ្ងៃនេះ ថាមានអាការៈឈឺចង្កេះជាប្រចាំ អង្គុយយូរមិនបាន អង្គុយយូរកាន់តែឈឺខ្លាំង និងបានផ្តល់អនុសាសន៍ថា សូមឲ្យអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីបន្ទប់ស្ថិតនៅខាងក្រោមសាលសវនាការនេះ។

ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា ចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និង តាមដានកិច្ចដំណើរការសវនាការពីចម្ងាយក្នុងរយៈពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

បាទ ជាបន្តទៅនេះអង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមសហ -- វត្តតំណាងសហព្រះរាជអាជ្ញាដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។ ហើយមុនផ្តល់ អង្គជំនុំជម្រះសូមរំឭកដល់លោកសាក្សី លោក មាស វឿន សូមឲ្យលោកស្តាប់សំណួរឲ្យបានច្បាស់ជាមុន សូមឆ្លើយតប។ ហើយការឆ្លើយតបរបស់លោកទៅនឹងសំណួរ គឺកម្រិតត្រឹមភាពចាំបាច់ពេញលេញ និងគ្រប់គ្រាន់ទៅនឹងសំណួរបានហើយ។ ចៀសវាងការដែលលោកអត្ថាធិប្បាយចាកចេញឆ្ងាយផុតពីភាពចាំបាច់សម្រាប់

ឆ្លើយតបទៅនឹងសំណួរ ការលំបាក វាធ្លាក់ទៅលើលោកខ្លួនឯងទេ។

[០៩:១០:៥០]

ទី២ គឺសូមរំឭកសហព្រះរាជអាជ្ញារងអន្តរជាតិថា ប្រសិនបើអាចធ្វើបាន គប្បីតាំងសំណួរខ្លីៗ សាមញ្ញ ហើយនិងងាយយល់ ឬក៏អាចបំបែកសំណួរ ដើម្បីឲ្យសាក្សីស្ដាប់បានងាយ ហើយនិងអាចឆ្លើយតបបានត្រឹមត្រូវ ចៀសវាងការដូចពីម្សិលមិញអ៊ីចឹង គឺវាមានតតិបតតុបច្រើន ដោយសារគាត់ស្ដាប់សំណួរមិនយល់ បង្កើតជាបញ្ហាម្ដងហើយ ម្ដងទៀត។

ហើយសហព្រះរាជអាជ្ញា រួមទាំងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី មានរយៈពេលមួយវគ្គនៅព្រឹកនេះ និង១៥នាទី នៅវគ្គ នៅពេលដំបូងនៃវគ្គទី២ សូមជ្រាប។ សូមអញ្ជើញ!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម និងភាគីទាំងអស់។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរបន្តដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** ជម្រាបសួរលោកសាក្សី កាលពីម្សិលមិញ មុនពេលឈប់សម្រាកនោះ លោកនិយាយថា រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ មានផែនការកម្ទេចយួនទាំងអស់ ដែលរស់នៅកម្ពុជាក្រោយឆ្នាំ១៩៧៥។ ហើយលោកបាននិយាយទៀតថា បើតាមផែនការនេះ គឺយួនមិនមានសិទ្ធិរស់នៅកម្ពុជាទេ។--

**ប្រធានអង្គជំនុំ៖**

ឈប់ៗ! កុំអាលទាន់! អញ្ជើញៗមេធាវីអន្តរជាតិការពារក្ដីលោក ខៀវ សំផន!

[០៩:១២:១៧]

**កញ្ញា អង់តា ហ្គីសសេះ**

សូមគោរពលោកប្រធាន ខ្ញុំសូមជំទាស់ទៅនឹងបញ្ហានេះ សាក្សីមិនបាននិយាយកាលពីម្សិលមិញថា មានផែនការរបស់រដ្ឋាភិបាលទេ។ គាត់និយាយអំពីផែនការ តែគាត់មិនបញ្ជាក់ពាក្យថា "រដ្ឋាភិបាល" ទេ។ គាត់ឆ្លើយយ៉ាងច្បាស់ថា គាត់មិនដឹងថាតើគោលនយោបាយរបស់រដ្ឋាភិបាលចំពោះយួនហ្នឹងយ៉ាងម៉េចទេ។ អ៊ីចឹងព្រះរាជអាជ្ញាគួរតែរៀបចំសួរឡើងវិញ កុំថាផែនការនេះ ជាផែនការរបស់រដ្ឋាភិបាល។

**លោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

លោកប្រធាន កាលពីម្សិលមិញ ប្រហែលជាម៉ោងបួន ខ្ញុំសូមដកស្រង់ជាភាសាអង់គ្លេស ពីព្រោះថា មិនទាន់មានប្រតិចារឹកជាបារាំងនៅឡើយទេ។ គាត់និយាយអំពីរដ្ឋាភិបាលកម្ពុជា៖ "ខ្ញុំមិនដឹងការជាក់ស្ដែងអំពីរដ្ឋាភិបាលកម្ពុជាឡើយ ក្នុងការដោះស្រាយជាមួយបញ្ហាយួន"។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** ដូច្នេះខ្ញុំនឹងព្យាយាមរៀបចំសំណួរឡើងវិញ។ លោកសាក្សី កាលពីម្សិលមិញ លោកនិយាយអំពីផែនការមួយ រួចលោកនិយាយអំពីរដ្ឋាភិបាលកម្ពុជា។ ដូច្នេះខ្ញុំចង់ដឹងថា តើផែនការហ្នឹងផែនការរបស់អ្នកណាដែលសំដៅកម្ទេចយួនទាំងអស់ដែលមិនព្រមចេញពីកម្ពុជា នៅឆ្នាំ១៩៧៥នោះ?

[០៩:១៣:៤៦]

**លោក មាស វឿន៖**

**ឆ៖** បាទ កាលដែលខ្ញុំបានដឹងខ្លះអំពីផែនការយួន ហើយនិងថ្នាក់ដឹកនាំ ក្នុងនោះគឺយួន ហើយនិងខ្មែរហ្នឹងមានទំនាស់គ្នា។ ទំនាស់គ្នា ដោយមានការវាយតប់គ្នា ដូចជាលោកបានដឹងស្រាប់ហើយ ឆ្នាំចិតសិប តាំងពីឆ្នាំ៧៩មក។ អ៊ីចឹងខ្ញុំឃើញថា ជាទិសដៅបានន័យថា ខ្មែរ -- ការតស៊ូរបស់បដិវត្តកម្ពុជាហ្នឹង ហើយនិងយួនហ្នឹង គឺមានការទាស់ទែងគ្នាឈ្លានពានគ្នាទៅវិញទៅមក ហើយមិនគោរពកិច្ចការអធិបតេយ្យភាពគ្នាទៅវិញទៅមក រហូតដល់បានយួនវាយបន្តបន្ទាប់មក។ អ៊ីចឹងក្នុងទិសដៅនៃអ្នកដឹកនាំនោះ គឺថាត្រូវតែវាយយួន ដើម្បីកុំឲ្យវាឈ្លានពានមកលើទឹកដីខ្មែរ ទឹកដីកម្ពុជា នេះដែលយួនពីខាងក្រៅ។ តែដល់យួននៅក្នុងកម្ពុជានោះ ក៏ត្រូវមានការប្រមូល ប្រមូលហើយស្រាវជ្រាវ ថាតើយួនដែលនៅកម្ពុជាដែលយូរហើយនោះ នៅកន្លែងណាខ្លះ? ដើម្បីប្រមូលយកមកទុកមួយកន្លែងដើម្បីយើងគ្រប់គ្រង។ ឯក្នុងការដែលថា កម្ទេចនោះ មិនទាន់មានផែនការថាកម្ទេចទេ គ្រាន់តែថា ប្រមូលទុកឃុំដើម្បីកុំឲ្យមានការទាក់ទង ពីព្រោះអីយួនពីខាងក្រៅកំពុងតែមានផែនការវ៉ៃ។ អ៊ីចឹងយើងឃើញក្នុងហ្នឹងការរៀបចំរបស់អ្នកដឹកនាំទប់ទល់នឹងស្ថានការណ៍ហ្នឹង។ ឯក្នុងការកម្ទេច ផែនការថាកម្ទេចយ៉ាងម៉េចនោះ មិនទាន់មានឯកសារ ឬក៏មិនទាន់មានអីណែនាំដល់ថា នៅក្នុងខាងក្នុងទេ។ ដូច្នេះកម្ទេចយួនខាងក្រៅដែលវាឈ្លានពានជាសំខាន់។ នេះដែលតាមទិសដៅខ្ញុំក្ដាប់បាន ហើយនិងការណែនាំប៉ុណ្ណឹង។ សូមអស់។

[០៩:១៦:១៤]

**ស៖** លោកសាក្សី កាលពីម្សិលមិញលោកមិនបាននិយាយអ៊ីចឹងទេ។ កាលពីម្សិលមិញ ម៉ោងបីជាងនោះ លោកបាននិយាយថា ខ្ញុំសូមដកស្រង់៖ "អ៊ីចឹងចំពោះយើងវិញ គឺនៅពេលក្រោយមកទៀត គេបានណែនាំឲ្យយើងថា កម្ទេចវៀតណាម ពីព្រោះថា ព្រោះពួកគេមិនព្រមត្រឡប់ទៅប្រទេសវិញ។" សូមបញ្ចប់ការដកស្រង់។ ហើយពេលមុនហ្នឹង គឺនៅម៉ោង០៣:៤៧:០២វនាទី ខ្ញុំសួរលោកដូចតទៅ ខ្ញុំសូមដកស្រង់ជាភាសាអង់គ្លេស៖ "តើលោកមានឮអំពីផែនការកម្ទេចវៀតណាមនៅកម្ពុជា ចន្លោះពីឆ្នាំ៧៥ ដល់៧៩ទេ? ហើយលោកឆ្លើយថា៖ បាទ ខ្ញុំបានឮអំពីផែនការនោះ។ ខ្ញុំឮអំពីវៀតណាមដែលរស់នៅក្នុងប្រទេសកម្ពុជា ហើយប្រជាជនវៀតណាមទាំងអស់នោះ មានបំណងបង្កបញ្ហាដល់ប្រជាជនកម្ពុជា ហើយពួកគេមិនមែនមានចិត្តរស់នៅដោយស្មោះត្រង់នោះឡើយ។" សូមបញ្ចប់ការដកស្រង់។

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

អញ្ជើញលោកមេធាវី អង់តា ហ្គិសសេ លោកស្រីមេធាវី អង់តា ហ្គិសសេ!

**កញ្ញា អង់តា ហ្គិសសេ៖**

លោកប្រធាន របៀបដែលព្រះរាជអាជ្ញាគាត់ធ្វើហ្នឹង គឺវាមិនពេញលេញទេ។ ខ្ញុំសូមជំទាស់ទៅនឹងរបៀបនៃការសួរសំណួរបែបនេះ ពីព្រោះថាក្រោយពីឃ្លាហ្នឹងមក សាក្សីគាត់និយាយអំពីឆ្នាំ៧០ ដល់ឆ្នាំ៧៥ទេ គាត់មិននិយាយអំពីរយៈពេលនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យទេ។ អ៊ីចឹងត្រូវតែបញ្ជាក់ឲ្យច្បាស់ត្រង់ចំណុចនេះ។ អ៊ីចឹងខ្ញុំសូមជំទាស់ទៅនឹងរបៀបនៃការតាំងសំណួរបែបនោះ ដែលដកស្រង់តែចម្លើយមួយផ្នែករបស់សាក្សីមកនិយាយ ហើយតាមពិតទៅសាក្សីគាត់និយាយបន្តទៀត ពីឆ្នាំ៧០ ដល់ឆ្នាំ៧៥ទេ។

[០៩:១៨:២៩]

**លោក វាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

ខ្ញុំសូមឆ្លើយតបលោកប្រធាន។ គាត់បាននិយាយច្បាស់ណាស់ គាត់និយាយពី៧០ដល់៧៥ ហើយបន្ទាប់មកទៀត គាត់បន្តទៅទៀត គាត់ថា ក្រោយមកទៀត អ៊ីចឹងមានន័យថា៖ "ក្រោយឆ្នាំ៧៥ហើយ យើងទទួលបានបញ្ជាថា ត្រូវតែកម្ទេចវៀតណាមចោលទាំងអស់ ពីព្រោះថាពួកគេមិនព្រមត្រឡប់ទៅប្រទេសរបស់ខ្លួនវិញ។" សូមបញ្ចប់ការដកស្រង់។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** ដូច្នេះខ្ញុំនឹងព្យាយាមសួរសំណួរឡើងវិញ។ បញ្ហាដែលលោកទទួលបាន សំដៅកម្ទេចជនជាតិវៀតណាមនេះ ពីព្រោះថាពួកគេមិនព្រមត្រឡប់ទៅស្រុកវិញ។ តើបញ្ហាទាំងនេះ ជាបញ្ហាដែលធ្វើនៅភូមិភាគបស្ចិម ឬក៏បញ្ហាដែលចេញមកពីមជ្ឈិមបក្សនៅភ្នំពេញ?

**លោក មាស វឿន៖**

**ឆ៖** បាទ ខ្ញុំចង់និយាយអំពីឆ្នាំ៧០ ពី៧០ នៅក្នុងពេលដែលយើងកំពុងតែប្រយុទ្ធគ្នាជាមួយថៃពី៧០ មកដល់៧៥។ តែពី៧៥មកវិញនោះ គឺខ្ញុំមិនបានទាន់និយាយទេ ខ្ញុំនិយាយពីឆ្នាំ៧០ មក៧៥ ក្នុងនោះដែលយើងឃើញថា កំពុងតែមានការប្រយុទ្ធគ្នាបន្តបន្ទាប់មក។ អ៊ីចឹងបានន័យថា ខ្ញុំចង់និយាយពីឆ្នាំ៧០ មក៧៥ហ្នឹង ក្នុងពេលដែលយួនដែលវានៅក្នុងស្រុកខ្មែរដែលយូរមកហើយ ហើយយើងត្រូវតែប្រមូលតាមកន្លែងអ្នកគ្រប់គ្រងមួយកន្លែងៗ។ ខ្ញុំមិនបាននិយាយពីឆ្នាំ៧៥មកដល់៧៩នោះទេ។ ហើយបើថាពីឆ្នាំ៧៥មក៧៩នោះ ខ្ញុំអត់បានទទួលផែនការនោះទេ ខ្ញុំចង់និយាយអ៊ីចឹងឯង។ ខ្ញុំសូមអស់។

[០៩:២០:៣៣]

**ស៖** ក៏ប៉ុន្តែសំណួរដែលបានសួរលោកនោះ គឺច្បាស់ណាស់ គេសួរថា តើលោកឮថាមានផែនការកម្ទេចវៀតណាមដែលរស់នៅកម្ពុជាចន្លោះពីឆ្នាំ៧៥ទៅដល់ឆ្នាំ៧៩ ដែរឬទេ ពេលនោះ? ហើយពេលនោះលោកឆ្លើយថា លោកទទួលបញ្ហាឲ្យកម្ទេចជនជាតិវៀតណាម។ ដូច្នេះខ្ញុំចង់ដឹងថា ពីចន្លោះឆ្នាំ៧០ ដល់ឆ្នាំ៧៥នោះ ពេលដែលជម្លោះជាមួយវៀតណាមនោះ តើលោកមានទទួលបញ្ហាឲ្យកម្ទេចជនជាតិវៀតណាមនៅក្នុងទឹកដីកម្ពុជាទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

អញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរលោក លោកស្រីចៅក្រម។ សំណួរមិនច្បាស់លាស់ឡើយកាលពីម្សិលមិញ។ ហេតុដូច្នេះហើយ លោកប្រធានបានឲ្យព្រះរាជអាជ្ញាសួរសំណួរឲ្យបានច្បាស់ ប៉ុន្តែឥឡូវនេះស្ថានភាពដែលកើតឡើង ហើយគាត់បាននិយាយអំពីស្ថានភាពឆ្នាំ៧០ ដល់៧៥ ហើយដែលផ្អែកតាមភ័ស្តុតាង ដែលយើងបានស្តាប់កាលពីសប្តាហ៍មុន គឺទាក់ទងទៅនឹងការវាយប្រយុទ្ធ

ជាមួយវៀតកុងនៅឆ្នាំ៧៣។ ហើយឥឡូវហ្នឹង គាត់និយាយហើយថា គាត់មិនដឹងថា គោលនយោបាយឆ្នាំ៧៥ ដល់៧៩ ជាអ្វីនោះឡើយ។ ដូច្នេះការដែលព្រះរាជអាជ្ញាសួរសំណួរច្បាស់លាស់កាលពីម្សិលមិញ ខ្ញុំនៅមានមន្ទិលសង្ស័យអំពីការអះអាងនេះ។

[០៩:២២:០៩]

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

លោកប្រធាន ខ្ញុំសូមឆ្លើយតប។ រឿងហេតុ គឺច្បាស់លាស់ហើយ សាក្សីគាត់បាននិយាយកាលពីម្សិលមិញថា ខ្ញុំជឿជាក់ថា នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ វៀតណាមមិនត្រូវបានអនុញ្ញាតឱ្យរស់នៅក្នុងទឹកដីកម្ពុជាទេ ពីព្រោះយើងដឹងក្នុងវគ្គអប់រំរៀនសូត្រអំពីទំនាស់រវាងយួន និងឡាវ ក៏ដូចជាកម្ពុជា។ ដូច្នេះសាក្សីរូបនេះ គាត់បាននិយាយច្បាស់ណាស់អំពីរបបកម្ពុជាប្រជាធិបតេយ្យ មិនមានភាពមន្ទិលសង្ស័យឡើយពាក់ព័ន្ធទៅនឹងចម្លើយនេះ។ ដូច្នេះខ្ញុំសូមការអនុញ្ញាតពីលោកប្រធាន ដើម្បីសួរសំណួរនេះ ពីព្រោះថា លោកសាក្សីគាត់បាននិយាយថា គឺនៅឆ្នាំ៧០ ដល់៧៥ គាត់និយាយរួចហើយ។ អ៊ីចឹងខ្ញុំសួរគាត់ ថាតើ៧៥ដល់៧៩ហ្នឹង មានវិវាទជាមួយនឹងវៀតណាមទេ ហើយគាត់មានបានទទួលបញ្ជាឱ្យកម្ទេចជនជាតិវៀតណាមដែលរស់នៅក្នុងកម្ពុជាទេ នៅសម័យនោះ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះបដិសេធនូវសេចក្តីជំទាស់របស់មេធាវីការពារក្តីលោក នួន ជា លើសំណួរនេះ។ ហើយសាក្សីឆ្លើយតបនឹងសំណួរនេះ ហើយក្នុងករណីចាំបាច់យ៉ាងណានោះ គឺក្រុមសហមេធាវីអាចប្រើប្រាស់ពេលវេលាដែលអង្គជំនុំជម្រះនឹងផ្តល់ឱ្យលោកចុងក្រោយ ដើម្បីតាំងសំណួរបញ្ជាក់បន្ថែម។ អ៊ីចឹងហើយបានយើងយល់ថា លោកលៃពេលថាខ្លួនហ្នឹង គឺទុកពេលវេលាខ្លះដើម្បីសួរចុងក្រោយបន្ទាប់ពីភាគីចោទប្រកាន់ហ្នឹងបានសួររួច។ សាក្សីឆ្លើយតបនឹងសំណួរនេះ!

[០៩:២៤:០១]

**លោក មាស វឿន៖**

**ឆ៖** បាទ សំណួរដែលលោកសួរ ខ្ញុំដឹងថា ជាសំខាន់គឺយួនដែលមិនឱ្យនៅទឹកដីខ្មែរនុ៎ង មិនមានថាផែនការកម្ទេចទេ ពីព្រោះថាមិនទាន់ថាមានដាក់ផែនការថា ឱ្យកម្ទេចទាំងអស់នោះទេ។ ឱ្យប្រមូលយកមកដើម្បីឱ្យបញ្ជូនមកខាងថ្នាក់លើ។ អាហ្នឹងដែលពី៧៥ មក៧៩ហើយហ្នឹង។ អាហ្នឹងដែលខ្ញុំនៅព្រំដែន ដែលនៅខាងក្រោយខ្ញុំមិនបានទទួលទេ ពីព្រោះខាង ព្រោះអីខ្ញុំបានធ្វើ បានដូចថាយួនដែលខ្ញុំចាប់

បានអ៊ីចឹង ខ្ញុំបញ្ជូនមកខាងៗលើ។ តែផែនការឲ្យខ្ញុំកម្ទេច ខ្ញុំអត់ទាន់បានកម្ទេចណា៎។ ខ្ញុំបញ្ជូនមកតាមថ្នាក់ដឹកនាំខាងលើរបស់ខ្ញុំដែរតើ។ សូមអស់។

**សួរដោយលោក វ៉ាំងសង់ វ៉ាយឌ៍ ដេស្នាឯល៖**

**ស៖** ចុះបញ្ហាថា មិនឲ្យយួនរស់នៅកម្ពុជា ត្រូវប្រមូលជនជាតិយួន ហើយបញ្ជូនទៅថ្នាក់លើនេះ ខ្ញុំចង់ដឹងថា បញ្ហាបែបហ្នឹងចេញមកពីថ្នាក់ណា? តើបញ្ហានេះចេញមកពីមេផ្ទាល់របស់លោក ឬក៏បញ្ហានេះមកពីថ្នាក់លើបន្តទៅទៀត គឺថ្នាក់លើ លើមេរបស់លោកទៅទៀត?

**ឆ៖** បាទ ខ្ញុំទទួលតែពីតាមកងពលខ្ញុំ ប្រធានកងពលខ្ញុំគឺ បងសឿង។ ខ្ញុំទទួលតែផែនការពីៗកងពលខ្ញុំតែប៉ុណ្ណោះឯង។ សភាពការណ៍យ៉ាងម៉េចៗ គឺខ្ញុំរាយការណ៍តែមកប្រធានកងពលខ្ញុំ បងសឿង តែប៉ុណ្ណឹងឯង។

[០៩:២៦:០៣]

**ស៖** តើលោកធ្លាប់ឮ នួន ជា, ប៉ុល ពត, សុន សេន, តាម៉ុក ឬ ខៀវ សំផន ជជែកគ្នាអំពីផែនការកម្ទេចយួនដែលរស់នៅក្នុងទឹកដីកម្ពុជាប្រជាធិបតេយ្យនៅក្នុងចន្លោះពីឆ្នាំ៧៦ ដល់ឆ្នាំ៧៩ ដែរឬទេ?

**ឆ៖** សំណួរ ខ្ញុំមិនបានជួបជាមួយគាត់ទេ។ ការងាររបស់គាត់ដឹកនាំខាងលើ ខ្ញុំមិនបានដែលទៅប្រជុំជាមួយគាត់ថ្នាក់ខ្ពស់ៗទេ។ ខ្ញុំត្រឹមតែទទួលបានតែពីត្រឹមលេខាកងពលខ្ញុំប្រាប់។ សូមអស់។

**ស៖** ពេលលោកទទួលបញ្ហាពីថ្នាក់លើរបស់លោកហ្នឹង លោកនៅឯណា? លោកនៅកោះកុង ឬក៏លោកទៅព្រះវិហារហើយ?

**ឆ៖** បាទ ខ្ញុំនៅកោះកុង។

**ស៖** ពេលនៅកោះកុងហ្នឹង គេចេញវិធានការអ្វីខ្លះដើម្បីប្រមូលជនជាតិវៀតណាមទុកម្តុំហើយបញ្ជូនទៅថ្នាក់លើនោះ?

**ឆ៖** បាទ ខ្ញុំនៅកោះកុង ដូចខ្ញុំបានបញ្ជាក់ពីខាងដើមពីម្សិលមិញអ៊ីចឹង គឺថាខ្ញុំទៅអត់មានមនុស្ស ប្រជាជនក៏គ្មានដែរ ហើយអ្នកស្រុកគេត្រូវដកចេញអស់។ ដូច្នេះដែលខ្ញុំបានទទួល ខ្ញុំយកតែៗវៀតណាមដែលរត់មកចូលតំបន់កោះកុងដែលខ្ញុំចាប់បានហ្នឹង ខ្ញុំបញ្ជូនមកតាមថ្នាក់ដឹកនាំរបស់ខ្ញុំហ្នឹងមក តាមកងពលខ្ញុំហ្នឹងមក ដែលខ្ញុំចាប់បានយួន ដែលយួនបើកកាណូតបើកអីចូលដែនទឹក ហើយប្រុងឆ្លងទៅថៃទៅអីហ្នឹង ខ្ញុំចាប់បានបញ្ជូនមកតាមកងពល តាមថ្នាក់ដឹកនាំរបស់ខ្ញុំហ្នឹងមក ប៉ុណ្ណឹងឯង។

[០៩:២៨:២៧]

**ស៖** ខ្ញុំនិយាយអំពីយួនដែលរស់នៅកម្ពុជាក្នុងចន្លោះឆ្នាំ៧៥ ដល់ឆ្នាំ៧៩ ខ្ញុំមិននិយាយអំពីជនភៀសខ្លួនយួនដែលចូលមកតាមសមុទ្រទេ។ លោកៗថាយួនមិនមានសិទ្ធិរស់នៅកម្ពុជាទេ ហើយថ្នាក់លើបានបញ្ជាឲ្យប្រមូល ហើយបញ្ជូនទៅឲ្យពួកគេ។ ដូច្នេះខ្ញុំចង់ដឹងថា តើបញ្ជាហ្នឹងត្រូវបានទម្លាក់មកឲ្យតែភូមិភាគលោកហ្នឹងទេ ឬក៏ទៅកាន់ភូមិភាគផ្សេងៗទៀតទាំងអស់នៅទូទាំងកម្ពុជាតែម្តង?

**ឆ៖** បាទ ខ្ញុំមិនបានសួរសាកថា គ្រប់ភូមិភាគនោះទេ ខ្ញុំបានទទួលតែពីត្រឹមកងពលខ្ញុំ ភូមិភាគខ្ញុំតែប៉ុណ្ណោះឯង។ ឯចំណែកគេដទៃទៀត គេទទួលបានយ៉ាងម៉េច អាហ្នឹងខ្ញុំមិនបានដឹងទេ។

**ស៖** នៅឆ្នាំណាដែលលោកបានទទួលបញ្ជាឲ្យប្រមូលជនជាតិយួននៅក្នុងកម្ពុជា ហើយបញ្ជូនទៅឲ្យថ្នាក់លើនោះ?

**ឆ៖** បាទ អាហ្នឹងខ្ញុំចង់និយាយពីឆ្នាំ៧០ រហូតមកដល់៧៥ ព្រោះអីខ្ញុំមិនបាននៅខាងក្នុង ខ្ញុំនៅខាងក្រៅ ខ្ញុំបានទទួលប៉ុណ្ណឹងឯង។

**ស៖** លោកសាក្សី សក្ខីកម្មរបស់លោកហ្នឹងយ៉ាងម៉េចនេះ? លោក ៧០ដល់៧៥ លោកនៅកោះកុង ជាអនុកងពលលេខ១នៃភូមិភាគបស្ចិម មែនទេ? ចម្លើយរបស់លោកមានន័យអ៊ីចឹងមែនទេ?

**ឆ៖** បាទ ខ្ញុំនៅកោះកុងឆ្នាំចិត ពី៧៥ ខ្ញុំនៅកោះកុង៣ឆ្នាំ។ ៣ឆ្នាំដែលខ្ញុំមិនបានមកនៅខាងៗក្នុងៗខេត្តនឹងគេទេ ព្រោះខ្ញុំនៅតែតាមព្រំដែនរហូត។ ហើយពេលនោះ ខ្ញុំបានទទួលដំណឹងកិច្ចការងារតែពីក្នុងកងពលរបស់ខ្ញុំប៉ុណ្ណឹងឯង។ ដូច្នេះវាមិនមានពេលដែលខ្ញុំបានមកទទួលផែនការផ្ទាល់ពីអ្នកដឹកនាំ ឬក៏ពីៗតាមកន្លែងផ្សេងៗដទៃទៀតដែលខ្ញុំមិនបានមក ដោយសារអី ដោយសារពេលនោះខ្ញុំគ្មានមធ្យោបាយចេញចូលដឹកនាំ តាមផ្លូវវាលំបាកណាស់។ ដូច្នេះមានតែផ្លូវទឹកមួយទេ ដែលៗអាចដើរទៅបាន។ ផ្លូវគោក អត់មានទេ។ ម្ល៉ោះហើយ ខ្ញុំបានទទួលដំណឹងតិចជាងអ្នកនៅខាងក្នុង។ អ៊ីចឹងខ្ញុំទទួលតែដំណឹងតែប៉ុណ្ណឹងឯង។

[០៩:៣១:៣៨]

**ស៖** ដូច្នេះលោកនិយាយអំពីឆ្នាំ៧០ដល់ឆ្នាំ៧៥។ ខ្ញុំសួរលោកពីឆ្នាំ៧៥ ដល់ឆ្នាំ៧៩ អំពីផែនការដែលលោកទទួលមកថា មិនឲ្យវៀតណាមរស់នៅកម្ពុជានោះ។ ខ្ញុំចង់សួរថា ពេលដែលលោកនៅកោះកុងមែនទេ ដែលលោកបានទទួលបញ្ជាទាំងអស់ហ្នឹង?

**ឆ៖** បាទ ខ្ញុំនៅកោះកុងហ្នឹងឯង។

**សៈ** កាលពីម្សិលមិញ លោកបានឆ្លើយថា មានជនជាតិវៀតណាមជាច្រើន ដែលបន្តរស់នៅក្នុងភូមិភាគបស្ចិមនៅឆ្នាំ៧៥។ ដើម្បីឲ្យបានពេញលេញ ខ្ញុំសូមដកស្រង់នូវចម្លើយរបស់លោក គឺនៅម៉ោង១៥:៥៨:០៤ គេសួរលោកដូចតទៅ ខ្ញុំសូមដកស្រង់ជាភាសាអង់គ្លេស៖ "ដោយសារមានវៀតណាមជាច្រើន មិនត្រឡប់ទៅវៀតណាម ហើយដែលត្រូវកម្ទេចនោះ ឧទាហរណ៍នៅក្នុងភូមិភាគបូព៌ា តើលោកបានឮអំពីវត្តមានរបស់ជនជាតិវៀតណាមណាខ្លះ ដែលសម្រេចចិត្តរស់នៅក្នុងប្រទេសទេ? ហើយចម្លើយរបស់លោកគឺថា៖ បាទ គឺមាន។ ហើយមានប្រជាជនវៀតណាមច្រើនត្រឡប់ទៅវិញ ប៉ុន្តែមិនមែនត្រឡប់ទៅគ្រប់គ្នាទាំងអស់នោះទេ។ ពួកគេមួយចំនួននៅបន្តរស់នៅក្នុងប្រទេសកម្ពុជា ឬក៏បានរៀបការជាមួយប្រជាជនកម្ពុជា។ ភាគច្រើនពួកគេសម្រេចចិត្តរស់នៅក្នុងប្រទេសកម្ពុជា គឺរស់នៅខេត្តកំពង់ចាម -- កំពង់ឆ្នាំង នៅតាមមាត់ទន្លេ។ ហេតុដូច្នេះហើយ គឺថានៅពេលក្រោយមកទៀត គឺមានការប៉ះទង្គិចរវាងប្រជាជនកម្ពុជា និងប្រជាជនវៀតណាម។ ហើយហេតុការណ៍នេះវាកើតឡើងនៅភូមិភាគបស្ចិមផងដែរ។ មាន ទោះបីថា មានប្រជាជនវៀតណាមនៅតែបន្តរស់នៅ ទោះបីថានៅឆ្នាំ៧៨ មានការវាយប្រហារវៀតណាមមកលើកម្ពុជាក៏ដោយ"។

[០៩:៣៤:០៤]

លោកឆ្លើយថា វៀតណាមជាច្រើននៅបន្តរស់នៅកម្ពុជានៅឆ្នាំ៧៥ ហើយពួកគេ អ្នកខ្លះនុំងរៀបការជាមួយខ្មែរ។ ហើយនៅពេលនោះ ខ្ញុំបានសួរថា តើគេអាចកំណត់ថា អ្នកណាជាខ្មែរ អ្នកណាជាយួនបានយ៉ាងម៉េច ដោយសារនិយាយរដឺនៗ ឬក៏មានគ្រួសារវៀតណាមយ៉ាងម៉េចពេលនុំង? ហើយលោកក៏បានឆ្លើយអ៊ីចឹង។ ឥឡូវនេះខ្ញុំចង់ដឹង ថាតើភូមិភាគបស្ចិមត្រូវរាយការណ៍ទៅមជ្ឈិមបក្សពាក់ព័ន្ធទៅនឹងបញ្ហាការពារទឹកដីដែលមានខ្មាំងផ្ទៃក្នុង និងខ្មាំងខាងក្រៅដែរឬទេ?

**ឆៈ** បាទ អាហ្នឹងខាងភូមិភាគហ្នឹង គេៗរាយទៅខាងថ្នាក់មជ្ឈិម។ គេ អាហ្នឹងគេរាយយ៉ាងម៉េច ខ្ញុំមិនដឹងទេ។ ក៏ប៉ុន្តែខ្ញុំមិនបានទាក់ទងរឿងក្នុងមជ្ឈិមទេ ខ្ញុំទាក់ទងតែក្នុងកងពលខ្ញុំទេ។ សាច់ការអ្វីដែលខ្ញុំបានទទួល បានដឹង គឺតែពីកងពលខ្ញុំទេ។ ដូច្នេះការងាររាយការណ៍យ៉ាងម៉េច បន្តទៅទៀតនោះ អាហ្នឹងនៅខាងភាគ កិច្ចការខ្ញុំមិនដឹងទេអាហ្នឹង។

**សៈ** ចុះខ្លួនលោកផ្ទាល់ហ្នឹងលោកចូលរួមកិច្ចប្រជុំនៅថ្នាក់ភូមិភាគបស្ចិមហ្នឹង ទៀងទាត់ដែរទេ?

**ឆៈ** មិនបានទៀងទាត់ទេ។ ជួនកាលកន្លះឆ្នាំអីបានមករួមម្តង។ បើគេហៅខ្ញុំ ក៏បានមក បើគេ

អត់ហៅក៏អត់ ព្រោះអីផ្លូវលំបាកដូចខ្ញុំប្រាប់អ៊ីចឹងឯង។

**ស៖** នៅក្នុងឯកសារ E3/73 នៅចម្លើយទី៦ លោកបានឆ្លើយដូចតទៅ ខ្ញុំសូមដកស្រង់៖ "ខ្ញុំច្រើនតែរាយការណ៍តាមសារទូរលេខជូនប្រធានកងពល។ ក្នុងរយៈពេល៣ ឬ៤ខែ បើមានការប្រជុំនៅភូមិភាគ ទើបខ្ញុំមកចូលរួម។" សូមបញ្ចប់ការដកស្រង់។ ក្នុងឯកសារនេះ លោកនិយាយថា ៣ឬ៤ខែម្ដង លោកបានប្រជុំនៅភូមិភាគបស្ចិម។ ដូច្នេះលោកអាចបញ្ជាក់ត្រង់ចម្លើយនេះ បន្តិចបានទេ?

[០៩:៣៦:៥៤]

**ឆ៖** បាទ ក្នុងការដែលបានមកប្រជុំ ជួនកាលពេលដែលមកប្រជុំ ជួនកាលពេលដែលខ្ញុំមិនបានមក អាហ្នឹងខ្ញុំប្រាប់តាម រាយការណ៍តាមទូរលេខ តែបើខ្ញុំមិនបានមកទេ អាហ្នឹងយើងខ្ញុំ ដោយការសភាពការណ៍តាមផ្លូវលំបាក។ ដូច្នេះជួនកាល បាន៣ខែទៅ គេហៅខ្ញុំមកម្ដងអ៊ីចឹងទៅ ជួនកាល៦ខែអ៊ីចឹងទៅ បានគេ សភាពការណ៍ដែលទឹកវាមិនសូវរលក បានគេហៅខ្ញុំមកម្ដងអ៊ីចឹងទៅ។ អាហ្នឹងជួនកាលវាទៅតាមសភាពការណ៍នោះដែរ។ ដូច្នេះវាផ្លូវវាឆ្ងាយ។ ខ្ញុំសូមបញ្ជាក់ប៉ុណ្ណឹង។

**ស៖** ចំពោះកិច្ចប្រជុំដែលលោកបានចូលរួមជាមួយលេខាភូមិភាគ ក៏ដូចជាថ្នាក់ដឹកនាំរបស់លោកនៅកងពលលេខ១ តើគេមាននិយាយអំពីបញ្ហាការពារប្រទេស បញ្ហាសន្តិសុខ បញ្ហាខ្មាំងផ្ទៃក្នុង និងបញ្ហាបង្កបង្កើនផលដែរឬទេ? តើគេមាននិយាយអំពីបញ្ហាទាំងអស់ហ្នឹងទេ នៅពេលប្រជុំនោះ?

**ឆ៖** បាទ ការប្រជុំគេនិយាយពី ទី១ គេនិយាយពីកិច្ចការពារប្រទេសនៅខាងព្រំដែន។ ហើយទី២ គេនិយាយពីការធ្វើស្រូវ ធ្វើស្រែ បង្កើនផល ១តោន ២តោន តាមតំបន់។ ហើយទី៣ គេលើកអំពីឧបាយកលខ្មាំងអ៊ីចឹងទៅដែលបង្កប់ស៊ីរូង ឬធ្វើឲ្យកិច្ចការដំណើរការរបស់អង្គភាពមិនជឿនលឿន ហើយនិងគេសរុបជួយ ជួនកាលគេសរុបពីលទ្ធផលស្រូវឆ្នាំនេះ បានប៉ុន្មានតោន។ អ៊ីចឹងអាហ្នឹងគឺថា គេប្រជុំមានកិច្ចការពីរផ្នែក បីផ្នែកហ្នឹង។ ហើយសរុបមកវិញមក គេថា មួយ ការពារប្រទេសដើម្បីឲ្យយើង កុំឲ្យប៉ះពាល់ជាមួយនឹងព្រំដែនខាងលិច។ ដូច្នេះមានបញ្ហាអីត្រូវរាយការណ៍ តាមដែនទឹក ដែនគោក ដែនសមុទ្រអីអ៊ីចឹង គេរាយការណ៍តាមផ្នែកៗរបស់គេអ៊ីចឹងទៅ។ ខ្ញុំរាយការណ៍តាមព្រំដែនខ្ញុំទៅពីកិច្ចការពារសន្តិសុខព្រំដែន។ គេៗរាយការណ៍ពីរឿងការកសាង ស្រូវ ធ្វើស្រូវ ធ្វើស្រែអ៊ីចឹងទៅ។ ខ្លះទៀត គេរាយការណ៍អំពីអង្គភាពរបស់គេមានការជឿនលឿន ដឹកនាំល្អអ៊ីចឹងទៅ នេះគឺតាមផ្នែកអ៊ីចឹង។ សូមអស់។

[០៩:៤០:១៤]

**ស៖** ខ្ញុំមានសំណួរមួយចំនួនពាក់ព័ន្ធទៅនឹងរបាយការណ៍ប្រចាំខែដែលផ្ញើដោយមន្ទីរ៤០១ "ជូនអង្គការជាទីគោរពស្នេហា" គឺឯកសារ E3/1094 ជារបាយការណ៍ប្រចាំខែកក្កដា ឆ្នាំ១៩៧៨ របស់មន្ទីរ៤០១ ផ្ញើជូនអង្គការ។

**លោក វាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

លោកប្រធាន សូមអនុញ្ញាតផ្តល់ឯកសារនេះ ជូនសាក្សី។ ឯកសារនេះធ្លាប់បានផ្តល់ជូនគាត់ម្តងរួចមកហើយកាលពី៣ឆ្នាំមុននៅក្នុងសវនាការយើង។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំដឹងថា ឯកសារនេះគឺនឹងយកមកបង្ហាញហើយ។ ខ្ញុំមានប្រតិចារឹកនៅចំពោះមុខខ្ញុំ ចុះថ្ងៃទី០៤ តុលា ២០១២ ដែលឯកសារនេះ ក៏ត្រូវបានយកមកបង្ហាញជូនទៅដល់សាក្សី។ ហើយក្រោយមកក៏មានអន្តរាគមន៍ពីលោកចៅក្រម ឡាវែន៍ នៅម៉ោង១៣:៥៣ ដែលនិយាយទៅលោកសហព្រះរាជអាជ្ញា៖ "សូមទោស សូមសួរទៅសាក្សីមើល តើកាលបរិច្ឆេទនៅលើឯកសារនេះ គាត់នៅតែធ្វើការនៅទីនោះដដែល ឬអត់ទេកាល់នោះ? ហើយសាក្សីក៏បានឆ្លើយថា៖ អត់ទេ ខ្ញុំបានចាកចេញរួចទៅហើយ។" ដូច្នេះនៅពេលនេះ សហព្រះរាជអាជ្ញាក៏នៅព្យាយាមយកឯកសារនេះ មកបង្ហាញម្តងទៀត។

[០៩:៤១:៥៦]

**លោក វាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

លោកប្រធាន ខ្ញុំសូមឆ្លើយតប។ កាលពីម្សិលមិញ សាក្សីបាននិយាយយ៉ាងច្បាស់ ហើយគាត់ក៏បាននិយាយជាច្រើននៅក្នុងកំណត់ហេតុរបស់គាត់ ថាគាត់បានចាកចេញពីកោះកុង ទៅព្រះវិហារនៅខែសីហា ឆ្នាំ៧៨។ យើងក៏ឃើញចម្លើយនេះនៅក្នុងកំណត់ហេតុ E3/424 នៅចម្លើយទី១៩។ ដូច្នេះខ្ញុំចង់បង្ហាញឯកសារនេះ ពីព្រោះថាយើងចូលមកដល់វគ្គថ្មី គឺនៅក្នុងសំណុំរឿង០០២/០២ ហើយយើងនិយាយអំពីជនវៀតណាម។ ហើយវាអាស្រ័យទៅតាមចម្លើយដែលសាក្សីបានឆ្លើយកាលពីម្សិលមិញនេះ ខ្ញុំគិតថា ខ្ញុំអាចសួរសំណួរសាក្សីនេះបានពាក់ព័ន្ធទៅនឹងខ្លឹមសារនៃឯកសារនេះ។ ដូច្នេះសូមលោកប្រធានមេត្តាអនុញ្ញាតឲ្យខ្ញុំសួរសំណួរពាក់ព័ន្ធនឹងឯកសារមួយនេះ។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះបដិសេធនូវសេចក្តីជំទាស់របស់មេធាវីការពារក្តី នួន ជា ហើយអង្គជំនុំជម្រះអនុញ្ញាត។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

**ស៖** លោកសាក្សី នៅក្នុងរបាយការណ៍នេះ នៅទំព័រទី៨ ជាភាសាបារាំងគឺ ERN 00593530, ជាភាសាខ្មែរគឺ 00143610, ជាភាសាអង់គ្លេសទំព័រ៧គឺ 00315374។ ក្នុងនេះមានដាក់ចំណងជើងថា៖ “តំបន់៣៧ សកម្មភាពខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង”។ ខ្ញុំចង់ដកស្រង់ ប៉ុន្តែឃើញខាងមេធាវីការពារក្តីងើបឈរម្តងទៀតហើយ។

[០៩:៤៣:៥៥]

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ទោះបីជាត្រូវមានការអនុញ្ញាតឱ្យបង្ហាញឯកសារក៏ដោយ ក៏ខ្ញុំសូមជំទាស់ទៅនឹងការសួរដោយយកខ្លឹមសារមកដកស្រង់ ដោយមិនទាន់បានសួរសំណួរបើកផង។ គាត់មិនទាន់សួរថា តើសាក្សីមានស្គាល់របាយការណ៍នេះ ឬក៏អត់? ធ្លាប់ឃើញរបាយការណ៍នេះឬក៏អត់? ត្រូវសួរបែបហ្នឹងសិន ទើបយកខ្លឹមសារមកសួរសាក្សីនោះ លោកប្រធាន។

**លោក វាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

ខ្ញុំគិតថា ដូចជាមិនចាំបាច់ធ្វើបែបហ្នឹងទេ កាលពីម្សិលមិញហ្នឹង មេធាវីការពារក្តីក៏សួរសំណួរផ្ទាល់ពីឯកសារតែម្តង ដោយមិនបានសួរសំណួរបើកជាមុននោះទេ។ ពេលវេលាខ្លីណាស់ អ៊ីចឹងហើយបានជាខ្ញុំសួរយកតែម្តង ពាក់ព័ន្ធនឹងខ្លឹមសារនៃឃ្លាមួយ។

**ប្រធានអង្គជំនុំ៖**

សកម្មភាពរបស់ភាគីម្ខាងទៀត បើជាកំហុសវាមិនមែនជាទម្រង់នៃភាគីម្ខាងទៀតរៀនតាមទេ។ គប្បីអនុវត្តឱ្យបានត្រឹមត្រូវតាមលក្ខខណ្ឌដែលអង្គជំនុំជម្រះបានណែនាំរួចហើយ សំណួរបើកហើយនិងសំណួរដាក់លាក់ទាញចេញ បញ្ជាក់ដោយសារក្រោយពីសួរបើករួចហើយ។ អង្គជំនុំជម្រះមិនទម្លាប់ឱ្យភាគីធ្វើដូច្នេះទេ។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

**ស៖** លោកសាក្សី ខ្ញុំចង់សួរសំណួរមួយ តើលោកធ្លាប់ឃើញរបាយការណ៍នេះទេ គឺរបាយ-

ការណ៍របស់ភូមិភាគបស្ចិមនៅពេលដែលលោកនៅកោះកុង? ហើយព្រោះថាលោកធ្លាប់ចូលរួមនៅក្នុងការប្រជុំនៅភូមិភាគបស្ចិម អ៊ីចឹងលោកធ្លាប់ឃើញគេបង្ហាញឯកសាររបៀបហ្នឹងទេនៅពេលប្រជុំនោះ?

**លោក មាស វឿន៖**

**ឆ៖** បាទ ខ្ញុំអត់បានទទួលផង អត់បានដឹង។ អត់មានឃើញគេរាយការណ៍នៅក្នុងអង្គប្រជុំហ្នឹងផង។ ហើយខ្ញុំក៏មិនបានទទួល នៅផ្នែកខាងលិច ក៏ខ្ញុំមិនបានទទួលរបាយការណ៍នេះផងដែរ។

**ស៖** ទោះជាយ៉ាងណាក៏ដោយ ខ្ញុំចង់សួរលោកពាក់ព័ន្ធទៅនឹងឯកសារនេះ។ វាផ្ទុយពីអ្វីដែលលោកបានឆ្លើយកាលពីម្សិលមិញ គឺដែលលោកថាមានផែនការប្រមូលផ្តុំជនជាតិវៀតណាមនៅកន្លែងមួយ គឺមិនមានផែនការកម្ទេចទេ។ ក៏ប៉ុន្តែនៅក្នុងរបាយការណ៍នេះ នៅ ERN ដែលខ្ញុំបានផ្តល់ជូនរួចមកហើយ គឺបានសរសេរថា៖ “អំពីការសម្រិតសម្រាំងសមាសភាពយួន ភ្នាក់ងារ សេ.អ៊ី.អា និងសមាសភាពមិនល្អ។ ទី១ កម្ទេចជនជាតិយួនទាំងតូច ទាំងធំ ទាំងចាស់ ទាំងក្មេង អស់ចំនួន១០០នាក់។”

អ៊ីចឹងគឺនៅក្នុងនេះបញ្ជាក់យ៉ាងច្បាស់ថា កម្ទេចជនជាតិយួន១០០នាក់ទាំងតូច ទាំងធំ ទាំងចាស់ទាំងក្មេង។ លោកសាក្សី លោកឃើញហើយថា ភូមិភាគបស្ចិមបានរាយការណ៍អំពីការកម្ទេចជនជាតិយួន១០០នាក់ ប៉ុន្តែលោកៗនិយាយថា មិនមានការកម្ទេចទេ មានតែការប្រមូលទុកម្តុំតែប៉ុណ្ណោះ។

[០៩:៤៨:០១]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំសូមជំទាស់ម្តងទៀតលោកប្រធាន។ ដោយសារនេះគឺជារឿងការពិតហើយ យើងបានបង្ហាញនៅក្នុងឆ្នាំ២០១២ បង្ហាញច្បាស់ហើយថា គាត់បានចាកចេញរួចទៅហើយ។ ដូច្នេះគាត់មិនមានអ្វីត្រូវនិយាយអំពីការរៀបចំបញ្ហានេះទេ។ ដូច្នេះការដែលលើកឡើងយកមកសួរម្តងហើយម្តងទៀត គឺជាការសួរត្រួតគ្នាដដែលៗ មិនគួរណាអនុញ្ញាតបែបនេះទេ។

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំសូមបន្ថែមទៅនឹងការជំទាស់របស់មេធាវី កូប៉េ។ យើងទើបតែស្តាប់ឮពីមាត់របស់សាក្សីថាក្នុងពេលដែលគាត់នៅកោះកុងនោះ គាត់មិនអាច -- គាត់អាចដឹងតែអំពីអ្វីដែលកើតឡើងនៅព្រំដែនសមុទ្រ ហើយនិងអ្វីដែលកើតឡើងនៅក្នុងកងពលរបស់គាត់តែប៉ុណ្ណោះ។ ហើយនៅពេលដែលយើងបង្ហាញរបាយការណ៍ដែលគាត់មិនដឹងអំពីខ្លឹមសារនោះ គាត់ៗមិនដឹងទេ គាត់មិនដឹងរឿងហេតុដែលកើតឡើងនៅក្នុងប្រទេសទេ។ ដូច្នេះខ្ញុំសូមជំទាស់ថា វាអត់មានប្រយោជន៍អីទេ ដែលយកឯកសារហ្នឹង

មកសួរសាក្សី ព្រោះសាក្សីគាត់មិនដឹងអ្វីទេ។

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

*(គ្មានការបកប្រែ)*--

[០៩:៤៩:១១]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសម្រេចបដិសេធនូវសេចក្តីជំទាស់ម្តងទៀត រឿងដដែលទេ។ អង្គជំនុំជម្រះបានស្តាប់សាក្សីផ្ទាល់ហើយថា កាលវេលាដែលគាត់បានចាកចេញពីខេត្តកោះកុង គឺនៅខែសីហា ឆ្នាំ១៩៧៨ ហើយគាត់ទៅនៅទីនោះបាន៤ខែត្រូវបែកយួន ច្បាស់លាស់ណាស់។ ដូច្នេះកាលបរិច្ឆេទនេះ គឺស្ថិតនៅក្នុងស្ថានភាពដែលត្រូវតែសួរបញ្ជាក់ បានបង្ហាញថា សាក្សីនៅក្នុងអំឡុងពេលដែលគាត់មានវត្តមាននៅក្នុងភូមិភាគបស្ចិម។ ទី២ គឺសាក្សីបានឆ្លើយខ្លួនឯងច្បាស់លាស់អំពីវិធានការកម្ទេចយួននៅខេត្តកំពង់ឆ្នាំង តាមដងទន្លេមេគង្គកាលពីម្សិលមិញ។ សាក្សីឆ្លើយតបទៅនឹងសំណួរចុងក្រោយរបស់សហព្រះរាជអាជ្ញារងអន្តរជាតិ។

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** សំណួរខ្ញុំអម្បាញ់មិញនេះ គឺខ្ញុំចង់ឲ្យលោកពន្យល់ថា ក្នុងនេះភូមិភាគបស្ចិមបានរាយការណ៍ទៅមជ្ឈិមបក្សថា ខ្លួនបានកម្ទេចជនជាតិវៀតណាមហ្នឹងបាន១០០នាក់។ ហើយលោកហ្នឹងលោកឆ្លើយកាលពីព្រឹកមិញថា ផែនការនុ៎ងមិនឲ្យកម្ទេចទេ គេគ្រាន់តែឲ្យប្រមូលទុកម្តុំតែប៉ុណ្ណោះ។ ឥឡូវលោកអាចពន្យល់យ៉ាងម៉េចបាន ចំពោះរបាយការណ៍មួយនេះ?

[០៩:៥០:៤៤]

**លោក មាស វឿន៖**

**ឆ៖** ពីព្រោះអីខ្ញុំមិនបានដឹងថា របាយការណ៍នេះ គេមិនបានឲ្យខ្ញុំដឹងទេ។ បើខ្ញុំដឹង ខ្ញុំឆ្លើយតាមនឹងតាមសំណួរដែលលោកសួរ។ ប៉ុន្តែរបាយការណ៍នេះ ខ្ញុំមិនបានដឹងដំណឹង ដឹងគេប្រាប់មកតាមភូមិភាគបស្ចិមទេ ពីព្រោះអី ដល់កន្លែងភូមិភាគហើយ គេមិនដែលរាយការណ៍បញ្ជាសមកៗខាងខ្ញុំវិញទេ គេរាយការណ៍តែទៅខាងលើទេ ព្រោះអីខ្ញុំមិនមែនតំណាងឲ្យភូមិភាគបស្ចិមឯណា។ អ៊ីចឹងរបាយ-

ការណ៍នេះ គេៗរាយពី -- គេរាយត្រឹមតែភូមិភាគហើយ ភូមិភាគរាយការណ៍ទៅថ្នាក់លើទៅទៀត។ អាហ្នឹងខ្ញុំមិនបានដឹងទេ។ អ៊ីចឹងខ្ញុំបានៗប្រាប់ម្តងហើយទៅ ហើយខ្ញុំបានបញ្ជាក់ម្តងហើយតើ ពីរឿងន៎ចម្លើយនេះនោះ។ ខ្ញុំសូមបញ្ជាក់ប៉ុណ្ណឹង សូមអស់។

**ស៖** ចំពោះឯកសារ E3/1094នេះ ខ្ញុំមានឃ្លាមួយទៀតដែលខ្ញុំចាប់អារម្មណ៍ ក៏ប៉ុន្តែជាដំបូង ខ្ញុំចង់សួរសំណួរបើកជាមុនសិន។ នៅសម័យកម្ពុជាប្រជាធិបតេយ្យ ពេលដែលលោកនៅក្នុងភូមិភាគបស្ចិម តើលោកដឹងថា មានការសាងសង់ព្រលានយន្តហោះនៅខេត្តកំពង់ឆ្នាំងទេ?

**ឆ៖** បាទ ខ្ញុំដឹង។ តែមិនបានទៅទេ គ្រាន់តែថាដឹង ឮ ហើយនិងដឹងតែប៉ុណ្ណឹង តែមិនបានទៅឃើញទេ។ សូមអស់។

**ស៖** តើការដ្ឋានហ្នឹងជាការដ្ឋានផ្ទាល់របស់ ក្រោមបញ្ជាផ្ទាល់របស់មជ្ឈិមបក្សតែម្តង ឬក៏ស្ថិតនៅក្រោមបញ្ជារបស់ភូមិភាគបស្ចិម?

**ឆ៖** ន៎ខ្ញុំមិនបានដឹង របស់ហ្នឹងថា មិនដឹងជានៅមជ្ឈិមគ្រប់គ្រង ឬក៏ភាគគ្រប់គ្រង ខ្ញុំអត់បានដឹង។

[០៩:៥៣:១៥]

**ស៖** តើលោកដឹងទេថា មានយោធាត្រូវបានដាក់ទណ្ឌកម្ម ឬក៏បញ្ជូនទៅរៀនសូត្រនៅការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំងនោះ?

**ឆ៖** បាទ ខ្ញុំអត់បានដឹងដែរ។

**ស៖** ពាក់ព័ន្ធទៅនឹងភូមិភាគបស្ចិម នៅទំព័រទី១ ដែលខ្ញុំបានប្រគល់ជូនលោកនុ៎ង ជាភាសាខ្មែរគឺដាក់ចុងទំព័រ១ និងដើមទំព័រ២ ហើយជាភាសាអង់គ្លេស និងបារាំង គឺទំព័រ១។ តំបន់កំពង់ឆ្នាំង ជាចំណាងជើង ខ្ញុំសូមដកស្រង់៖ "សកម្មភាពខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង កាលពីយប់ថ្ងៃទី២៤ ខែ០៧ ឆ្នាំ៧៨ វេលាម៉ោងមួយកន្លះយប់ មានខ្មាំងរត់ចេញពីកន្លែងព្រលានយន្តហោះចំនួនបីនាក់។ ពេលនោះមិត្តយើងក៏បាញ់ ហើយចាប់បានវាពីរនាក់។" ហើយក្នុងរបាយការណ៍នេះដដែល មានហេតុការណ៍មួយទៀតដែលនិយាយអំពីខ្មាំងព្យាយាមរត់ចេញពីព្រលានយន្តហោះកំពង់ឆ្នាំង។ ដូច្នេះ តើលោកដឹងថាមានការព្យាយាមរត់ចេញពីការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំងទេ?

**ឆ៖** ខ្ញុំអត់ដឹងទេ។

**ស៖** ឥឡូវនេះខ្ញុំចូលទៅនិយាយអំពីបញ្ហាវៀតណាមនៅចន្លោះឆ្នាំ៧៧ ឆ្នាំ៧៨។ តើលោកធ្លាប់

ឮគេនិយាយថា វៀតណាមជាសត្រូវលេខ១ របស់កម្ពុជាប្រជាធិបតេយ្យទេ?

**ឆ៖** បាទ ឮគេនិយាយ ឮ ព្រោះអី ឮហើយព្រមទាំងសភាពការណ៍តាមព្រំដែនមានការប៉ះពាល់ប្រទូសប្រទាំងគ្នាខ្លះដែរ។

[០៩:៥៥:៤៩]

**ស៖** តើលោកធ្លាប់ឮថា វៀតណាមដែលនៅក្នុង ឬក៏ក្រៅទឹកដីកម្ពុជាហ្នឹង គឺជាសត្រូវស្លូពូជរបស់ខ្មែរទេ?

**ឆ៖** បាទ ឮ ប្រជាជនខ្មែរក៏ឮ ខ្ញុំក៏ឮទាំងអស់គ្នា ជាសត្រូវស្លូពូជ។

**ស៖** ដោយសារតែវៀតណាមជាសត្រូវស្លូពូជ ដូច្នេះតើកងពល១៦៤ ដែលលោកធ្វើការនៅកោះកុងនេះ មានភារកិច្ចចាត់ទុកវៀតណាមហ្នឹងជាខ្មាំងដែរឬទេ? ទោះបីជាវៀតណាមហ្នឹងជាទាហានក៏ដោយ ជាស៊ីវិលក៏ដោយ មានភេទប្រុស ភេទស្រី អាយុប៉ុន្មានក៏ដោយ គឺពួកលោកចាត់ទុកថាជាខ្មាំងទាំងអស់អ៊ីចឹងមែនទេ?

**ឆ៖** មិនមែនកងពល១៦៤ទេ ខ្ញុំកងពលលេខ១តើ។ លោកសួរថា ខ្ញុំកងពល១៦៤អំមិញ ខ្ញុំកងពលលេខ១ នៅកោះកុងផ្សេងតើ។ ហើយដូច្នេះ ខ្ញុំឃើញថា កងទ័ពឃើញជាសត្រូវអ៊ីចឹងហើយ ព្រោះអីបានវ៉ៃគ្នា ប្រយុទ្ធគ្នាជាបន្តបន្ទាប់ហើយ ដូច្នេះវាត្រូវជាសត្រូវរបស់ខ្ញុំហើយ បើនិយាយផ្ទាល់គឺថា វាមានការសត្រូវគ្នាហើយ។

**ស៖** ដោយសារតែមានការប្រឈមមុខគ្នាជាមួយនឹងវៀតណាម តើវៀតណាមរួមទាំងជនភៀសខ្លួននៅលើទូកហ្នឹងត្រូវបានគេចាត់ទុកថាជាខ្មាំងទាំងអស់មែនទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកស្រីមេធាវី អង់តា ហ្គីសសេ!

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំសូមជំទាស់ទៅនឹងសំណួររបស់សហព្រះរាជអាជ្ញា ពីព្រោះថាគាត់ធ្វើពុតដូចជាមិនចងចាំថាសាក្សីគាត់បានឆ្លើយច្បាស់ហើយកាលពីម្សិលមិញថា គេមិនចាត់ទុកជនភៀសខ្លួនវៀតណាមជាខ្មាំងទេ ពេលហ្នឹងគឺស្ថិតនៅក្នុងស្ថានភាពសង្គ្រាម។ អ៊ីចឹងសហព្រះរាជអាជ្ញាធ្វើដូចជាមិនដឹង មិនឮពីចម្លើយកាលពីម្សិលមិញនេះ។

[០៩:៥៨:៥០]

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

ខ្ញុំសូមជំទាស់។ លោកប្រធាន ខ្ញុំចាំច្បាស់ណាស់កាលពីម្សិលមិញ គាត់បាននិយាយថា តាមទស្សនៈរបស់គាត់ គេមិនចាត់ទុកជាខ្មាំងទេចំពោះជនភៀសខ្លួនទាំងអស់ហ្នឹង ក៏ប៉ុន្តែគាត់មិនដឹងពីជោគវាសនារបស់ពួកគេទេនៅពេលដែលគេបញ្ជូនទៅដល់កំពង់សោមហើយនោះ។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** អ៊ីចឹងពាក់ព័ន្ធទៅនឹងសត្រូវសួព្វជនេះ ខ្ញុំចង់អានទូវចម្លើយរបស់សាក្សី 2-TCW-1000 គាត់មកពីកងពល១៦៤។ នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់គាត់គឺ E319/23.3.54 គាត់បានឆ្លើយដូចតទៅ ក្នុងចម្លើយ៣១ ដល់៣៣ ខ្ញុំសូមដកស្រង់ គឺគេនិយាយអំពីកិច្ចការចាប់ខ្លួនជនជាតិវៀត-ណាមនៅលើកប៉ាល់។ "បើតាមលោក តើល្អទេដែលគេចាប់ -- ដែលគេសម្លាប់អ្នកចាប់បាននោះ? ចម្លើយ៖ ខ្ញុំគិតថា វាខុសទាំងស្រុង ពីព្រោះប្រជាជនទាំងអស់នោះមិនដឹងអ្វីទាំងអស់។ គឺពួកគាត់គ្រាន់តែរត់ចេញពីសង្គ្រាមដើម្បីរស់រានមានជីវិតតែប៉ុណ្ណោះ។ ប៉ុន្តែនៅពេលនោះខ្មែរក្រហមគិតថា ពួកយួនជាសត្រូវសួរពូជ។ ចម្លើយ៣២៖ បាទពីព្រោះថៃមិនមានទំនាស់ច្រើនជាមួយខ្មែរទេ នៅក្នុងប្រវត្តិសាស្ត្រ ប៉ុន្តែយួនមានទំនាស់ជាមួយខ្មែរច្រើន។ ទើបយួនត្រូវបានចាត់ទុកជាសត្រូវសួព្វជ និងសត្រូវទី១។ សំណួរទី៣៣៖ ហើយអ្វីបានជាលោកដឹងអំពីរឿងនេះ? ចម្លើយ៖ ពីព្រោះមេបញ្ជាការកងវរសេនាតូច និងវរសេនាធំទៅរៀនសូត្រជាមួយនឹងកងពល ហើយពេលគេត្រឡប់មកវិញ គេបានបង្រៀនយើងអំពីរឿងនេះ ក្នុងវគ្គអប់រំរៀនសូត្រ។" សូមបញ្ចប់ការដកស្រង់។ លោកសាក្សី តើលោកមានប្រតិកម្មយ៉ាងណាតបទៅនឹងចម្លើយរបស់សាក្សីរូបនោះ ដែលគាត់បាននិយាយថា វៀតណាមហ្នឹងជាសត្រូវសួព្វជ ហើយគឺមានទំនាស់ច្រើនជាមួយខ្មែរ មិនដូចថៃទេ គឺមានទំនាស់តិចតួច?

[១០:០១:១២]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

អញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំជំទាស់ទៅនឹងសំណួរនេះ។ អាចថាពីសប្តាហ៍មុន ឬក៏សប្តាហ៍ពីរ

កន្លងមកហ្នឹង គឺថាព្រះរាជអាជ្ញាបានជំទាស់ជាមួយនឹងការសួររបស់ខ្ញុំ ដោយសារខ្ញុំបានប្រើប្រាស់ភ័ស្តុតាងដោយការជ្រើសរើសយកបែបនេះ ប៉ុន្តែឥឡូវនេះ ព្រះរាជអាជ្ញាធ្វើដូចគ្នានឹងអ្វីដែលខ្ញុំបានធ្វើ។ គឺថាគាត់អានឲ្យសាក្សីស្តាប់នូវភ័ស្តុតាងដែលដកស្រង់ចេញពីកងពល១៦៤ គឺកងទ័ពឋានៈតូចមួយដែលចេញ ដែលជាការដកស្រង់សម្តីហ្នឹង គឺនិយាយផ្ទុយពីអ្វីដែលបានលើកឡើង។ ដូច្នេះខ្ញុំគិតថា ព្រះរាជអាជ្ញា គួរតែកែប្រែនូវវិធីសាស្ត្រនៃការចោទសួរបែបនេះ។

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

ខ្ញុំគិតថា ការជំទាស់នេះគឺមិនត្រឹមត្រូវនោះទេ ព្រោះកាលពីម្សិលមិញ យើងបានឮមេធាវីការពារក្តីបាននិយាយបានច្បាស់អំពីសក្ខីកម្ម ហើយដែលយើងជំទាស់ ហើយក្នុងរយៈពេល៤០នាទីកន្លងមក គឺយើងត្រូវបានគេជំទាស់ម្តងហើយម្តងទៀតៗ។ ដូច្នេះខ្ញុំសូមការអនុញ្ញាតពីលោកប្រធាន ឲ្យខ្ញុំបន្តទៅមុខទៀត។ សូមអរគុណ។

[១០:០២:៤២]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះបដិសេធនូវសេចក្តីជំទាស់បែបនេះ របស់មេធាវីការពារក្តីលោក នួន ជា។ សាក្សីឆ្លើយតបនឹងសំណួរ! ព្រោះសំណួរបើកបានសួរហើយ មានការរំខានពីភាគីមេធាវីការពារក្តីច្រើនលើកច្រើនសានៅក្នុងវគ្គនេះ។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** ខ្ញុំចង់សួរថា តើលោកយល់យ៉ាងម៉េចដែរ ចំពោះអ្វីដែលសាក្សីបាននិយាយថា គេគិតថាយួនមានទំនាស់ជាមួយខ្មែរច្រើន ប៉ុន្តែមិនមែន -- ប៉ុន្តែថៃវិញមិនសូវមានទំនាស់ច្រើនជាមួយខ្មែរនោះទេ។ តើលោកយល់យ៉ាងណាដែរ?

**ប្រធានអង្គជំនុំ៖**

កែសំណួរឡើងវិញ។ សំណួរនេះ យើងបានហាមរួចហើយ សាក្សីមិនអាចផ្តល់លក្ខណៈជាជំនាញទេ អ្នកជំនាញទេ។ កាលណាឲ្យគាត់យល់ជាអត្តនោម័តិរបស់គាត់ គឺគាត់ឋានៈ សួរឋានៈជាអ្នកជំនាញហើយ។ ហើយសំណួរបែបនេះ យើងបានប្រើប្រាស់ពាក្យមួយ គឺប្រតិកម្មយ៉ាងដូចម្តេចចំពោះសំណួរនេះ។ នេះយើងបានអនុញ្ញាតកន្លងមកដោយសារការពិភាក្សាគ្នាច្រើនលើកច្រើនសា សវនាការដូចជាច្រើនឆ្នាំហើយ។ រៀបចំសំណួរឡើងវិញ យើងមិនបណ្តែតបណ្តោយឲ្យប្រើប្រាស់ចេះតែបំប្លែង

នូវវិធីសាស្ត្រ នូវរបៀបសួរ តាំងសំណួរដេញដោលនៅទីនេះទេ។ របៀបបច្ចេកទេសគួរតែកម្រិតឲ្យបាន សមស្រប ដើម្បីអនុវត្តឲ្យបានត្រឹមត្រូវ។

[១០:០៤:២៩]

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** បាទ លោកប្រធាន ខ្ញុំបានសួរសាក្សីឲ្យបង្ហាញប្រតិកម្មរបស់គាត់ចំពោះសក្ខីកម្មដែលខ្ញុំបាន អានពីសាក្សីដទៃទៀត ដែលថា វៀតណាមជាសត្រូវស្នូលពូជរបស់កម្ពុជា និងជាសត្រូវ -- និងមាន ទំនាស់ច្រើនជាមួយខ្មែរ គឺមិនដូចថៃនោះទេ។

**លោក មាស វឿន៖**

**ឆ៖** ខ្ញុំមិនអាចនិយាយប្រៀបធៀបជាមួយថៃ និងវៀតណាមទេ។ បើលោកសួរពីរឿងវៀត-ណាម វៀតណាមហើយ។ បើសួរពីរឿងថៃ ខ្ញុំនិយាយពីថៃ។ តែខ្ញុំអត់យក អត់ទទួលសំណួរលោកពី រឿងថៃ ទទួលសំណួរពីរឿងយួនទំនាស់ជាមួយនឹងខ្មែរ អាហ្នឹងខ្ញុំនិយាយ។ ខ្ញុំប្រាប់រួចអស់ហើយ ហើយ ខ្ញុំអត់យកពីរឿងថៃមកជម្រាបលោកទេ។ សូមអស់។

**ស៖** នៅសវនាការថ្ងៃ១៦ ធ្នូ ២០១៥ ឯកសារ E1/369.1 គឺសាក្សីបាននិយាយដូចតទៅនេះ គឺ និយាយអំពីការអប់រំដែលគេធ្វើឡើងនៅកងវរសេនាធំ១៤០ ដែលនិយាយអំពីសត្រូវស្នូលពូជ។ ដូច្នេះខ្ញុំចង់ សួរថាតើ អ្នកបង្រៀនលោក គាត់បាននិយាយអ្វីទាក់ទងទៅនឹងខ្មាំង ក៏ដូចជាសត្រូវស្នូលពូជ គឺថាតាមការ នេះគឺថាពួកគេបញ្ជាឲ្យសម្លាប់ទាំងអស់ សូម្បីតែកូនង៉ែត ដោយសារតែពួកគេជាសត្រូវស្នូលពូជ។ ហេតុ ដូច្នេះហើយ វាជាការទទួលខុសត្រូវរបស់កងអនុសេនាធំ ក្នុងការសម្លាប់ទៅលើកង ទៅលើទាហាន ទៅលើជនជាតិវៀតណាមទាំងអស់?

[១០:០៦:៥៨]

**ឆ៖** ខ្ញុំសូមបញ្ជាក់ពីរឿងសត្រូវស្នូលពូជបន្តិច ពីព្រោះអីលោកអាចដឹងហើយ។ ក្នុងខ្មែរ ហើយ និងយួន បើយើងដឹងថា ជាសត្រូវយូរណាស់មកហើយ មិនមែនជាសត្រូវទើបសត្រូវ៧៩ហ្នឹងទេ។ សត្រូវតាំងពីយូរយារណាស់ហើយ តាំងពីខ្ញុំមិនទាន់កើត ក៏យួន ហើយខ្មែរហ្នឹងសត្រូវដែរ ហ្នឹងខ្ញុំឆ្លើយ ឆ្ងាយបន្តិចចុះ អាចមើលឃើញ។ ក៏ប៉ុន្តែយើងខ្ញុំផ្ទាល់ ខ្ញុំមានគំនិតមួយថា មួយខ្មាំងសត្រូវដែលកំពុង កាន់កាំភ្លើងវាយគ្នា អាហ្នឹងវាជាសត្រូវមួយ។ ក៏ប៉ុន្តែមួយ ជាប្រជាជនដែលៗរស់នៅជាសញ្ជាតិយួនដែរ នោះ ខ្ញុំផ្ទាល់ ខ្ញុំតែតែគិតដែរ។ បើៗអ៊ីចឹង បើខ្ញុំចាប់ កន្លងមកបើខ្ញុំចាប់យួនបាន ខ្ញុំកម្ទេចទាំងអស់នៅ

តាមមុខសញ្ញាកោះកុង ខ្ញុំបាត់ទៅហើយ។ ដូចខ្ញុំ អ៊ីចឹងបានជាខ្ញុំបញ្ជូនទៅតាមថ្នាក់ដឹកនាំរបស់ខ្ញុំ គេដោះស្រាយតាមមធ្យោបាយយ៉ាងម៉េច អាហ្នឹងវាជារឿងមួយផ្នែកខាងគេទៀត។ ហើយចំពោះខ្ញុំ ខ្ញុំគិតអ៊ីចឹងព្រោះអីខ្ញុំឃើញថា ចាប់បាន វាមិនមានជាទ័ព មិនមានជាកាំភ្លើង មិនមានជាគ្រឿងអាវុធ វាជាដៃទទេ អាហ្នឹងក៏ខ្ញុំបញ្ជូនតាមហ្នឹង តាមដំណើរដែលខ្ញុំមានគំនិតមួយថា ខ្ញុំគិតឃើញថាជាប្រជាជនធម្មតា ដើម្បីរកសេចក្តីសុខ។ អ៊ីចឹងខ្ញុំមានមតិឃោបល់ប៉ុណ្ណឹងជម្រាបលោក។

**ស៖** ឥឡូវនេះខ្ញុំសូមអានមួយសាទៀត ទៅលើអ្វីដែលលោកបានអានគឺ E3/1.3 គឺ E319/23.3.32។ ខ្ញុំសូមដកស្រង់៖ “ជាទូទៅ នៅពេលដែលយើងទៅដល់កប៉ាល់ ឬក៏ទូកណាមួយ គឺយើងត្រូវតែអែបទូក ហើយទាហានរបស់យើងលោតចូលទៅក្នុងសមុទ្រ ហើយបន្ទាប់មកឡើងទៅលើទូកនោះ គឺថាពួកគេលោតចូលទៅក្នុងទឹក ហើយបន្ទាប់ៗមកទៀត ពួកទាហានហ្នឹងវាលោតចូលទឹក ហើយយើងកម្ទេចទាំងអស់។” ដូច្នេះលោកបានប្រាប់អ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតជាច្រើនដងថា គឺគេនឹងតាមដានមើល ថាតើអ្នកនៅលើទូកហ្នឹង ជាថៃ ឬក៏វៀតណាម។ ហើយមិនត្រូវបានបញ្ជូនទៅទីបញ្ជាការធំទេ ប៉ុន្តែសម្លាប់ចោលតែម្តង។ ដូច្នេះខ្ញុំចង់ដឹងថា តើលោកនិយាយមានន័យយ៉ាងម៉េចដែលថា អ្នកដែលនៅសល់លើទូកយើងនឹងកម្ទេចចោលនោះ។ ដូច្នេះតើអ្នកណាដែលលោកនិយាយថា យើងហ្នឹង តើកងពល១០ ឬកងពល៦៤?

[១០:១០:១៤]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកស្រីមេធាវី អង់តា ហ្គីសសេ!

ហើយកងពល១០ ឬក៏កងពល១៦៤ ហ្នឹងដូចអត់មានទេកងពល១០ មានតែកងពល១។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

បាទ ការពិតខ្ញុំនិយាយអំពីកងពលលេខ១។

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវីការពារក្តី!

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ ប្រសិនបើយើងនិយាយអំពីឯកសារ E319/23.3.32 គឺសំណួរ

ចម្លើយលេខ៨ តើអ៊ីចឹងមែនទេ? ប៉ុន្តែប្រសិនបើអ៊ីចឹងខ្ញុំជំទាស់ទៅនឹងការសួរសំណួរចម្លើយទី៨ ដែលព្រះរាជអាជ្ញាបានលើកឡើងនេះ ព្រោះថា នៅក្នុងសំណួរចម្លើយនេះ សាក្សីបានបង្ហាញភាពខុសគ្នារវាងទូកស៊ីវិល ឬក៏ទូកកប៉ាល់ចម្បាំង។ ហើយគាត់និយាយថា មុននឹងចូលទៅជិត យើងត្រូវពិនិត្យមើល ថាតើជាទូកស៊ីវិល ឬក៏ជាទូកនេសាទដែលអមដោយកប៉ាលចម្បាំង។ ដូច្នេះកាលដែលនិយាយបែបនេះ គឺកាលដែលព្រះរាជអាជ្ញាថា ធ្វើជាមួយទូកទាំងអស់ហ្នឹង គឺជាការមិនត្រឹមត្រូវទេ ព្រោះគឺមានការបែងចែកច្បាស់រវាងទូកស៊ីវិល និងទូកដែលមានកប៉ាល់ចម្បាំង។

[១០:១១:៥៣]

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្អាងលេះ**

**ស៖** តាមពិតទៅ ខ្ញុំនិយាយខុស គឺខ្ញុំនិយាយទៅសំណួរចម្លើយទី៩ទេ។ គឺនៅចុងនៃសំណួរចម្លើយទី៩៖ "ជាធម្មតាដល់ពេលយើងចូលទៅចាប់ទូកណាមួយ យើងត្រូវតែបើកកាណូតរបស់យើងទៅអែបនឹងទូកនោះសិន ហើយយោធារបស់យើងប្រុងប្រៀបជានិច្ចពេលដែលលោតចូលក្នុងទូកនេសាទនោះ។ ជាទូទៅ អ្នកដែលនៅលើទូកបានលោតចូលទឹក ហើយអ្នកដែលនៅសល់លើទូក គឺយើងនឹងកម្ទេចចោល។" ដូច្នេះតើលោកអាចអាចបញ្ជាក់បានទេ ថាអ្នកនៅលើទូកបានលោតចូលទឹក ហើយអ្នកដែលនៅលើទូក គឺយើងនឹងកម្ទេចចោល។ ដូច្នេះខ្ញុំចង់សួរលោកថា ជាដំបូងតើទាហានរបស់កងពល១ ឬកងពល១៦៤ គឺជាអ្នកទទួលខុសត្រូវលើការកម្ទេចចោលអ្នកដែលនៅលើទូកហ្នឹង តើអ៊ីចឹងមែនទេ?

**ឆ៖** តាមខ្ញុំដឹង ចាំមើលខ្ញុំជម្រាបជូនពីសភាពហ្នឹង។ ទូកថៃវាចាប់ត្រីក្នុងដែនសមុទ្រយើង ហើយយើងនឹងទៅល្បាតមើល តើទូកហ្នឹងជាទូកមានទូកប្រជាជន ឬក៏មានកប៉ាល់អមការពារ។ ដល់យើងទៅមើល យកទូកទៅមើលអត់មានយកកប៉ាល់ទៅមើលទេ យកទូកដូចគ្នាទៅមើល។ ទៅមើលទូកគេ ទូកប្រជាជនមែន ហើយយើងក៏ទូករបស់យើង ក៏ជារបៀបប្រជាជនដែរ មិនមែនជាទូកយោធាទេ ប៉ុន្តែគ្រាន់តែថា យើងក៏មានអាវុធ។ ក៏ប៉ុន្តែយើងបើកទៅដល់ជិតទៅ ទូកប្រជាជនគេមែន ប៉ុន្តែគេមានកាំភ្លើង គេបាញ់យើងមុនមកៗ យើងក៏បាញ់តវិញទៅ។ ដូច្នេះវាមិនមានកប៉ាល់អមការពារទេ ក៏ប៉ុន្តែទូកនេសាទសុទ្ធតែមានកាំភ្លើងនៅក្នុងទូក។ ដល់បាញ់អ៊ីចឹង យើងក៏បាញ់ដែរ។ ដល់បាញ់ទៅ ទូកយើងរាងធំជាងគេបន្តិច ដល់នេះទៅ បាញ់ជិតទៅយកអែប យកទូកទៅអែបជិតគ្នាទៅវា យើងត្រូវតែលោតចូលក្នុងទូកគេទៅ គេលោតទម្លាក់ទឹកខ្លះ យើងលោតតោងទូកគេបាន។ ហើយយើងនាំទូកថៃហ្នឹងមក។ អត់ដឹងថា ទូកថៃហ្នឹងនៅ មនុស្សថៃនៅឯក្រោមម៉ាស៊ីនក្រោម យើងក៏បើកឯលើទៅ ស្រាប់តែ

មកដល់ -- មិនទាន់ដល់កោះផង កាណូតហ្នឹង កាណូតដែលនាំមកហ្នឹងត្រូវលិចទឹក លិចទាំងថៃនៅក្រោមហ្នឹង លិចទាំងពួកយើងពីរនាក់លើហ្នឹង លិចទាំងអស់គ្នា។ ដូច្នេះអត់ទាន់មាននរណាសម្លាប់នរណានៅឡើយទេ ប៉ុន្តែនៅពេលដែលបាញ់គ្នាយើងចាប់បានទូកគេមុន ក៏ប៉ុន្តែក្រៅពីហ្នឹងកម្លាំងនៅក្នុងទូកហ្នឹងរត់លោតទម្លាក់ទឹក។--

[១០:១៥:១៣]

**ស៖** *(គ្មានការបកប្រែ)*

**ឆ៖** ដូច្នេះបានន័យថា មកដល់ -- មិនទាន់ដល់កោះផង កាណូតហ្នឹងលិចទាំងអស់គ្នា។ លិចទាំងអស់គ្នាទៅ មនុស្សយើងក៏លង់ទឹក មនុស្សថៃក៏លិចលង់ទាំងអស់គ្នាទៅ បាត់ទូកតែទាំងអស់គ្នា។ អ៊ីចឹងក្នុងរឿងហ្នឹង ដែលខ្ញុំបានដឹងនៅខាងខ្ញុំមានអ៊ីចឹង។ ឯខាង៦៤ ខ្ញុំមិនដឹងគេមានរបៀបម៉េចទេ ខ្ញុំមិនបានដឹង។ សូមអស់។

**លោក វាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

លោកប្រធាន។ ខ្ញុំបានដាក់សំណួរពាក់កណ្ដាលរួចទៅហើយ ហើយខ្ញុំគិតថា ដូច្នេះខ្ញុំសូមអនុញ្ញាតលោកប្រធានសូមបន្ថែម១៥នាទី ដើម្បីឱ្យខ្ញុំអាចបញ្ចប់ការសួរសាក្សីនេះ ព្រោះសាក្សីនេះជាសាក្សីដ៏សំខាន់មួយរូប។ វាជាការសោកស្ដាយ ប្រសិនបើសាក្សីនេះត្រូវបានបញ្ចប់ដោយមិនឱ្យខាងសហព្រះរាជអាជ្ញាបានសួរឱ្យបានពេញលេញ។ ដូច្នេះខ្ញុំសូមការអនុញ្ញាតពីលោកប្រធាន ដើម្បីផ្ដល់ពេលវេលាដែលយើងខ្ញុំថែម១៥នាទីទៀត។ សូមអរគុណ។

[១០:១៦:៣៩]

**ប្រធានអង្គជំនុំ៖**

ពីព្រឹកមិញយើងបានប្រាប់ហើយថា នៅពេលវេលានៅសល់១៥នាទី សម្រាប់វគ្គទី១ អ៎! វគ្គទី២ ម៉ោងដំបូងនៃវគ្គទី២។ តើមានបញ្ហាអីទៀតទេ ព្រោះយើងបានបញ្ជាក់តាំងពីព្រឹកមិញម្ល៉េះ?

**លោក វាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

បាទ លោកប្រធាន គឺយើងខ្ញុំចង់បានពេលវេលាបន្ថែមទៀត បន្ថែម១៥នាទីទៀត ដោយសារតែព្រឹកនេះ មានការជំទាស់យ៉ាងច្រើន ហើយវាធ្វើឱ្យការសួរដេញដោលរបស់ខ្ញុំមានការយឺតយ៉ាវ។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត!

បាទ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់កន្លះ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់ រួមទាំងមេធាវីប្រឹក្សាសាក្សីមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញ នៅវេលាម៉ោងដប់កន្លះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:១៧ នាទី ដល់ម៉ោង ១០:៣៤ នាទី)*

[១០:៣៤:៣៧]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយតទៅនេះផ្តល់វេទិកាជូនទៅក្រុមតំណាងសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីសួរសំណួរដេញដោលសាក្សីរូបនេះ។ សូមអញ្ជើញ!

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

អរគុណច្រើនលោកប្រធាន។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** លោកសាក្សី កាលពីម្សិលមិញលោកនិយាយថា មានកប៉ាល់ជនភៀសខ្លួនវៀតណាមតិចតួចណាស់នៅកោះកុង។ លោកថាប្រហែលជាគេបើកផ្លូវវាងដើម្បីទៅដល់ទីនោះ។ ខ្ញុំសូមដកស្រង់នូវចម្លើយរបស់លោក ដែលលោកបានឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជា លោកនិយាយអំពីជនជាតិវៀតណាម១០០នាក់ជាង។ គឺឯកសារ E3/8752 ទំព័រ២៦ជាភាសាអង់គ្លេស និង២៨, ២៩ ជាភាសាខ្មែរ។ លោកបាននិយាយដូចតទៅ៖ "មិនមានចោរព្រៃទេ មានតែជនជាតិវៀតណាមដែលរត់គេចតាមទូក ហើយឆ្លងកាត់តាមផ្លូវរបស់យើង។ មានជនជាតិវៀតណាមរាប់រយនាក់ ពួកគេរត់គេចទៅប្រទេស

ថៃ ដើម្បីធ្វើដំណើរទៅសហរដ្ឋអាមេរិក។ ហើយបន្តទៅមុខទៀត ពួកគេបានចាកចេញ ដោយនៅពេលដែលពួកគេចាញ់វៀតណាមខាងជើង ដូច្នេះគេបានឆ្លងកាត់សមុទ្ររបស់យើង ឆ្ពោះទៅកាន់ប្រទេសថៃ។ យើងបានចាប់ពួកគេ និងបញ្ជូនពួកគេទៅកំពង់សោម។ បន្ទាប់មកគេបានចរចាចំពោះការចាប់ខ្លួននេះ។ ខ្ញុំមិនដឹងថា តើប្រជាជនទាំងនោះមកទីណាទេ។ សួរៈ តើពួកគេត្រូវបានបញ្ជូនទៅទីណា? ឆ្លើយៈ គឺបញ្ជូនទៅអគ្គសេនាធិការនៅកំពង់សោម។ ខ្ញុំមិនដឹងថាគេដោះស្រាយយ៉ាងម៉េចជាមួយពួកទាំងនោះទេ។"

[១០:៣៦:៥៨]

ក្នុងឃ្លាំនេះលោកបាននិយាយថា មានវៀតណាមរាប់រយនាក់ រត់ភៀសខ្លួនចេញពីប្រទេសរបស់ខ្លួន។ នៅពេលដែលលោកនិយាយអំពីជនជាតិវៀតណាមរាប់រយនាក់នេះ លោកសំដៅទៅលើអ្នកដែលត្រូវបានចាប់ខ្លួននៅកោះកុង ឬក៏លោកនិយាយជាលក្ខណៈទូទៅ គឺលោកសំដៅទៅជនជាតិវៀតណាមដែលនៅតាមឆ្នេរផ្សេងៗទៀត មិនសំដៅតែនៅលើកោះកុងទេ? តើលោកអាចបញ្ជាក់ចំណុចនេះបានទេ?

**លោក មាស វឿន៖**

**ឆ៖** បាទ នៅតាមកោះអត់មានទេ មិនមានពួកវៀតណាមនៅទេ ព្រោះពី វាអស់។ អស់មានកន្លែងនៅហើយ គេ សូម្បីតែខ្មែរយើងក៏មិនបាននៅដែរតាមកោះ។ ខ្ញុំនិយាយតែត្រឹមវៀតណាមរត់ពីនិយាយរួមរត់ពីស្រុកយួន មិនដឹងរត់ពីកោះត្រល់ ខ្ញុំមិនដឹងដែរ ប៉ុន្តែគេឆ្លងកាត់តាមដៃព្រែក តាមឆ្នេរសមុទ្រយើងមក តាមទូកម្តង។ ទូកតូចៗទេ មិនមែនជាកប៉ាល់ទេ ទូកខ្នង់៣០សេស ២៥សេសអីប៉ុណ្ណឹង។ ម្តងជិះ១០នាក់អី ១៥នាក់អីអ៊ីចឹង មិនបានជិះបានច្រើនទេ។ ដូច្នេះខ្ញុំនិយាយតែពីត្រឹមកាណូតវៀតណាមដែលត្រូវរត់ចេញទេ អត់មាននិយាយពីរឿងទូទៅទេ។ អស់។

**ស៖** តើលោកធ្លាប់ទទួលបញ្ជាពីថ្នាក់លើឲ្យប្រុងប្រយ័ត្នចំពោះគិញ ដែលថាអាចមានគិញលួចបង្កប់ខ្លួននៅក្នុងចំណោមជនភៀសខ្លួនទាំងអស់នោះ? លោកធ្លាប់មានទទួលបញ្ជាបែបហ្នឹងទេ?

**ឆ៖** បាទ អត់មានទេ។ ខ្ញុំអត់បានទទួលបញ្ជាហ្នឹងទេ តែខ្ញុំត្រូវតែប្រយ័ត្នតាមបច្ចេសទេស និងយុទ្ធវិធីរៀង តាមអង្គភាពខ្ញុំ។

[១០:៣៩:៣០]

**ស៖** កាលពីម្សិលមិញ លោកឆ្លើយថា ដោយសារតែពួកគេជាជនភៀសខ្លួនវៀតណាម លោក

មិនចាត់ទុកពួកទាំងអស់ហ្នឹងជាខ្មាំងទេ។ បើលោកមិនចាត់ទុកថា ជាខ្មាំង ហេតុអីបានជាលោកចាប់អ្នកទាំងអស់ហ្នឹង?

**ឆ៖** បាទ អាហ្នឹងជាក្រឹត្យក្រម ធម្មតាប្រទេសមួយឆ្លងប្រទេសមួយ ត្រូវតែចាប់អ៊ីចឹងហើយ ច្បាប់ទម្លាប់។ បើយើងមិនចាប់ ឲ្យគេដើរតាមដំណើរ តាមហូរតាមហែដូចជាផ្លូវធម្មតា ហ្នឹងម៉េចៗថា យើងកិច្ចការពារប្រទេសយើងបាន។

**ស៖** នៅក្នុងចម្លើយដែលខ្ញុំបានអានទុំង លោកនិយាយអំពីជនជាតិវៀតណាមរាប់រយនាក់ ហើយលោកចាប់ខ្លួនពួកគេ។ ដូច្នេះលោកអាចបញ្ជាក់បានទេថា កងកម្លាំង កងពលលេខ១មែនទេ ដែលជាអ្នកចាប់ខ្លួនជនជាតិវៀតណាមរាប់រយនាក់ ហើយបញ្ជូនទៅកំពង់សោមនេះ?

**ឆ៖** បាទ។ កងពលលេខ១ហ្នឹង ចាប់អ៊ែ ចាប់បញ្ជូនទៅខាងកំពង់សោម ហើយទៅឲ្យទៅខាងកំពង់សោម។

**ស៖** ប្រធានបទចុងក្រោយ លោកបាននិយាយថា នៅកោះកុង លោកមានកូនទាហាន២.៧០០ នាក់ ហើយក្រោយមកគឺនៅសល់តែ១.៧០០នាក់ទេ។ លោកក៏បានឆ្លើយផងដែរថា ជនស៊ីវិលគឺត្រូវបានគេជម្លៀសចេញពីកោះផ្សេងៗ ទៅដីគោក។ ហើយលោកថា លោកនៅក្នុងចំណោមក្រុមរបស់លោកហ្នឹង គឺមិនមានអ្នកណាជាស្ត្រីទេ មែនទេ? ដូច្នេះខ្ញុំចង់សួរបញ្ជាក់ឲ្យលោកច្បាស់ថា ក្រោយពីសង្គ្រាម ៥ឆ្នាំជាមួយ លន់ នល់ ហើយនោះ តើទាហានទាហានច្រើននៅក្នុងកងពលរបស់លោកហ្នឹង គឺកងពលលេខ១ហ្នឹង សុទ្ធតែជាអ្នកនៅលីវ មែនទេ? ហើយសុទ្ធតែដល់អាយុរៀបការ មែនទេ?

[១០:៤១:៥៤]

**ឆ៖** បាទ ចម្រុះ មានទាំងអ្នកមានប្រពន្ធក៏មាន អ្នកមានអាយុច្រើនក៏មាន អាយុតិចក៏មាន។ វាមានចម្រុះគ្នាទាំងអស់ហ្នឹង។

**ស៖** តើគេមានជំរុញឲ្យ គឺថ្នាក់លើរបស់លោក មានជំរុញឲ្យមានការរៀបការនៅក្នុងកងពលលេខ១របស់លោកហ្នឹងទេ ឧទាហរណ៍ដូចជា តាស៊ី, តាសឿង, សុន សេន ជាដើមនោះ មានជំរុញឲ្យមានការរៀបការនៅក្នុងកងពលលេខ១ហ្នឹងទេ?

**ឆ៖** បាទ មានគាត់ដែលនាំឲ្យរៀបការអ៊ីចឹងដែរ អ្នកណាដែលដល់អាយុ ទើបអាយុ២០អី គាត់ឲ្យរៀបចំបណ្តើរៗដែរ ប៉ុន្តែគាត់អត់មាននារីណានៅហ្នឹងទេ ប៉ុន្តែគាត់ដឹកកាលពីៗមន្ទីរគាត់ពីហ្នឹងមកយកមកឲ្យ មើល ឲ្យរៀបការហ្នឹង។

**ស៖** តាមរយៈឯកសារបោះពុម្ពផ្សាយដូចជា ទស្សនាវដ្ដីទង់បដិវត្តជាដើមនោះ លោកធ្លាប់ឮថា បក្សចង់បង្កើនចំនួនប្រជាជនឱ្យបានច្រើន ដោយសារតែវៀតណាមនុ៎ង មានចំនួនប្រជាជនច្រើនជាង។ លោកធ្លាប់ឮបែបហ្នឹងទេ?

**ឆ៖** បាទ ឮ។

**ស៖** តើការជំរុញឱ្យកងទ័ពរៀបការហ្នឹង វាពាក់ព័ន្ធទៅនឹងឆន្ទៈរបស់ថ្នាក់ដឹកនាំក្នុងការបង្កើនចំនួនប្រជាជននៅប្រទេសកម្ពុជា មែនទេ?

**ឆ៖** បាទ មែន។

**ស៖** តើលោកមានធ្លាប់ធ្វើបញ្ជីឈ្មោះទាហាន កូនទាហាននៅក្នុងកងពលរបស់លោក ដែលចង់រៀបការទេ?

[១០:៤៤:២៥]

**ឆ៖** បាទ ធ្វើតើ បានរៀបខ្លះបណ្ដើរៗដែរតើ។

**ស៖** លោកបាននិយាយថា នៅក្នុងតំបន់របស់លោក ឬក៏នៅក្នុងកងពលរបស់លោក គឺមិនមានស្ត្រីទេ មិនមានជនស៊ីវិលជាស្ត្រីទេ។ អ៊ីចឹងតើទាហានទាំងអស់ហ្នឹង រៀបការជាមួយនឹងអ្នកណា បើអត់មានស្ត្រីផង? ហើយមុននេះលោកបាននិយាយថា តាស៊ី បានយកស្ត្រីមកពីមន្ទីររបស់គាត់។ អ៊ីចឹងខ្ញុំយល់អ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** បាទ មិនមែនយកពីកន្លែង តាស៊ី ទេ យកពីកន្លែងកងពលខ្ញុំ ព្រោះកាលនោះមានកងនារីមួយកងធំដែរ គេនៅប្រចាំនៅ ជាមួយនឹងកងពលហ្នឹងឯង។

**ស៖** តើចំនួនស្ត្រីនៅក្នុងកងហ្នឹង គ្រប់គ្រាន់ឱ្យទាហានដែលមានអាយុត្រូវរៀបការនៅក្នុងកងពលលេខ១ហ្នឹងអាចរៀបការបានទេ គឺគ្រប់គ្រាន់ទេ ចំនួនហ្នឹង ឬក៏ត្រូវការយកស្ត្រីមកពីកន្លែងផ្សេងទៀតដើម្បីមកឱ្យរៀបការជាមួយនឹងកងទ័ពទាំងអស់ហ្នឹង?

**ឆ៖** មិនគ្រប់ទេ។ តែយើងរៀបបណ្ដើរៗ មិនទាន់អស់ឯណា បើថាឱ្យគ្រប់វាមិនទាន់គ្រប់ទេ។

**ស៖** អ៊ីចឹងស្ត្រីដែលមកពីខាងក្រៅហ្នឹង គាត់ស្គាល់ទាហានដែលខ្លួននឹងត្រូវរៀបការជាមួយនឹងពីមុនមកទេ?

**ឆ៖** ស្គាល់ដែរហ្នឹងឯង ស្គាល់ខ្លះដែរហ្នឹង។

[១០:៤៦:៣៩]

**លោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

សូមអរគុណ។ ខ្ញុំអស់សំណួរហើយលោកប្រធាន សូមអនុញ្ញាតប្រគល់វេទិកានេះ ជូនសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ!

**លោក ឡោ ជុនធី៖**

បាទអរគុណលោកប្រធាន។ សូមគោរពអង្គជំនុំជម្រះទាំងមូល។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី**

**សួរដោយលោក ឡោ ជុនធី៖**

**ស៖** សូមជម្រាបសួរលោកសាក្សី ខ្ញុំបាទ ឡោ ជុនធី ដែលជាមេធាវីតំណាងដើមបណ្ដឹងរដ្ឋ-ប្បវេណី ហើយខ្ញុំជាមេធាវីមកពីអង្គការជំនួយផ្នែកច្បាប់នៅកម្ពុជា។ នៅពេលនេះ ខ្ញុំបាទសុំជម្រាបសួរទៅលោកសាក្សី ពាក់ព័ន្ធទៅនឹងបរិបទដែលជាការបទពិសោធន៍របស់លោកសាក្សីពីឆ្នាំ១៩៧៥ ដល់ ១៩៧៩។ ជាដំបូង ខ្ញុំបាទសូមជម្រាបសួរថា នៅឆ្នាំ១៩៧៥ ភ្លាមដែលលោកថា បាននាំកងទ័ពវាយចូលទៅភ្នំពេញ។ ថាតើការដែលនាំកងទ័ពវាយចូលទៅភ្នំពេញហ្នឹង ទៅតាមច្រកណាខ្លះ ចំពោះកងពលរបស់លោកសាក្សី?

[១០:៤៨:២០]

**លោក មាស វឿន៖**

**ឆ៖** បាទ ខ្ញុំសូមជម្រាបជូនលោកអំពីវៃចូល៧៥ ចូលទៅភ្នំពេញ។ ខាងកងពលនិរតីកាលនោះមានតែកងពលនិរតីតែមួយទេ មិនទាន់មានរៀបចំច្រើន។ គឺមានកងពលនិរតីតែមួយទេដែលនៅពីទិសខាងលិច។ ពីទិសខាងលិចហ្នឹង គឺចូលពីពោធិ៍ចិនតុង ហើយអូរបែកក្អម និងស្ទឹងមានជ័យ ហ្នឹងកងពលលេខ១។ ខ្ញុំសូមបញ្ជាក់ប៉ុណ្ណេះ។

**ស៖** បាទ អរគុណ។ នៅពេលដែលកងពលលោកសាក្សីបានចូលទៅដល់ភ្នំពេញ តើចូលទាំងបីច្រកហ្នឹង ហើយទៅដល់ចំណុចណានៃទីក្រុងភ្នំពេញដែលហៅថា ទៅដល់កន្លែងនោះ គឺចាប់ដៃគ្នារវាងកងពលផ្សេងៗ ដែលវាយចូលភ្នំពេញ?

**ឆ៖** បាទ ខ្ញុំបានទទួលបញ្ជាពីលេខាកងពល មកខាងមុខសញ្ញាកងពលលេខ១ គឺចូលបីមុខសញ្ញា ហើយកងពលដទៃទៀត គ្រាន់តែខ្ញុំបាទទទួលខ្លះថា ខាងឧត្តរនឹងចូលពីកើត ហើយខាងជើងខាងភូមិភាគឧត្តរចូលពីជើង ខាងបូព៌ាចូលពីកើត។ ហ្នឹងគឺបានទទួលជារួមអ៊ីចឹង។ ក៏ប៉ុន្តែទិសដៅសំខាន់ដែលការដែលចូលហ្នឹង គឺមុខព្រួញតូចៗទៀត ខ្ញុំមិនបានដឹងទេ ហើយសំខាន់សំដៅទៅចាប់ដៃគ្នាហ្នឹង នៅកន្លែងអគ្គសេនាធិការ។ សូមអស់។

**ស៖** បាទ អរគុណណាស់។ ចំណុចសំខាន់មួយទៀតថា នៅពេលដែលយើងចាប់ដៃគ្នាហើយនោះ ថាតើមានខាងណាដែលបញ្ជាឲ្យកងទ័ពខាងលោកសាក្សីហ្នឹងដកចេញវិញ?

**ឆ៖** បាទ ក្រោយពីបានវៃចាប់ដៃគ្នារួចហើយនោះ កងទ័ពខាងខ្ញុំដែលបានបញ្ជាចេញឲ្យមកនៅខាងក្រៅ គឺបញ្ជាពី តាម៉ុក តាមរយៈកងពលខ្ញុំផងគឺ បងសឿង។

[១០:៥១:២៨]

**ស៖** បាទ អរគុណ។ ខ្ញុំសូមត្រឡប់ទៅក្រោយបន្តិច គឺថានៅពេលដែលចេញពីទីក្រុងភ្នំពេញលោកសាក្សីបានឆ្លើយហើយថា អត់ដឹងពីការបញ្ជាឲ្យការជម្លៀសប្រជាជនចេញទេ។ តើចំណុចហ្នឹងលោកសាក្សីលើកបែបនេះ ថាតើប្រជាជនដែលដើរចេញទៅបានជួបគាត់ ហើយបានសួរគាត់ទេថាតើការឲ្យចេញហ្នឹង ចេញដោយស្ម័គ្រចិត្ត ឬមួយចេញយ៉ាងម៉េច?

**ឆ៖** បាទ ក្រោយពីបានបញ្ជាឲ្យចេញ ឲ្យកងទ័ពខ្ញុំចេញមកខាងក្រៅ គឺខ្ញុំសម្រាកនៅត្រឹមតែអូរបែកក្អម ហើយនិងមកដល់ផ្លូវលេខ៣ ហើយនិងផ្លូវលេខ៤ សម្រាកនៅត្រង់ហ្នឹង។ ប្រហែលរយៈក្រោយមកៗ ខ្ញុំសម្រាកបានប្រហែល ខ្ញុំមិនចាំច្បាស់ ប្រហែលជាជិតមួយអាទិត្យ ឃើញប្រជាជនគាត់ចេញមក។ គាត់ចេញមក ខ្ញុំសួរគាត់ថា ទៅខាងណាវិញអ៊ំ គាត់ថា អ្ហ! អង្គការគេឲ្យចេញៗហើយ។ ហើយអ៊ំចេញទៅខាងណាវិញ? មិនដឹងទៅខាងណាទេ វា គេចេះតែឲ្យមកអ៊ីចឹងហើយ។ ខ្ញុំបានដឹងតាមរយៈប្រជាជនហ្នឹង ហើយចុះគេឲ្យមកស្រួល ឬក៏អ៊ំឯងចេញដោយខ្លួនឯង? អត់ទេ ថាអង្គការឲ្យចេញមកទៅនៅកន្លែងណាបាន នៅកន្លែងហ្នឹង។ ហ្នឹងខ្ញុំបានសួរអ៊ីចឹង ខ្ញុំនៅតែតាមដើមៗផ្លូវៗហ្នឹង។ សួរគាត់អ៊ីចឹង ឃើញខ្លះក៏បើកឡានមក ខ្លះក៏បើក ធាក់ស៊ីក្លូមក ខ្លះក៏អូសរទេះអូសអីមក។ ខ្ញុំឃើញបន្តៗគ្នាអ៊ីចឹងទៅ។ ខ្ញុំសួរគាត់បានប៉ុណ្ណឹង។ ខ្ញុំក៏ គាត់ទៅខាងណាក៏ទៅចុះ ស្រេចតែគាត់ យើងអត់មានឃាត់ឃាំងអីទេ ខាងខ្ញុំអត់ឃាត់ឃាំងអីទេ តាមដំណើររបស់គាតទៅៗ។ មានប៉ុណ្ណឹង ពួកខ្ញុំអត់មានធ្វើអីទាំងអស់។ នៅចាំតែប៉ុណ្ណឹង។ សូមអស់។

[១០:៥៤:០៥]

**ស៖** បាទ អរគុណ។ ខ្ញុំសូមត្រឡប់ទៅក្រោយបន្តិច ថាតើមុនពេលដែលកងទ័ពលោកសាក្សីចូលមកវាយផ្តាច់នៅភ្នំពេញហ្នឹង តើមានការណែនាំពីខាងលើបញ្ជាឲ្យមកខាងលោក ឬមួយខាងណាដែលបញ្ជាខាងលោកហ្នឹង ថាឲ្យវាយចូលហ្នឹង? ហើយតើមានការប្រជុំគ្នាមុនដែរអត់ ដែលរៀបចំការវាយចូលភ្នំពេញនេះ?

**ឆ៖** បាទ តាមការដឹងខ្លះ ខ្ញុំដឹងពីកងពលខ្ញុំ ប្រហែលជា ខ្ញុំគ្រាន់ប្រហែលទេ ប៉ុន្តែប្រហែលជាកងពលខ្ញុំបានទៅប្រជុំជាមួយថ្នាក់ដឹកនាំខាងលើទៀត បានជាគាត់មកប្រាប់ខ្ញុំថា ឲ្យរៀបចំវ៉ៃចូលភ្នំពេញ ថ្ងៃ១៨ មេសា គឺយើងកំណត់យកថ្ងៃ១៨ មេសា ឲ្យឈ្នះ ដើម្បីវ៉ៃផ្តាច់ ដើម្បីកុំឲ្យយួនវារៀបចំវ៉ៃយើង។ អាហ្នឹងគេនិយាយអ៊ីចឹង គេនិយាយប្រាប់ខ្ញុំអ៊ីចឹង ប៉ុន្តែខ្ញុំចាំបានអ៊ីចឹង។ ដូច្នេះការបញ្ជាមក គឺថាខ្ញុំទទួលបានពីត្រឹមកង ខ្ញុំអត់បានទៅប្រជុំរួមជាមួយអ្នកដឹកនាំខ្ពស់ៗទេ ទទួលបានប៉ុណ្ណឹង។ ហើយក្នុងពេលដែលវ៉ៃចូលផ្តាច់ហ្នឹង គឺឲ្យវ៉ៃឈ្នះថ្ងៃ១៨ ប៉ុន្តែយើងរៀបចំទៅ ត្រូវវ៉ៃឈ្នះថ្ងៃ១៧វិញ។ សូមអស់។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះរំឭកសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្រែងលោមានការភ័ន្តច្រឡំអំពីអង្គហេតុ។ អង្គហេតុដែលសួរនេះ ទំនងជានៅក្នុង០០២/០១ យើងធ្វើសវនាការរួចហើយ។ ហើយ ០០២/០២ យើងធ្វើគោលដៅជាក់លាក់ចំពោះជនជាតិវៀតណាម ហើយនិងគោលដៅចំពោះអតីតទាហាននៃរបបសាធារណរដ្ឋខ្មែរ។ ក្រែងលោមានការភ័ន្តច្រឡំ ហើយវាសួរទៅវាអត់ប្រយោជន៍ ហើយជាន់នឹងអ្វីដែលយើងបានធ្វើរួចហើយ។ យើងអនុញ្ញាតឲ្យករណីមួយចំនួន គឺករណីនោះវាមានអាចពាក់ព័ន្ធទៅនឹងខ្លឹមសារសំខាន់នូវព្រឹត្តិការណ៍មួយចំនួនដែលពាក់ព័ន្ធប៉ុណ្ណោះ។ ម្សិលមិញគឺភាគីបានជំទាស់ច្បាស់លាស់ណាស់ រវាងការសួរដេញដោលដែលលៀនចេញផុតពីរបៀបវារៈនៃធ្វើសវនាការនៅក្នុងសំណុំរឿង០០២/០២។

[១០:៥៦:៥០]

**លោក ឡោ ជុនធី៖**

បាទ អរគុណលោកប្រធាន។

**សួរដោយលោក ឡោ ជុនធី៖**

**ស៖** ខ្ញុំចូលទៅឯកសារមួយដែលឯកសារ E3/73។ ក្នុងនោះថាមាន លោកមានបានដឹងថា មាន

ការបង្កើតនូវមន្ទីរ ហៅថាមន្ទីរសន្តិសុខនៅព្រៃនប់ទេ។ លោកមានដឹងអត់?

**លោក មាស វឿន៖**

**ឆ៖** បាទ ខ្ញុំគ្រាន់តែឮ។ តែទៅ អត់ដែលបានទៅទេ ប៉ុន្តែគ្រាន់តែឮយុទ្ធជនខ្ញុំនិយាយប្រាប់។

**ស៖** បាទ អរគុណ។ ចំណុចមួយទៀត ថាលោកបានមានការប្រជុំនៅកំពង់ឆ្នាំង ចំនួនពីរដង។ ថាតើការប្រជុំនៅកំពង់ឆ្នាំងពីរដងហ្នឹង លោកមានចាំទេថា មានថ្នាក់ដឹកនាំណាខ្លះដែលចូលរួម? ហើយមានប្រធានបទអី ដែលមានការណែនាំពីថ្នាក់ដឹកនាំទេ?

**ឆ៖** ខ្ញុំសូមជម្រាបថា ខ្ញុំដូចមិនដែលបានទៅដល់ខេត្តកំពង់ឆ្នាំង តែបើខ្ញុំប្រជុំនៅលង្វែក ខ្ញុំធ្លាប់ប្រជុំម្តង។ សូមអស់។

**ស៖** ប្រជុំនៅលង្វែក គឺក្នុងខេត្តកំពង់ឆ្នាំង។ តើមានប្រធានបទអី? ហើយមានមេដឹកនាំណាខ្លះដែលចូលរួម?

[១០:៥៩:០៤]

**ឆ៖** បាទ ប្រជុំនៅលង្វែកមាន កាលនោះមានអ្នកដឹកនាំមាន តាស៊ី មានកងពលខ្ញុំ តាសឿងហ្នឹង ហើយនិង អ៊ំប៉ុល ពត អស់។

**ស៖** បាទ អរគុណ។ នៅក្នុងឯកសារមួយទៀត ឯកសារ E3/80 តើក្នុងនោះពូបានលើកឡើងអំពី ពាក់ព័ន្ធនឹងសំណួរចម្លើយទី១៦ លើកអំពីថាមានសន្និបាតនៅភូមិភាគបស្ចិម ថាតើមានសន្និបាតហ្នឹងដែរអត់ទេ?

**ឆ៖** មានសន្និបាតនៅភូមិបស្ចិម មានម្តងនៅចំការដូង ហៅច្បារមន។ ខ្ញុំចាំកន្លែងហ្នឹងច្បាស់ស្គាល់តែកន្លែងពីរប៉ុណ្ណឹង ចំការដូង ច្បារមន។ សូមអស់។

**ស៖** និយាយចំ តើសន្និបាតហ្នឹងលោកបានចូលរួមពិភាក្សាគ្នាទេ? ហើយតើបើបានចូល តើសន្និបាតហ្នឹងធ្វើរយៈពេលប៉ុន្មានថ្ងៃដែរ?

**ឆ៖** ខ្ញុំចូលរួមធ្វើសន្និបាតហ្នឹង បើតាមខ្ញុំគិតទៅប្រហែលជាមួយអាទិត្យ ឬក៏លើសតិចតួច។ សូមអស់។

**ស៖** បាទអរគុណ។ លោកអាចជម្រាបលម្អិតតិចទេ ថានៅក្នុងសន្និបាតហ្នឹងគេបានលើកនូវប្រធានបទពិភាក្សាអ្វីខ្លះដែរ?

**ឆ៖** ក្នុងការសន្និបាតហ្នឹង គឺនិយាយ គេនិយាយពីការពង្រឹងពង្រីកស្នូលដឹកនាំ ហើយនិង

លទ្ធផលធ្វើស្រែ ធ្វើស្រូវ ហើយនិងផ្នែកការពារប្រទេស។ សូមអស់។

[១១:០២:០៧]

**ប្រធានអង្គជំនុំ៖**

អស់ពេលហើយ សហព្រះរាជអាជ្ញា អ៎!សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។ ពេលវេលាបែងចែកឲ្យអស់ហើយ។

តទៅនេះអង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីមានឱកាសសួរដេញដោលចំពោះសាក្សីរូបនេះ ឬក៏ក្រុមមេធាវីមួយដែលមានបំណងតាំងសំណួរបន្តទៅទៀតនៅចុងវគ្គនៃការស្តាប់សក្ខីកម្មសាក្សីរូបនេះ។ សូមអញ្ជើញ!

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំនឹងចាប់ផ្តើមមុន ហើយប្រសិនបើសហភាតារបស់ខ្ញុំមានសំណួរបន្ថែម ខ្ញុំនឹងទុកពេលឲ្យគាត់។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ជម្រាបសួរលោក មាស វឿន។ ខ្ញុំឈ្មោះ អង់តា ហ្គីសសេ។ ខ្ញុំជាសហមេធាវីអន្តរជាតិការពារក្តីលោក ខៀវ សំផន។ ខ្ញុំនឹងសួរសំណួរបន្ថែមមួយចំនួនចំពោះលោក។ ជាដំបូងខ្ញុំនឹងសួរអំពីរយៈពេលដែលលោកធ្វើការនៅខេត្តកោះកុង គឺចន្លោះពីឆ្នាំ៧៥ ដល់ឆ្នាំ៧៨ កាលពីម្សិលមិញលោកបានបញ្ជាក់ជាច្រើនលើកច្រើនសា ថាក្នុងអំឡុងពេល៣ឆ្នាំនៅកោះកុងនោះ លោកមិនបានចាប់ទាហាន -- លោកមិនបានចាប់ទូកវៀតណាមទេ ហើយទូកតែមួយគាត់ដែលលោកប្រឈមមុខជាមួយហ្នឹងគឺទូកជនភៀសខ្លួន។ តើខ្ញុំយល់អ៊ីចឹងត្រឹមត្រូវទេ?

[១១:០៣:៥៨]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

អញ្ជើញលោកសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

ខ្ញុំមិនច្បាស់អំពីចំណុចនេះទេ គួរតែដកស្រង់ឃ្លាណាមួយនៃចម្លើយរបស់សាក្សី ហើយម៉ោង

ណាដែលសាក្សីគាត់និយាយបែបនេះ។ គាត់បានរៀបរាប់លម្អិតដូចដែលក្នុងឃ្លាដែលខ្ញុំបានអានមុននេះ អ៊ីចឹងពាក់ព័ន្ធទៅនឹងការចាប់ទូកវៀតណាមនោះ។ គាត់ៗបានបញ្ជាក់ថា ជនជាតិវៀតណាមរាប់រយនាក់ត្រូវបានបញ្ជូនទៅកំពង់សោម។ ដូច្នេះសំណួរនេះ ដូចជាមិនត្រឹមត្រូវទេ។

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំមិនទាន់លើកឡើងអំពីពេលដែលបញ្ជូនជនជាតិវៀតណាមទៅកំពង់សោមទេ។ ខ្ញុំចង់និយាយអំពីប្រភេទទូក ឬក៏កប៉ាល់ ដែលសាក្សីគាត់ធ្លាប់ជួបប្រទះ។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ខ្ញុំសូមការបំភ្លឺពីសាក្សី ថាតើលោកសាក្សីខ្ញុំយល់ត្រឹមត្រូវទេថា ក្នុងអំឡុងពេលដែលលោកធ្វើការ៣ឆ្នាំនៅកោះកុងនោះ លោកធ្លាប់ជួបតែកប៉ាល់ ឬក៏កាណូតជនភៀសខ្លួនទេ ខ្ញុំនិយាយអ៊ីចឹងត្រឹមត្រូវទេ?

[១១:០៥:២៩]

**លោក មាស វឿន៖**

**ឆ៖** បាទ កប៉ាល់ អត់មានជួបទេ ជួបតែកាណូតតើ។

**ស៖** សូមលោកឆ្លើយម្តងទៀត យើងអត់បានទទួលការបកប្រែនូវចម្លើយរបស់លោកទេ។

**ឆ៖** លោកមានប្រសាសន៍ថា ជនភៀសខ្លួន ខ្ញុំមានជួបតែកាណូតប្រជាជនវៀតណាមទេ។ កប៉ាល់ គឺខ្ញុំមិនដែលបានជួបកប៉ាល់វៀតណាមទេ ខ្ញុំជួបតែកាណូតតើ។ សូមអស់។

**ស៖** ខ្ញុំសួរលោកថា ក្នុងអំឡុងពេល៣ឆ្នាំហ្នឹង លោកជួបតែកាណូតរបស់ជនភៀសខ្លួនទេ ឬក៏លោកជួបកាណូតរបស់អ្នកនេសាទដែរ?

**ឆ៖** បាទ លោកចង់បញ្ជាក់ខ្ញុំថា គឺកាណូតវៀតណាម ឬក៏កាណូតថៃ ហើយខ្ញុំឆ្លើយអំមិញរួចហើយ ខ្ញុំថាជួបតែកាណូតវៀតណាម តែបើលោកសួរពីកាណូតវៀតណាម ខ្ញុំឆ្លើយពីវៀតណាម។ ដូច្នេះខ្ញុំជួបតែកាណូតរបស់វៀតណាម។

**ប្រធានអង្គជំនុំ៖**

សំណួរសួរអ៊ីចេះថា កាណូតដែលវៀតណាមដែលលោកជួបហ្នឹង តើមានតែកាណូតអ្នកជនភៀសខ្លួនទេ ឬក៏មានទាំងកាណូតជនភៀសខ្លួនផង ហើយមានទាំងកាណូតអ្នកនេសាទវៀតណាមផង?

[១១:០៧:២៨]

**លោក មាស វឿន៖**

**ឆ៖** អត់ៗមាននេសាទ គឺកាណូតតែវៀតណាមដែលប្រុងរត់ទៅក្រៅ។ នេសាទ អត់មានទេ។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** មុននេះសហព្រះរាជអាជ្ញាបានលើកឡើងអំពីកិច្ចសម្ភាសន៍របស់លោកជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា គាត់បាននិយាយអំពីការជួបប្រទះជាមួយនឹងកាណូតជនភៀសខ្លួន។ ដូច្នេះខ្ញុំចង់ដឹងថាលោកចាំទេ ក្រោយពីលោកប្រគល់មនុស្សទៅឲ្យសេនាធិការហើយនោះ តើក្រោយមកនុ៎ង មានការចរចាគ្នា ដើម្បីដោះលែងជនភៀសខ្លួនដែលចាប់បានហ្នឹងទេ?

**ឆ៖** ការដែលៗខ្ញុំបញ្ជូនទៅកន្លែងនេ៎ះ កន្លងកងអគ្គសេនាធិការគេនៅកំពង់សោមហ្នឹង អាហ្នឹងខ្ញុំទៅជូនហើយ គេដោះស្រាយយ៉ាងណា អានោះខ្ញុំអត់បានដឹងទេ រឿងផ្សេងរបស់គេខាងនោះ។ សូមអស់។

**ស៖** នៅក្នុងឯកសារ E3/8752, ERN ជាភាសាអង់គ្លេស 00849511, ERN ជាភាសាខ្មែរ 00733340។ ខ្ញុំសូមដកស្រង់ជាភាសាអង់គ្លេស ដើម្បីរំឭកការចងចាំរបស់លោក។ នេះជាចម្លើយដែលលោកបានឆ្លើយនៅពេលនោះ៖ "ពួកគេបានរត់គេច បន្ទាប់ពីចាញ់វៀតណាមខាងជើង ហើយបានឆ្លងកាត់ផ្លូវរបស់យើងទៅប្រទេសថៃ។ យើងចាប់ខ្លួនពួកគេ ហើយបញ្ជូនទៅកំពង់សោម។ បន្ទាប់មកទៀតមានការចរចាទាក់ទងទៅនឹងការចាប់ខ្លួន។ យើងមិនដឹងថា ពួកគេមកពីទីណាទេ។ សំណួរ៖ អ៊ីចឹងមានបញ្ជូនមកខាងណាដែរ? ចម្លើយ៖ សេនាធិការ។ សំណួរ៖ សេនាធិការនៅឯណា? ចម្លើយ៖ សេនាធិការប្រចាំនៅកំពង់សោម។ គេដោះស្រាយយ៉ាងណាយើងមិនដឹង។ យើងគ្រាន់តែចាប់ហើយបញ្ជូនមក។ គេចរចាហើយលែងស្រេចតែគេទេ។ ការងារបរទេស គេចរចាគ្នាយ៉ាងម៉េច យើងមិនបានដឹងដែរ។" សូមបញ្ចប់ការដកស្រង់។

ដូច្នេះពាក់ព័ន្ធទៅនឹងចម្លើយដែលលោកបានឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជានេះ ខ្ញុំចង់ដឹងថា ទោះបីជាលោកមិនដឹងអំពីអ្វីដែលបានកើតឡើងនៅសេនាធិការក៏ដោយ តើលោកធ្លាប់ឮគេនិយាយអំពីការចរចាគ្នាទេ ក្រោយពីមានការចាប់ខ្លួននៅសមុទ្រហើយនោះ?

[១១:១១:០៣]

**ឆ៖** បាទ ខ្ញុំអត់បានទទួលដំណឹងហ្នឹងផង ហើយក៏មិនបានដឹងអ្វីតទៀតទេ ខ្ញុំខាងខ្ញុំមិនដឹង។

**ស៖** លោកឆ្លើយថា ក្នុងអំឡុងពេល៣ឆ្នាំនៅកោះកុង លោកទទួលបញ្ជាផ្ទាល់ពី តាសឿង។

ហើយពេលដែល តាសឿង មិននៅ លោកទទួលទូរលេខពី សុន សេន។ ដូច្នេះខ្ញុំយល់អ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** បាទ ត្រឹមត្រូវ។

**ស៖** ពេលដែល តាសឿង មិននៅហ្នឹង លោកដឹងទេថា គាត់ប្រហែលជាទៅប្រជុំនៅភ្នំពេញមែនទេ?

**ឆ៖** បាទ គាត់មិនបានប្រាប់ខ្ញុំថា ទៅប្រជុំកន្លែងណា ឬក៏គាត់ទៅកន្លែងណានោះទេ ប៉ុន្តែគាត់ប្រាប់ថា បើសិនជាខ្ញុំមិននៅ គាត់ប្រាប់ថា ឲ្យរាយការណ៍ទៅកន្លែងអគ្គសេនាធិការ មន្ទីរគេនោះទៅ។ គ្រាន់គាត់ប្រាប់តែប៉ុណ្ណឹង។ ឯគាត់ទៅកន្លែងណា គាត់អត់ប្រាប់ទៀតទេ។

**ស៖** លោកថា នៅពេលដែលលោកជួបកាណូតជនភៀសខ្លួន លោកត្រូវចាប់ ហើយបញ្ជូនទៅសេនាធិការ។ អ្នកណាជាអ្នកបញ្ជាឲ្យលោកបញ្ជូនជនភៀសខ្លួនទៅឲ្យសេនាធិការនោះ?

**ឆ៖** បាទ អាហ្នឹងគឺគាត់ប្រាប់ពីដើមមកស្រេច។ បើសិនណាជាចាប់បានយើងរាយការណ៍ឲ្យគាត់ គាត់ប្រាប់ថា ឲ្យបញ្ជូនទៅខាងកំពង់សោមទៅ ខ្ញុំបញ្ជូនទៅតាមហ្នឹង។

**ស៖** គាត់ហ្នឹងៗអ្នកណា? តាសឿង ហ្នឹងមែនទេ?

**ឆ៖** តាសឿង ហ្នឹងឯង។

[១១:១៣:៥០]

**ស៖** អ៊ីចឹងគឺមានន័យថា មេបញ្ជាការកងពលរបស់លោក ជាអ្នកបញ្ជាឲ្យលោក ឲ្យបញ្ជូនជនភៀសខ្លួនវៀតណាមដែលចាប់បានទៅសេនាធិការ អ៊ីចឹងមែនទេ?

**ឆ៖** បាទ អ៊ីចឹងមែន។

**ស៖** គាត់មានប្រាប់ទេថា បញ្ជាហ្នឹងគឺចេញមកពី សុន សេន?

**ឆ៖** គាត់មិនបានប្រាប់ទេ ពីព្រោះអី គាត់ប្រាប់ខ្ញុំហើយ បញ្ជាពីខាងនោះទៀតក៏ខ្ញុំមិនដឹងដែរ បើគាត់ប្រាប់ខ្ញុំតែប៉ុណ្ណឹង។

**ស៖** ពេលដែលលោកឆ្លើយទៅនឹងសំណួររបស់សហព្រះរាជអាជ្ញាអន្តរជាតិលោកថា លោកមិនបានចូលរួមក្នុងកិច្ចប្រជុំនៅភ្នំពេញទេ មុនពេលលោកចាកចេញទៅកោះកុង។ លោកឆ្លើយថា លោកមិនដឹងថា តាសឿង ទៅភ្នំពេញដែរឬក៏អត់ ក្នុងពេលគាត់មិននៅនោះ។ អ៊ីចឹងលោកធ្លាប់ស្តាប់ឮអំពីសន្និបាតមួយដែលគេធ្វើនៅភ្នំពេញ នៅចុងឆ្នាំ៧៧ ហើយនៅក្នុងពេលសន្និបាតនោះ សុន សេន បានចេញបញ្ជា ឬក៏សេចក្តីណែនាំពាក់ព័ន្ធទៅនឹងការចាត់ការចំពោះជនភៀសខ្លួននៅក្នុងដែនទឹកកម្ពុជា។

លោកធ្លាប់ឮគេអំពីនិយាយកិច្ចប្រជុំហ្នឹងទេ?

**ឆ៖** អត់, អត់បានឮទេ។

[១១:១៥:៤៦]

**ស៖** ខ្ញុំនិយាយបែបនេះ ពីព្រោះថានៅក្នុងសំណុំរឿង យើងមានឯកសារមួយ របស់បុគ្គលដែលខ្ញុំមិនអាចបញ្ចេញឈ្មោះបានទេគឺ E319/23.3.12។ នៅក្នុងចម្លើយ៧៥ គាត់បាននិយាយដូចតទៅ គាត់គឺជាបុគ្គលម្នាក់ដែលជាប្រធានកងអនុសេនាធំនៅក្នុងកងពល១៦៤។ គាត់បានឆ្លើយដូចតទៅ៖ “ចុងឆ្នាំ៧៧ ខ្ញុំបានចូលរួមសន្និបាតមួយនៅភ្នំពេញ ដើម្បីបូកសរុបការងាររបស់កងពល១៦៤។ ក្នុងឱកាសនោះខ្ញុំឮ មាស មុត បង្ហាញរបាយការណ៍មួយអំពីកាណូតវៀតណាម ដែលបានរំលោភចូលមកក្នុងដែនទឹកកម្ពុជា។ ពេលនោះ សុន សេន គាត់បានប្រាប់ថា បើជាជនភៀសខ្លួនទៅថៃមិនត្រូវចាប់ខ្លួនទេ បណ្តោយឲ្យពួកគេទៅដល់ថៃទៅចុះ ដោះលែងគេទៅ។” សូមបញ្ចប់ការដកស្រង់។ ដូច្នេះ ខ្ញុំចង់សួរលោកថា លោកមាននឹកឃើញឡើងវិញទេថា មិនមែន តាសឿង ទេអ្នកនិយាយបែបនេះនោះ គឺជាអ្នកណាផ្សេងដែលមានការលើកឡើងអំពីបញ្ហាបែបនេះនោះ?

**ឆ៖** ខ្ញុំអត់បានឮផង។ មិនដែលបានទទួលដំណឹងហ្នឹងផង។

**ស៖** ទោះជាយ៉ាងណាក៏ដោយ តើលោកអាចបញ្ជាក់បានទេថា លោកមិនធ្លាប់ទទួលបញ្ជាពី តាសឿង ឲ្យសម្លាប់ជនភៀសខ្លួនដែលលោកបានជួបនៅលើសមុទ្រទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

អញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

[១១:១៨:១០]

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមជំទាស់ ខ្ញុំមិនយល់អំពីមូលដ្ឋាននៃសំណួរនេះទេ។ គាត់សុំឲ្យសាក្សីបញ្ជាក់អំពីចំណុចនេះ ក៏ប៉ុន្តែមុននេះពេលដែលខ្ញុំអានសម្រង់នូវចម្លើយដែលថា ត្រូវកម្ទេចមនុស្សមួយចំនួននៅលើកាណូតនោះ គាត់ជំទាស់។ អ៊ីចឹងមិនយល់អំពីមូលដ្ឋាននៃការសួរសំណួរនេះទេ មិនដឹងថាតើគាត់ចង់បានចម្លើយបែបណាពីសាក្សី។ ខ្ញុំគិតថា គាត់មិនគួរសួរបែបនេះទេ។

**កញ្ញា អង់តា ហ៊្គីសសេ៖**

មូលដ្ឋាននៃសំណួររបស់ខ្ញុំ គឺថាសំណួរដែលខ្ញុំបានសួរកាលពីប៉ុន្មាននាទីមុននោះ ខ្ញុំបានឲ្យគាត់ឆ្លើយបញ្ជាក់ថា តើនៅពេលដែលមានជនភៀសខ្លួនចាប់បាន គាត់ធ្វើយ៉ាងម៉េច? គាត់ថា គាត់បញ្ជូនទៅសេនាធិការ។ អ៊ីចឹងហើយបានជាខ្ញុំសួរបញ្ជាក់នេះ ថាតើគាត់មានធ្លាប់ទទួលបញ្ជាណាមួយពីថ្នាក់លើថា មានការបញ្ជាឲ្យសម្លាប់ដែរឬទេ នៅពេលដែលជួបជនភៀសខ្លួននៅសមុទ្រនោះ? អ៊ីចឹងតើ តាសឿង នុំងគាត់មានបានចេញសេចក្តីណែនាំឲ្យសម្លាប់ជនភៀសខ្លួន ឬក៏អត់? អ៊ីចឹងខ្ញុំអាចដកពាក្យថាឲ្យសុំគាត់បញ្ជាក់ក៏ដែរ ប្រសិនជាសហព្រះរាជអាជ្ញាមិនពេញចិត្តហ្នឹងពាក្យហ្នឹង។

**សួរដោយកញ្ញា អង់តា ហ៊្គីសសេ៖**

**ស៖** អ៊ីចឹងឥឡូវខ្ញុំសួរគាត់អ៊ីចេះថា លោកសាក្សី តើលោកធ្លាប់ទទួលបញ្ជាពី តាសឿង ឲ្យសម្លាប់ជនជាតិវៀតណាមដែលលោកបានជួបនៅសមុទ្រដែរឬទេ?

[១១:១៩:៤០]

**លោក មាស វឿន៖**

**ឆ៖** គាត់អត់បានឲ្យខ្ញុំសម្លាប់ទេ។ គាត់ថា បើចាប់ជនជាតិវៀតណាម ឬក៏ជនជាតិណាក៏ដោយ គឺត្រូវបញ្ជូនឲ្យ -- រាយការណ៍ឲ្យគាត់ដឹង គាត់នឹងមានវិធានការឲ្យបញ្ជូនទៅតាមថ្នាក់។ គាត់ប្រាប់អ៊ីចឹងរួចស្រេចហើយ បានខ្ញុំចាប់បានហើយ ខ្ញុំបញ្ជូនតាមគាត់ប្រាប់អ៊ីចឹងទៅ។ សូមអស់។

**ស៖** ចំពោះលោកផ្ទាល់ តើលោកធ្លាប់ចេញបញ្ជាទៅឲ្យកូនទាហានទាំងពីរទាំង១.៧០០ របស់លោកហ្នឹង លោកធ្លាប់បញ្ជាឲ្យសម្លាប់ជនភៀសខ្លួនវៀតណាមដែលចូលមកក្នុងដែនទឹកកម្ពុជាទេ?

**ឆ៖** អត់មានផង អត់មានបញ្ជាផង គ្រាន់តែបញ្ជាឲ្យចាប់បាន ហើយបញ្ជូន។ សូមអស់។

**ស៖** ខ្ញុំសួរសំណួរនេះ ព្រោះថាដូចបានសហព្រះរាជអាជ្ញាបញ្ជាក់មុននេះអម្បាញ់មិញអ៊ីចឹង គឺថាមានសាក្សីមួយរូបដែលជាកូនទាហាធម្មតា គាត់បាននិយាយថា គាត់បានទទួលបញ្ជាពីថ្នាក់លើផ្ទាល់របស់គាត់ ឲ្យសម្លាប់ចោលទាំងអស់ ឲ្យតែជាជនជាតិវៀតណាម ដែលពួកគេជួបនៅលើកាណូតដែលមានគ្នាតិចជាង២០នាក់ គឺឲ្យតែជួបវៀតណាមមានគ្នាតិចជាង២០នាក់នៅលើកាណូតគឺត្រូវតែសម្លាប់ចោលទាំងអស់។ អ៊ីចឹងតើ តាសឿង ឬក៏អ្នកណាផ្សេងទៀតនោះ គាត់ធ្លាប់ចេញបញ្ជាបែបហ្នឹងទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

អញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

[១១:២១:៥៣]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។ ខ្ញុំគិតថា ក្នុងសំណួរនេះត្រូវតែបញ្ជាក់ឲ្យបានច្បាស់ថា សាក្សីរូបនោះធ្វើការឲ្យកងពល១៦៤ មិនមែននៅក្នុងកងពលលេខ១ទេ ដើម្បីឲ្យសាក្សី មាស វឿន នេះគាត់ច្បាស់ កុំឲ្យគាត់មានការភ័ន្តច្រឡំ។

**កញ្ញា អង់តា ហ្គីសសេ៖**

មិនបញ្ហាអ្វីទេ ខ្ញុំអាចបញ្ជាក់បាន។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** គឺបុគ្គលរូបនោះគាត់មកពីកងពល១៦៤។ អ៊ីចឹងតើលោកធ្លាប់ឮមេរបស់លោក ឬក៏ថ្នាក់ដឹកនាំកងពលលេខ១ ឬក៏ថ្នាក់ដឹកនាំកងពល១៦៤ ដែលលោកផ្លាស់ប្ដូរព័ត៌មានគ្នាហ្នឹង លោកធ្លាប់ឮអំពីបញ្ជាឲ្យបាញ់ជនស៊ីវិលដែលនៅលើទូក បើសិនបើគ្នាមានតិចជាង២០នាក់ លោកធ្លាប់ឮបញ្ជាបែបហ្នឹងទេ?

**លោក មាស វឿន៖**

**ឆ៖** បាទ ខ្ញុំអត់បានឮផង មិនបានឮហើយក៏មិនបានដឹងដែររឿងសភាពការណ៍ហ្នឹង។ សូមអស់។

**ស៖** ក្នុងពេលទាក់ទងគ្នាតាមតេ.អូ ពីនាវាទៅទីបញ្ជាការនោះ តើលោកមានឆ្លើយឆ្លងគ្នាតាមតេ.អូជាមួយនឹងកងពល១៦៤ ទេ?

[១១:២៣:៤០]

**ឆ៖** ខ្ញុំបានបញ្ជាក់ពីមុនរួចហើយតើ កងពល១៦៤ មកនៅជាមួយគ្នានឹងកោះកុងសម្រាប់ប្រចាំការនៅហ្នឹងស្រេច។ អត់មានបញ្ហាអី រឿងការទាក់ទងអីទៀតទេ យើងត្រូវទៅនិយាយអីនិយាយភ្លាម។ ដូច្នេះមិនចាំនិយាយទៅ តេ.អូទៅឯណាទៀតទេ ពីព្រោះកងហ្នឹងនៅជាប់គ្នារហូត អ៊ីចឹងទៅ។ មានសភាពការណ៍អី យើងនិយាយគ្នាយើងប្រាប់គ្នា យើងសហការណ៍គ្នា ដឹងគ្នា ក៏ប៉ុន្តែឮបញ្ជាថាឲ្យសម្លាប់ជនភៀសខ្លួន ឬឲ្យសម្លាប់អីហ្នឹង អត់មានទេ។ ខ្ញុំសូមមានមតិប៉ុណ្ណេះ។

**ស៖** នៅពេលដែលលោកនិយាយថា មិនចាំបាច់ទាក់ទងគ្នាអីតាមតេ.អូទេ ព្រោះនៅក្បែរគ្នា

ហើយ អ៊ីចឹងមានន័យថាលោកនិយាយគ្នាទល់មុខគ្នាតែម្តង ជាមួយកងពល១៦៤ នៅពេលដែលលោកនៅលើនាវាជាមួយគ្នា ឬក៏នៅលើដីគោកជាមួយគ្នាហ្នឹង។ លោកអាចបញ្ជាក់បានទេ ពេលដែលលោកថានៅក្បែរគ្នាហ្នឹង លោកសំដៅទៅពេលណាដែរ?

**ឆ៖** បាទ អាហ្នឹងខ្ញុំបានប្រាប់ពីមុនរួចហើយ គឺថាកប៉ាល់របស់១៦៤ហ្នឹង មកចតនៅជាមួយនឹងកងខ្ញុំហ្នឹង សម្រាប់ធ្វើកិច្ចសហប្រតិបត្តិការជាមួយគ្នា។ ដូច្នេះបានន័យថា ដូចតែយើងនៅជាមួយគ្នាទៅហើយ។ ដូច្នេះអ្នកនៅជើងគោក ដើម្បីការពារជើងគោក។ អ្នកនៅជើងទឹក ការពារជើងទឹកជាមួយហ្នឹងហើយ។ ដូច្នេះមានបញ្ហាអី យើងនិយាយទាក់ទងគ្នាភ្លាមៗ មិនចាំបាច់ទៅនិយាយ ទៅដល់កំពង់សោមទេ ពីព្រោះបើនិយាយទៅដល់កំពង់សោម អាហ្នឹងវាជារឿងរបស់កង៦៤ហ្នឹង គេនិយាយទៅទីបញ្ជាការគេកំពង់សោមទៀត។ ខ្ញុំអត់មាននិយាយទៅហ្នឹង ខ្ញុំដឹងតែនិយាយនៅជាមួយគ្នា ធ្វើអីៗ យើងនិយាយជាមួយគ្នានៅហ្នឹង ជាប់គ្នាហ្នឹង ព្រោះអីវានៅនឹងកោះជាមួយគ្នាទៅហើយ។ សូមបញ្ជាក់ប៉ុណ្ណេះ។

**ស៖** ដូច្នេះខ្ញុំចង់ដឹងថា ពេលដែលលោកទាក់ទងគ្នាជាមួយនឹងកងពល១៦៤នោះ លោកដឹងថាតើមានបញ្ហាឲ្យសម្លាប់ជនស៊ីវិលនៅក្នុងដែនទឹកដែរឬទេ?

[១១:២៦:២៤]

**ឆ៖** ខ្ញុំអំមិញមិន -- ខ្ញុំបញ្ជាក់អំមិញហើយតើ ថាអត់មានទៅទទួលអាបញ្ជាហ្នឹងទេ។ រឿងថាបាញ់សម្លាប់ជនភៀសខ្លួននៅក្នុងកាណូត ឬនៅក្នុងកប៉ាល់ វាមិនៗមានទេ ពីព្រោះអី ខ្ញុំបានបញ្ជាក់ខាងដើមអំមិញរួចហើយតើ គ្មានទទួលបញ្ជាហ្នឹងពីណា អត់មានទេ។

**ស៖** ក្នុងអំឡុងពីឆ្នាំ៧៥ ដល់ឆ្នាំ៧៨ដែលលោកនៅកោះកុង ខ្ញុំយល់តាមរយៈចម្លើយរបស់លោកកាលពីព្រឹកមិញនេះ លោកថា លោកដឹងតែរឿងហេតុដែលកើតឡើងនៅព្រំដែនសមុទ្រ ហើយនិងនៅក្នុងដែនទឹកតែប៉ុណ្ណោះ។ ដូច្នេះលោកអាចបញ្ជាក់បានទេថា រឿងហេតុដែលកើតឡើងនៅក្នុងភូមិភាគបស្ចិមនុ៎ង គឺថាលោកមិនដឹងទេ។ មែនទេ?

**លោក វាំងសង់ វ៉ាយដ៍ ដេស្ពាឯល៖**

*(គ្មានការបកប្រែ)*

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

អញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក វាំងសង់ វ៉ាយដ៏ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។ ខ្ញុំគិតថា មេធាវីការពារក្តីមិនគួរណាទាញសន្និដ្ឋានបែបហ្នឹងទេ។ គាត់ៗបានថា គាត់បានទៅប្រជុំនៅភូមិភាគបស្ចិម រៀងរាល់បីបួនខែម្តង ហើយក្នុងពេលប្រជុំនោះ គេនិយាយគ្នាអំពីបញ្ហាការពារជាតិ បញ្ហាខ្មាំងផ្ទៃក្នុងជាដើម។ ដូច្នេះមិនគួរសួរកម្រិតត្រឹមតែតំបន់សមុទ្រទេ។

[១១:២៨:០០]

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំរៀបចំសំណួរឡើងវិញ ដើម្បីឲ្យស្របទៅនឹងចម្លើយរបស់សាក្សីកាលពីព្រឹកមិញនេះ។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** លោកសាក្សី កាលពីព្រឹកមិញនេះ ពេលដែលគេសួរលោកអំពីរបាយការណ៍មួយដែលលោកមិនដឹងនោះ លោកថា ចំពោះការប្រព្រឹត្តចំពោះជនជាតិវៀតណាមនោះ លោកមិនអាចនិយាយ -- លោកអាចនិយាយបានតែអំពីអ្វីដែលកើតឡើងនៅកន្លែងដែលលោកធ្វើការតែប៉ុណ្ណោះ គឺនៅកោះកុង។ ដូច្នេះក្នុងពេលប្រជុំ តើលោកមានបានឮព័ត៌មានណាផ្សេងទៀត ពាក់ព័ន្ធទៅនឹងការប្រព្រឹត្តចំពោះជនជាតិវៀតណាមដែរឬទេ?

**លោក មាស វឿន៖**

**ឆ៖** ខ្ញុំអត់បានឮផង ប្រជុំតែរឿងកិច្ចការពារ ហើយនិងធ្វើស្រែ ហើយនិងពង្រឹងការដឹកនាំប៉ុណ្ណឹងឯង ព្រោះការណ៍នេះអត់បានដឹង ដូចគេមិនផ្សាយទេ។ បើៗគេមិនផ្សាយ ក៏ខ្ញុំអត់ដឹងដែរ។ សូមអស់។

**ស៖** កាលពីម្សិលមិញ លោកបាននិយាយអំពីមីងរបស់លោក ដែលគាត់រៀបការជាមួយប្តីវៀតណាម ហើយក្រោយមកគេចាប់ខ្លួន។ ពេលណាដែលលោកដឹងរឿងនេះ? ពេលលោកនៅកោះកុង ឬក៏ពេលបែក បន្ទាប់ពីបែករបបខ្មែរក្រហមហើយទេ?

[១១:២៩:៤៨]

**ឆ៖** ហ្នឹងពេលៗដែលខ្ញុំត្រឡប់ចេញពីកោះកុង ខ្ញុំទៅព្រះវិហារ ខ្ញុំដឹង ព្រោះបានខ្ញុំដើរកាត់ភូមិស្រុកខ្ញុំ គេប្រាប់ខ្ញុំ ខ្ញុំទើបដឹង ខ្ញុំទៅព្រះវិហារឆ្នាំ៧៨ -- ៧៨។

**សះ** ភូមិ ស្រុក ឃុំអីហ្នឹង លោកដឹងទេអ្នកណាជាថ្នាក់ដឹកនាំនៅពេលនុ៎ង?

**ឆះ** ខ្ញុំមិនដឹងអស់ទេ ពីព្រោះអី មិនដឹងថ្នាក់ដឹកនាំគេអស់ទេ ការដឹង មិនដឹងច្បាស់លាស់ថា ខ្ញុំដឹងតែតំបន់៣២, តំបន់៣១ ខ្លះប៉ុណ្ណឹង។ ឯកិច្ចការរៀបចំរដ្ឋបាលខាងក្រោយ ខ្ញុំមិនសូវស្គាល់គេអស់ទេ ខ្ញុំមិនបានចេញចូល។

**សះ** លោកចាំឈ្មោះប្រធានភូមិដែលលោកនិយាយថា មីងរបស់លោកនិងប្ដីរបស់គាត់ត្រូវបានគេចាប់នោះ លោកចាំទេ នៅក្នុងភូមិណា? ហើយប្រធានភូមិហ្នឹងឈ្មោះអីដែរនៅពេលនុ៎ង?

**ឆះ** អត់ស្គាល់ប្រធានភូមិ មិនស្គាល់ប្រធានភូមិ ប៉ុន្តែស្គាល់តែភូមិ។ មីងខ្ញុំឈ្មោះ មីងគុណស្លាប់ហើយមិនដឹង។

**សះ** ពេលដែលលោកទៅដល់ឆ្នាំ៧៨ហ្នឹង ប្រធានភូមិហ្នឹងនៅជាប្រធានភូមិដដែលពីមុន ឬក៏មានការផ្លាស់ប្ដូរ?

**ឆះ** ប្រធានភូមិហ្នឹង មិនដឹងគេជម្លៀសទៅឯណាពីភូមិហ្នឹងបាត់ទៀត។ ទើបផ្លាស់ប្រធានភូមិក្រោយ មិនដឹងប្រធានភូមិអីទេ ខ្ញុំមិនបានចូលសួរសុខទុក្ខទេ ពីព្រោះអីខ្ញុំធ្វើដំណើរ គេដឹកតាមឡានទៅមិនបានចូលស្រុកភូមិទេ ឮតែ ជួបបងប្អូនតាមផ្លូវគេប្រាប់ អ៊ីចឹង។

[១១:៣២:៤៥]

**សះ** ដូច្នេះមានន័យថា លោកមិនបានទទួលព័ត៌មានគ្រប់គ្រាន់អំពីការចាប់ខ្លួនមីង ហើយនិង -- មីងរបស់លោក និងប្ដីរបស់គាត់ទេ មែនទេ?

**ឆះ** អ៊ំដឹង ខ្ញុំដឹងច្បាស់ មិនដឹងច្បាស់ ថាគាត់ស្លាប់ហើយ គេចាប់ ដឹងថាៗគេចាប់បាត់ហើយហ្នឹង។ ហើយប្ដីគាត់ដល់ទៅ ទៅប្ដីគាត់ទៅហាណូយ អ៊្ហឹទៅស្រុកយួន ហើយប្រពន្ធគាត់ត្រូវគេចាប់។ ខ្ញុំដឹងច្បាស់អាហ្នឹង ខ្ញុំដឹងច្បាស់។ តែអ្នកណាចាប់អី អ្នកណាចាប់ ខ្ញុំមិនដឹងដែរ ប៉ុន្តែដឹងច្បាស់ថាគេចាប់ហើយ។

**សះ** អ៊ីចឹងមានន័យថា ប្ដីគាត់ត្រឡប់ទៅវៀតណាមវិញ មែនទេ?

**ឆះ** បាទ ប្ដីទៅវៀតណាមវិញ។

**សះ** លោកដឹងថា គាត់ទៅវៀតណាមវិញហ្នឹងឆ្នាំណា? ពេលដែលលោកទៅដល់ភូមិហ្នឹងវិញហ្នឹង គេប្រាប់លោកថា ប្ដីគាត់ទៅបាត់ហើយ ឬក៏ក្រោយមកទេ?

**ឆះ** ប្ដីគាត់ទៅហើយ ទៅបាត់ហើយ ពីព្រោះអី គាត់ទៅតាំងពី បើគេប្រាប់ខ្ញុំថា គាត់ទៅតាំងពី

ឆ្នាំ៧០នោះ ពេលដែលឃួនចូលជួយរំដោះខ្មែរហ្នឹង ហើយគាត់ទៅតាំងពីឆ្នាំ៧០ ហើយនៅប្រពន្ធ។ នៅប្រពន្ធ ក្រោយមកគេចាប់ប្រពន្ធហ្នឹងបាត់ទៀតទៅ។ នៅកូនមួយ ដល់ក្រោយមកទៀត ដឹងម៉េចកូនមួយហ្នឹង ក៏វៀតណាមយកទៅតាមដែលគេឱ្យឃួនចេញទៅស្រុកវិញហ្នឹង ធ្វើដំណើរការទៅស្រុកវិញហ្នឹង ក៏ទៅតាមវៀតណាមហ្នឹងបាត់ទៀតអស់ទៅ។ អង្កាល់នោះគេឱ្យវៀតណាមទៅស្រុកនោះ ឆ្នាំ៧០។ អាហ្នឹងដែលតាមគាត់ប្រាប់អ៊ីចឹង។

[១១:៣៥:១១]

**ស៖** អ៊ីចឹងមានន័យថា ប្ដីគាត់ទៅវៀតណាមនៅឆ្នាំ៧០។ លោកប្រធានជាសំណួរចុងក្រោយ ខ្ញុំគិតថា វាអស់ម៉ោងហើយ។ មីងរបស់លោកត្រូវបានចាប់ខ្លួននៅក្នុងចន្លោះឆ្នាំ៧៥ ដល់ឆ្នាំ៧៩ មែនទេ? អ៊ីចឹងខ្ញុំសួរឡើងវិញគឺថា មីងរបស់លោកហ្នឹងគឺត្រូវបានចាប់ខ្លួនចន្លោះពី៧៥ ដល់៧៨ មែនទេ?

**ឆ៖** បាទ ចាប់ពីឆ្នាំ មើលឆ្នាំ៧០ៗ ចុងឆ្នាំ៧០ – ៧០, ៧១, ៧២។ ហ្នឹងហើយគេចាប់ពីជំនាន់នុ៎ង គឺក្រោយពីឆ្នាំ៧០ ប្រហែលជា៧៣ តាមមើល ដែលគេប្រាប់ខ្ញុំហ្នឹង។ ខ្ញុំមិនបានទាន់ដឹងគាត់ច្បាស់ទេ តែគេប្រាប់ខ្ញុំថា ចាប់ពីឆ្នាំ៧០ហ្នឹង។

**ស៖** អ៊ីចឹងដើម្បីឱ្យច្បាស់ទាំងអស់គ្នា គឺថាពេលដែលលោកនិយាយអំពីការចាប់ខ្លួនមីងរបស់លោក គឺមុនពេលខ្មែរក្រហមវាយបែកភ្នំពេញមែនទេ?

**ឆ៖** ទេ វាយបែកភ្នំពេញហើយ។ មើលទំនងវាយបែកភ្នំពេញហើយ បានបាត់គាត់ហ្នឹង។ វាយបែកភ្នំពេញហើយ បានបាត់គាត់ហ្នឹង។

**កញ្ញា អង់តា ហ្គីសសេះ**

លោកប្រធាន ដោយសារតែអស់ពេល អ៊ីចឹងខ្ញុំសូមបញ្ចប់ត្រឹមនេះ លោកប្រធាន។

[១១:៣៧:២០]

**ប្រធានអង្គជំនុំះ**

បាទ ហើយសវនាការនៅថ្ងៃនេះ ដល់ពេល -- អង្គជំនុំជម្រះអរគុណលោក មាស រឿន។ ការស្ដាប់សក្ខីកម្មរបស់លោកក្នុងឋានៈជាសាក្សីដល់ពេលនេះ បានចប់ហើយ។ ហើយសក្ខីកម្មរបស់លោកនឹងអាចរួមវិភាគទានក្នុងការស្វែងរកការពិតក្នុងរឿងក្ដីនេះ។ ឥឡូវនេះវត្តមានរបស់លោកនៅ អ.វ.ត.ក នេះ លែងមានភាពចាំបាច់ទៀតហើយ លោកអាចវិលត្រឡប់ទៅកាន់លំនៅដ្ឋាន ឬក៏គោលដៅណាដែលលោកមានបំណងចង់ទៅបានហើយ។ ហើយសូមលោកមានសុខភាពល្អ ជួបតែសំណាងល្អ បានសេចក្ដី

សុខ សេចក្តីចម្រើន។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនលោក មាស វឿន វិលត្រឡប់ទៅកាន់លំនៅដ្ឋានរបស់គាត់ ឬក៏គោលដៅណាដែលគាត់មានបំណងចង់ទៅបានហើយ។ អង្គជំនុំជម្រះក៏សូមអរគុណលោកស្រីមេធាវី សុក សុជាតា មេធាវីប្រឹក្សាសាក្សី ឥឡូវនេះលោកស្រីអាចសម្រាកបានហើយ។

ហើយសវនាការនៅរសៀលនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សក្ខីកម្មសាក្សី អ៊ិន យឿង ហើយឥឡូវនេះដល់ពេលសម្រាកហើយ។ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយកន្លះរសៀលនេះ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

ហើយនិងបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ លោក ខៀវ សំផន ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការនេះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញនៅរសៀលនេះ ឲ្យបានមុនម៉ោងមួយកន្លះ។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១១:៣៨ នាទី ដល់ម៉ោង ១៣:៣២ នាទី)*

[១៣:៣២:៤៧]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនការ ហើយសវនាការនៅរសៀលនេះ អង្គជំនុំជម្រះធ្វើសវនាការបន្តស្តាប់សក្ខីកម្មសាក្សី អ៊ិន យឿង។ ហើយអង្គជំនុំជម្រះក៏សូមជម្រាបជូនភាគី និងសាធារណជនដែរ នៅពេលនេះ គឺតាមសំណើសុំរបស់សាក្សីរូបនេះ អង្គជំនុំជម្រះអនុញ្ញាតឲ្យមានវត្តមានលោកស្រី ឆាយ ម៉ារីដែត ដែលជាបុគ្គលិកអង្គការ ធី.ភី.អូ អង្គុយអមជាមួយនឹងសាក្សី ដោយសារបញ្ហាសាក្សី គាត់មានបញ្ហាសុខភាពផង ហើយគាត់មានបញ្ហាភ័យខ្លាចផង។

អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមតំណាងសហព្រះរាជអាជ្ញា ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

**លោក ស្រ៊ា រតនៈ៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម និងសូមជម្រាបសួរភាគី។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរបន្តដោយលោក ស្រ៊ា រតនៈ៖**

**ស៖** សូមជម្រាបសួរម្តងទៀតលោកស្រីសាក្សី។ ពីថ្ងៃសវនាការលើកមុននោះ ខ្ញុំបានជម្រាបសួរលោកស្រីនូវសំណួរមួយចំនួនតូចហើយ។ ឥឡូវថ្ងៃនេះ ខ្ញុំសូមបន្តនូវសំណួរនេះមួយចំនួនទៀត។ ជាបឋមនេះ ខ្ញុំសូមសួរបញ្ជាក់លោកស្រីឡើងវិញ ទៅលើអាយុលោកស្រី តើលោកស្រីមានអាយុប៉ុន្មានឆ្នាំហ្នឹង ឆ្នាំនេះ?

[១៣:៣៤:២៧]

**លោកស្រី អ៊ុន យឿង៖**

**ឆ៖** ៥៦ឆ្នាំ។

**ស៖** បើតាមខ្ញុំចាំកាលពីសប្តាហ៍ កាលពីសវនាការលើកមុន លោកស្រីបានឆ្លើយជម្រាបទៅអង្គជំនុំជម្រះថា លោកស្រីថាលោកស្រីមានអាយុ៦៥ឆ្នាំ។ បើអ៊ីចឹង តើលោកស្រីមានអាយុប៉ុន្មានឲ្យប្រាកដមកដល់ថ្ងៃនេះ?

**ឆ៖** អាយុឲ្យប្រាកដហ្នឹងតែ៥៥ឆ្នាំទេ មិនមែន៦០ទេ។ អ៎! ៥៦ ច្រឡំ៥៥ ច្រឡំអ៊ីចឹង។

**ស៖** អ៊ីចឹងអ៊ីចេះវិញ ចង់ៗសួរ ខ្ញុំសួរមួយបែបផ្សេងទៀតវិញ លោកស្រីអាចឆ្លើយបានទេថា លោកស្រីកើតនៅឆ្នាំណា?

**ឆ៖** ខ្ញុំអត់បានចាំទេ ម្តាយខ្ញុំស្លាប់ហើយ អត់មានបានប្រាប់ផង។

**ស៖** បើអ៊ីចឹង ខ្ញុំសួរលោកស្រីមួយបែបទៀត លោកស្រីនៅចាំបានព្រឹត្តិការណ៍ថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ ទេ?

**ឆ៖** អត់បានចាំទេគ្រូ។

[១៣:៣៦:៥៤]

**ស៖** ចុះលោកស្រីដឹងៗថា ខ្ញុំប្រើពាក្យសាមញ្ញដូចដែលប្រជាជនទូទៅប្រើ បែកភ្នំពេញៗនៅឆ្នាំណា? ដឹងទេ?

**ឆ៖** បែកភ្នំពេញនៅក្នុងឆ្នាំ៧៥។

**ស៖** អ៊ីចឹងខ្ញុំយកឆ្នាំ៧៥ជាគោល ដោយសារលោកស្រីចាំបាន។ តើនៅកាលពីឆ្នាំ៧៥ហ្នឹង លោកស្រីមានអាយុប៉ុន្មាន?

**ឆ៖** ដឹងអាយុប៉ុន្មានទេ ចៅក្រម ខ្ញុំមិនបានគិតអារឿងអាយុ រឿងអីទេ វាជាប់ការងារអ៊ីចឹង ខ្ញុំមិនដឹងបានគិតអាយុទេ។

**ស៖** ចុះកាលហ្នឹងលោកស្រីនៅក្នុង -- ខ្ញុំចាំបានថាលោកស្រីបាន ត្រូវបានគេចាត់តាំងឲ្យធ្វើការងារច្រើនកន្លែងដែរ។ លោកស្រីពេលហ្នឹងស្ថិតនៅក្នុងកងកុមារ ឬកងយុវជន?

**ឆ៖** នៅក្នុងកងចល័តតែម្តង គេៗឲ្យធ្វើការខាងកម្លាំងពេញ គេថាអ៊ីចឹង។

**ស៖** បើៗអ៊ីចឹងលោកស្រីអត់ចាំឆ្នាំ អត់ចាំអាយុ អ៊ីចឹងប្រហែលៗមើលលោកស្រីអាយុ១០ជាង ឬ២០ជាង?

**ឆ៖** អាយុ១៥ឆ្នាំហើយអង្កាល់ខ្ញុំធ្វើកម្លាំងពេញហ្នឹង។

**ស៖** ឥឡូវខ្ញុំយកចំណុច១៩៧៥ហ្នឹងដដែល ខ្ញុំចង់ដឹងថា តើនៅ១៩៧៥ ដែលខ្ញុំសួរលោកស្រីមុនហ្នឹង គឺសំដៅទៅលើថ្ងៃដែលភ្នំពេញបែក បានន័យថា ហើយមួយជំហានទៀតគឺថ្ងៃដែលរបបកម្ពុជាប្រជាធិបតេយ្យចាប់ផ្តើម។ អ៊ីចឹងនៅៗពេលហ្នឹង តើនៅក្នុងភូមិ ឃុំ ដែលលោកស្រីរស់នៅហ្នឹងមានជនជាតិវៀតណាមរស់នៅទេ?

[១៣:៤០:០២]

**ឆ៖** អត់មានទេ។

**ស៖** ចុះបើនៅភូមិឃុំដែលលោកស្រីរស់នៅ អត់មាន លោកស្រីដែលឃើញមានជនជាតិវៀត-ណាមទេ នៅបន្ទាប់ពីថ្ងៃបែកភ្នំពេញហើយ?

**ឆ៖** បែកភ្នំពេញហើយហ្នឹងអត់មានឃើញដែរ ខ្ញុំ។

**ស៖** ចុះមុនពេលបែកភ្នំពេញ លោកស្រីដែលឃើញមានជនជាតិវៀតណាមទេ ទាំងនៅក្នុងភូមិ ឬក៏នៅតំបន់ ដែលលោកស្រីធ្លាប់ស្នាក់នៅ?

**ឆ៖** ទាល់តែខ្ញុំទៅនៅកងចល័ត ឃើញវៀតណាមនៅព្រំដែន ឃើញមែន តែនៅតាមភូមិមិនបានមានឃើញទេ។

**ស៖** កងចល័តដែលលោកស្រីមានប្រសាសន៍ហ្នឹងនៅកន្លែងណា ហើយ នៅកន្លែងណា?

**ឆ៖** ខ្ញុំនៅកន្លែង នៅៗកន្លែងដូង នៅទល់ព្រំដែនយួនហ្នឹង។ ឃើញគេដើរម្ខាង ខ្ញុំនៅកងចល័ត

ហ្នឹងក៏នៅម្ខាងដែរ អត់មានច្រឡូកច្រឡាសគ្នាទេ។ ហើយកងចល័តហ្នឹងក៏ខ្លាចដែរ ខ្លាចយួនហ្នឹងដែរ។

**ស៖** លោកស្រីៗបញ្ជាក់កន្លែងនេះឲ្យច្បាស់បន្តិច ខ្ញុំស្តាប់ដូចជាមិនសូវយល់ លោកស្រីថា ឃើញម្ខាងហ្នឹង បានន័យថា ឃើញវៀតណាមនៅដីវៀតណាម យើងនៅដីយើង។ ខ្ញុំយល់អ៊ីចឹងត្រូវទេ?

**ឆ៖** នៅម្ខាងម្នាក់ ខ្ញុំនៅខាងហ្នឹង វៀតណាមនៅខាងដីគាត់ហ្នឹងទៅ ខ្មែរនៅដីខ្មែរធ្វើការៗខាងប្រព័ន្ធភ្លឺស្រែ ខាងហ្នឹងម្ខាងទៅ។ អត់មានចេញចូលទេ បើចេញចូលក៏យើងមិនហ៊ានដែរ ខ្លាចរត់ចេញដែរ។

[១៣:៤៣:០៨]

**ស៖** អ៊ីចឹងដោយសារបែបនេះ ដោយសារលោកស្រីឆ្លើយថា ឃើញជនជាតិវៀតណាមនៅម្ខាង ឥឡូវខ្ញុំសូមកំណត់ ហើយសូមពន្យល់លោកស្រីថា អ្វីដែលខ្ញុំសួរអំពីជនជាតិវៀតណាម គឺជនជាតិវៀតណាមដែលនៅក្នុងដីខ្មែរយើង ដែលៗនៅក្នុងដីខ្មែរយើង។ ដូច្នេះលោកស្រីកុំឆ្លើយអំពីជនជាតិវៀតណាមដែលនៅដីគាត់ អាហ្នឹង ខ្ញុំអត់ចង់ដឹងរឿងហ្នឹងទេ។ ខ្ញុំសួរលោកស្រីកន្លែងនេះមួយសាទៀត គឺបើនៅក្នុងទឹកដីខ្មែរតែម្តង លោកស្រីធ្លាប់បានឃើញជនជាតិវៀតណាមទេ ចាប់ពី -- ខ្ញុំសួរជាក់លាក់មួយសាទៀត ជនជាតិ -- លោកស្រីធ្លាប់ឃើញជនជាតិវៀតណាមនៅក្នុងកន្លែងលោកស្រីរស់នៅទេ ចាប់បន្ទាប់ពីបែកភ្នំពេញហើយ?

**ឆ៖** ចំពោះខ្ញុំបានឃើញមែន ទទេ។

**ស៖** ដើម្បីជាជំនួយដល់ការចងចាំរបស់លោកស្រី ខ្ញុំសូមលើកយកចម្លើយរបស់លោកស្រីដែលបានឆ្លើយជាមួយនឹងខាងមជ្ឈមណ្ឌលឯកសារកម្ពុជាកាលពីឆ្នាំ២០០៥ គឺនៅក្នុងឯកសារ E3/7525 ត្រង់ ERN ជាភាសាខ្មែរ 00089629, ជាភាសាបារាំង 00903085, 00885515។ ពេលនោះអ្នកសម្ភាសសួរលោកស្រីថា សូមដកស្រង់៖ “នៅភូមិមានជនជាតិយួនប៉ុន្មាននាក់ដែលគេយកទៅ បងមានចាំទេ? (អ្នកជិតខាងៗ ដែលគេដាក់អ្នកជិតខាងនៅពេលហ្នឹង គឺលោកស្រីដែលបានឆ្លើយ)៖ “ទេ មិនដឹងទេ ខ្ញុំមិនដឹង ខ្ញុំនៅតែភូមិខ្ញុំហ្នឹងណ៎ា ហើយភូមិខ្ញុំផ្លាស់មកពីកំពង់ត្រាចយកទៅ គេផ្លាស់មកកំពង់ត្រាចយកទៅ។ អូ៎ សួរបន្តទៀត៖ ផ្លាស់ពីកំពង់ត្រាចទេ? លោកស្រីឆ្លើយបន្តទៀត៖ ចាស ផ្លាស់ពីកំពង់ត្រាចយកទៅ។ គេសួរបន្តទៀត៖ ឃើញយួនប៉ុន្មានគ្រួសារដែរ ដែលគេយកទៅ? មឹងបានឆ្លើយ លោកស្រីបានឆ្លើយទៀតថា៖ កាលហ្នឹងប៉ុន្មានទេ មឹងអឺ ប៉ុន្មានបួនគ្រួសារ គេផ្លាស់ខ្ញុំយកទៅ។” អ៊ីចឹងកន្លែងនេះលោកស្រីបានចាំទេថា កាលនុ៎ង លោកស្រីបានឆ្លើយថា មានជនជាតិវៀតណាមប្រមាណៗគ្រួ -- បួន

គ្រួសារដែលៗលោកស្រីឃើញ ហើយត្រូវបានគេផ្លាស់មកពីឃុំកំពង់ត្រាច?

[១៣:៤៦:៣៦]

**ឆ៖** ខ្ញុំភ្លេចអស់ហើយអ៊ីចុង យូរពេកហើយ។

**ស៖** ខ្ញុំសូមជម្រាបសួរលោកស្រីបន្តទៀត ចុះលោកស្រីស្គាល់ព្រៃចកទេ នៅស្គាល់ព្រៃចកទេ?

**ឆ៖** ស្គាល់ ព្រៃចក។

**ស៖** ព្រៃៗចក ព្រៃចកហ្នឹង ស្ថិតនៅកន្លែងណាដែរ?

**ឆ៖** ព្រៃចកហ្នឹង ស្ថិតនៅខាងថ្បូង ខាងលិចភូមិស្រះ។

**ស៖** ឃុំអី ស្រុកអី?

**ឆ៖** ឃុំជ្រៃ ព្រៃចកហ្នឹង ឃុំជ្រៃ បើនិយាយភូមិ ភូមិលិចភូមិស្រះ។

**ស៖** ស្រុកអីដែរ?

**ឆ៖** ស្រុក គេហៅឃុំជ្រៃតែម្ដង ភូមិ បើៗព្រៃចក គេហៅខាងលិចស្រះ ខាងលិចគេហៅស្រុកខាងរំលេចស្រះ គេថាអ៊ីចឹងអ្នកស តែបើៗភូមិ បើឃុំ ឃុំជ្រៃ។

**ស៖** បើប្រៀបធៀបជាមួយនឹងកន្លែងដែលលោកស្រីរស់នៅកាលនុ៎ង នៅចម្ងាយប៉ុន្មាន ឬស្ថិតមានទីតាំងស្ថិតនៅកន្លែងឆ្ងាយប៉ុន្មាន ពីកន្លែងដែលលោកស្រីរស់នៅ?

**ឆ៖** រស់កន្លែងៗព្រៃចកនុ៎ង ហើយកន្លែងខ្ញុំរស់នៅហ្នឹង ចម្ងាយប្រហែលពី៥គីឡូ ប៉ុណ្ណឹង។

**ស៖** ខ្ញុំសូមសួរៗឲ្យៗកាន់តែច្បាស់មែនទែន។ កន្លែងរស់នៅហ្នឹង គឺៗសំដៅទៅលើកន្លែងដែលលោកស្រីរស់នៅមុនឆ្នាំ៧៥ហ្នឹង បានន័យថា មុនពេលដែលលោកស្រីចល័ត។ អ៊ីចឹងតើមានចម្ងាយម៉ានចម្ងាយប៉ុន្មានព្រៃចកពីកន្លែងដែលលោកស្រីរស់នៅ មុនពេលភ្នំពេញបែក?

[១៣:៤៩:៣៩]

**ឆ៖** ចម្ងាយដែលព្រៃចកៗចម្ងាយមកផ្ទះខ្ញុំហ្នឹង ចម្ងាយប្រហែល ៥គីឡូៗដី។

**ស៖** តើនៅៗស្ថិតនៅក្នុងភូមិសាស្ត្រស្រុក និងខេត្តតែមួយនៃភូមិឃុំដែលលោកស្រីរស់នៅ ឬក៏នៅកន្លែងផ្សេង ឬក៏នៅស្រុកផ្សេង ខេត្តផ្សេង?

**ឆ៖** នៅខេត្តផ្សេង មួយខេត្តឃុំជ្រៃ មួយខេត្តកំពង់ត្រាច។ ខេត្ត -- អូ៎! ខ្ញុំច្រឡំៗ។

**ស៖** នៅក្នុងស្រុករមាសហែក ខេត្តស្វាយរៀងដូចដែលកំពង់ត្រាចលោកស្រីដែរ ឬក៏នៅស្រុកផ្សេង ខេត្តផ្សេង?

**ឆ៖** នៅស្រុកតែមួយដែរ នៅស្រុកគេហៅ ឃុំជ្រៃនុំង ហើយខ្ញុំ -- អើប៉ុន្តែខេត្ត វាខេត្តតែមួយទេ ខេត្តស្វាយរៀងដូចតែគ្នា ប៉ុន្តែវានៅក្នុងឃុំជ្រៃ ហើយបើខេត្ត ខេត្តស្វាយរៀងដូចតែគ្នា។

**ស៖** ចុះព្រៃចកហ្នឹង មានទំនាក់ទំនងអីជាមួយនឹងជនជាតិវៀតណាម? បើលោកស្រី បើគេនិយាយដល់ព្រៃចក និយាយពីជនជាតិវៀតណាម តើមានអីទាក់ទងគ្នា?

**ឆ៖** ដឹងមានអីទាក់ទងទេ ខ្ញុំវាភ្លេចអស់ហើយ មិនដឹងមានអីទាក់ទងជាមួយគ្នាទេ ខ្ញុំក៏ដឹងថាព្រៃចកៗទៅ ប៉ុន្តែថាឲ្យមានទាក់ទងជាមួយវៀតណាមនោះ ខ្ញុំវាភ្លេចអស់ហើយ។ មិនបានច្របូកច្របល់ វាមិនបានដឹងច្បាស់លាស់ទេ។

**ស៖** ដើម្បីរំឭកការចងចាំរបស់លោកស្រី ខ្ញុំសូមដកស្រង់នូវចម្លើយដែលលោកស្រីបានឆ្លើយ គឺនៅក្នុងឯកសារពីមុនហ្នឹង E3/7525 ដែលមានERNជាភាសាខ្មែរ 00089627, ជាភាសាបារាំង 00903083 និងភាសាអង់គ្លេស 00885013។ កាលនោះអ្នកសម្ភាសបានសួរលោកស្រីថា ឬក៏មានវៀតណាម គ្រួសារវៀតណាមរស់នៅភូមិហ្នឹងពីមុនមកទេ? សម័យខ្មែរក្រហមណា?

[១៣:៥២:៤០]

**ប្រធានអង្គជំនុំ៖**

អញ្ជើញសហមេធាវីអន្តរជាតិការពារក្តីលោក ខៀវ សំផន!

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន តាមរយៈភាសាបារាំងនោះ យើងមិនទទួលបានលេខERNទេ លោកសហព្រះរាជអាជ្ញាសូមបញ្ជាក់ម្តងទៀត។

**សួរដោយលោក ស្រ៊ា រតនះ៖**

**ស៖** ERN ជាភាសាបារាំងគឺ 00903083។ ខ្ញុំសូមបន្តការដកស្រង់ លោកស្រីបានឆ្លើយថា៖ “មិនដែលមានរស់នៅទេ។ ទោះបីបើមាន ទោះបើមាន គេយកចោលព្រៃចកអស់ បើមានចោលព្រៃចកអស់ ព្រៃចកហ្នុង។” អ៊ីចឹងតាមដែលខ្ញុំលើកឡើងប៉ុណ្ណោះ តើលោកស្រីអាចរំឭកការចងចាំបានខ្លះទេ ថាតើមានអីកើតឡើងចំពោះជនជាតិវៀតណាមនៅឯព្រៃចក?

**លោក អ៊ុន យឿង៖**

**ឆ៖** ខ្ញុំភ្លេចហើយហ្នឹង យូរពេក។ ខ្ញុំភ្លេចហើយលោកពូចៅក្រម ខ្ញុំវាមិនបានចងចាំវិញសោះ។ ព្រៃចកៗ ឃើញតែគេទៅបាត់ៗ ទៅមែន តែវាមិនដឹង វាអត់មានការចងចាំ ភ្លេចបាត់ហើយ យូរពេក។

**ស៖** លោកស្រីមានប្រសាសន៍មុននឹងថា ដឹងតែគេទៅបាត់ៗ តើគេហ្នឹងអ្នកណាគេ? ជាអ្នកណា?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

អញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

[១៣:៥៤:៤៣]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ដើម្បីបញ្ជាក់ឲ្យបានច្បាស់ ឯកសារដែលជាកំណត់ហេតុស្តាប់ចម្លើយជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា គឺជាការសម្ភាសជាមួយបុគ្គលផ្សេងទេ។ មិនមែនជាការសម្ភាសជាមួយបុគ្គលម្នាក់ឈ្មោះ អៀង ហុង នោះទេ។ គឺថា ជាអ្នកជិតខាងទេ ដែលគាត់មកឆ្លើយនៅពេលចុងក្រោយនុ៎ង។ ប៉ុន្តែដោយពិចារណាទៅលើចម្លើយរបស់គាត់ពាក់ព័ន្ធទៅនឹងអ្វីដែល អ៊ិន យ៉ុង បានផ្តល់សក្ខីកម្ម ខ្ញុំមិនប្រាកដ១០០ភាគរយទេ ថាតើយើងកំពុងតែនិយាយពីមនុស្សតែមួយ ឬក៏មនុស្សផ្សេងគ្នាឡើយ។ ខ្ញុំមិនដឹងថាឈ្មោះ អ៊ិន យឿង ហ្នឹងជាមនុស្ស ជាឈ្មោះទូទៅ ឬក៏ជាឈ្មោះដែលមានលក្ខណៈពិសេសនោះទេ។ ដូច្នេះហើយខ្ញុំគិតថា ថាតើយើងទទួលបានចម្លើយដូចគ្នា ឬក៏ឆ្លើយខុសគ្នានៅក្នុងផ្នែកខាងក្រោយនៃកំណត់ហេតុស្តាប់ចម្លើយនោះ។

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

លោកប្រធាន ខ្ញុំគិតថា ដូចជាមិនមានភាពស្រពេចស្រពិលអីទេ ពីព្រោះថាអ្នកជិតខាងហ្នឹងគាត់អន្តរាគមន៍នៅពេលដែលសាក្សីបានផ្តល់ចម្លើយទៅមជ្ឈមណ្ឌលឯកសារកម្ពុជា។ អ៊ីចឹងអ្នកចុង -- ខាងចុងក្រោយអ្នកជិតខាងហ្នឹង គេដាក់ថាឈ្មោះ អ៊ិន យឿង។ ហើយនៅពេលដែលសួរថា តើប្តីគាត់ឈ្មោះអី? គាត់ឆ្លើយថាឈ្មោះ ចាន់ គា។ អ៊ីចឹង ចាន់ គា ហ្នឹងហើយជាមនុស្សដែលត្រូវបានមជ្ឈមណ្ឌលឯកសារកម្ពុជាសម្ភាសនោះ។ ដូច្នេះខ្ញុំគិតថា ដូចជាយើងមើលទៅដូចជាមិនមានភាពស្រពេចស្រពិលអីទៀតទេ។ ឥឡូវនេះ ខ្ញុំចូលមកនិយាយអំពីខ្លឹមសារនៃចម្លើយដែលវាមិនស៊ីសង្វាក់គ្នានោះ--

[១៣:៥៧:០២]

**ប្រធានអង្គជំនុំ៖**

សហមេធាវី -- សហព្រះរាជអាជ្ញា គប្បីបញ្ជាក់បញ្ហាហ្នឹងមើល៍ តើវាជាការសន្មតរបស់លោក

ផ្អែកលើឯកសារ ឬក៏វាជាចម្លើយផ្ទាល់មាត់ពីសាក្សី ពីសាក្សីដែលបញ្ហាលើបញ្ហានេះ រវាងអ្នកជិតខាង ហើយនិងអ្នកផ្តល់សក្ខីកម្មនៅក្នុងប្រតិចារឹកនេះ។ សំណួរកន្លងមកនេះ មិនទាន់បានសួរបញ្ជាក់លើចំណុចនេះឲ្យបានច្បាស់លាស់នៅឡើយទេ។

**លោក ស្រ៊ា រតនះ៖**

សូមជម្រាបលោកប្រធាន។ តាមរយៈឯកសារ E3/75/25 នេះគឺមានថា “អ្នកជិតខាង” ហើយសម្ភាសជាមួយនឹង តួអង្គដែលសម្ភាសនោះ គឺឈ្មោះ ចាន់ គា។ ប៉ុន្តែតាមរយៈខ្លឹមសារចុងក្រោយនៅខ្លឹមសារនៅ អ្នកសម្ភាសដែលសួរចុងក្រោយ គឺនៅទំព័រជាភាសាខ្មែរទំព័រលេខ៤៦ ហើយជាភាសាបារាំងមាន ERN 00903087, ជាភាសាអង់គ្លេស 00885016ហ្នឹង អ្នកសម្ភាសសួរថា គាត់ឈ្មោះអី? គាត់ឆ្លើយថា៖ ឈ្មោះ អ៊ិន យឿង។ ហើយអ្នកសម្ភាសឈ្មោះ ចាន់ គា។ កាលពីសវនាការលើកមុន ខ្ញុំបានសួរបញ្ជាក់គាត់ថា ប្តីគាត់ឈ្មោះអី គាត់ថាប្តីគាត់ឈ្មោះ ចាន់ គា។ តាមរយៈចំណុចពីរនេះ ទើបខ្ញុំច្បាស់ថា អ្នកជិតខាងដែល -- ព្រោះពីដំបូងៗអ្នកសម្ភាសអត់ដឹង ឃើញគាត់នៅហ្នឹងអត់ដឹងគាត់ហ្នឹងថាប្រពន្ធទេ ហើយអត់ដឹងឈ្មោះអីទេ។ គាត់ចេះតែលូកមាត់ឆ្លើយឆ្លង។ អាហ្នឹងតាមរយៈការអានកិច្ចសម្ភាសន៍ហ្នឹងឃើញថាអ៊ីចឹង។ អ៊ីចឹងទីបំផុត អ្នកជិតខាងសួរឈ្មោះគាត់ បានដឹងថាគាត់ឈ្មោះ អ៊ិន យឿង។ ហើយតាមខ្លឹមសារនៃអត្ថន័យហ្នឹង គឺគាត់ឆ្លើយថា អ៊ិន យឿង ហ្នឹង ហើយប្តីគាត់ឈ្មោះ ចាន់ គា អ៊ីចឹងគឺគាត់ហ្នឹងឯង។ ព្រោះខ្ញុំសួរបញ្ជាក់គាត់ថា ប្តីគាត់ឈ្មោះ ចាន់ គា។

[១៣:៥៩:០៥]

**ប្រធានអង្គជំនុំ៖**

យើងចង់ប្រាប់លោកថា តើលោកសន្និដ្ឋានដោយខ្លួនឯង ឬក៏គប្បីលោកសួរបញ្ជាក់នៅទីនេះ ដើម្បីឲ្យភាគី និងសាធារណជនយល់អំពីអត្តសញ្ញាណបុគ្គលដែលកំពុងតែផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះនេះ។ វាពាក់ព័ន្ធយ៉ាងដូចម្តេចទៅឈ្មោះ ជាមួយនឹងឈ្មោះ ចាន់ គា ហើយគាត់ចូលរួមយ៉ាងដូចម្តេចនៅក្នុងកិច្ចសម្ភាសន៍។ នេះជារំលេច ដើម្បីឲ្យបញ្ជាក់ឲ្យច្បាស់លាស់។ ឥឡូវហ្នឹងវាមានភាពច្របូកច្របល់តាំងពីទីទៅ។ សូម្បីតែភាគី ខាងការពារក្តីក៏មានការឆ្ងល់ដែរ ហើយការដែលលោកសន្និដ្ឋានអំមិញ គឺសន្និដ្ឋានដោយខ្លួនឯង។ វាមិនមែនជាព័ត៌មានដែលត្រូវសួរដេញដោលដោយសវនាការដែលសម្រាប់ភាគីទាំងអស់ ទាំងសាធារណជនយល់ដឹងពីបញ្ហានេះទេ។ លោកយល់ដែរទេ?

E1/387.1/Old-1

**លោក ស្រ៊ា រតនៈ៖**

បាទ លោកប្រធាន។

**សួរដោយលោក ស្រ៊ា រតនៈ៖**

**ស៖** សូមដើម្បី -- ខ្ញុំសូមសួរត្រឡប់ទៅក្រោយវិញ តើលោកស្រីមានចាំទេ លោកស្រីធ្លាប់បានផ្តល់ -- លោកស្រីធ្លាប់បានចូលរួមផ្តល់កិច្ចសម្ភាសន៍មួយកាលពីឆ្នាំ២០០៥ ដែរទេ?

[១៤:០០:១៨]

**លោកស្រី អ៊ិន យឿង៖**

**ឆ៖** ខ្ញុំមិនដែលបានសម្ភាសទេក្នុង២០០៥ហ្នឹង។ ហើយដែលប្តីខ្ញុំទេហ្នឹងដែលជួបជាប់ជួនជំពាក់ជំពិនហ្នឹង ដែលប្តីខ្ញុំទេមានមុខឡើងហ្នឹង។ លោកអង្គការយក ដែលច្រឡំខ្ញុំ ច្រឡំហើយ ព្រោះប្តីខ្ញុំមានមុខឡើងហ្នឹង ព្រោះពួកក្រុមគ្រួសាររបស់គាត់ផ្ទាល់ ឯខ្ញុំសាច់ថ្លៃទេ។ ឥឡូវប្តីខ្ញុំគាត់ក៏មក គាត់ថាគាត់ចង់ឡើងណាស់ ប៉ុន្តែខ្ញុំថា ឈ្មោះខ្ញុំនោះវិញ។

**ស៖** អ៊ីចឹងបានន័យថា កាលនោះគឺប្តីលោកស្រីទេដែលបានឆ្លើយ?

**ឆ៖** ចាស ប្តីខ្ញុំទេបានឆ្លើយនុ៎ង។ ឥឡូវគាត់មកៗតើ គាត់ចង់ឡើងណាស់។ គាត់ថាឯងមិនមែនត្រូវឡើងទេ ខ្ញុំដែលត្រូវឡើង។ ហើយខ្ញុំសួរបងឡើងអធិបតីហ្នឹងដែរថា មិនត្រូវយកខ្ញុំទេ ត្រូវយកគាត់។

**ស៖** ចុះលោកស្រីពេលនុ៎ងមានបានលូកមាត់ឆ្លើយជំនួសប្តីលោកស្រី ឬក៏ចូលរួមក្នុងកិច្ចសម្ភាសន៍ហ្នឹងខ្លះទេ?

**ឆ៖** ខ្ញុំបានឆ្លើយបានតិចតួចខ្លះដែរ ហើយដែលអ្នកខាងហ្នឹង មានតាមួយនៅក្បែរហ្នឹងគាត់ដឹងជ្រៅជ្រះ គាត់ឆ្លើយជំនួសច្រើន។

**ស៖** ចុះអ្នកដែលចូលរួមឆ្លើយជំនួសហ្នឹង ក្រៅពីតាហ្នឹងមានអ្នកជិតខាងស្រីណាផ្សេងទៀតទេ?

**ឆ៖** គ្មានស្រីណាទៀតទេ ឃើញតែពីរនាក់តា។

[១៤:០២:០២]

**ស៖** អ៊ីចឹងខ្ញុំបញ្ជាក់ឡើងវិញ នៅពេលសម្ភាសហ្នឹងអ្នកដែលឆ្លើយមានតែប្តីលោកស្រី, តា និងលោកស្រីតែម្នាក់គត់?

**ឆ៖** ចាស។

**ស៖** ក្រៅៗពីលោកស្រី គឺគ្មានស្រីឯណា ឬទៀតទេ នៅពេលសម្អាសហ្នឹង?

**ឆ៖** ខ្ញុំដូចថាវាភ្លេចភ្លាំងពាក់កណ្ដាលហើយ មិនដឹងយ៉ាងណាយ៉ាងណីទេ អង្គាល់ហ្នឹងវាយូរពេក ហើយដល់មកស្រាវជ្រាវអង្កាល់ហ្នឹងវាភ្លេចអស់។ វាស្រាវជ្រាវវិញ ក៏អត់មានអាញាណក្នុងខ្លួនដែរ ទទេ ភ្លេចភ្លាំងអស់រលីងតែម្ដង។

**ស៖** ខ្ញុំគ្រាន់តែចង់សួរបញ្ជាក់លោកស្រីថា អ្នកឆ្លើយភេទស្រី ក្រៅតែពីលោកស្រីអត់មានអ្នកជិតខាងណាម្នាក់ទៀតចូលរួមទេ។ អ៊ីចឹងមែនទេបាទ?

**ឆ៖** មានដែរ តូចតាចក្មេងធំអីដែរនៅឈរក្បែរចោមរោមគាត់នុ៎ង ប៉ុន្ដែចេះតែថា អានោះបន្ដិចថាអានេះទៅ អ្នកដែលឆ្លើយ ចេះតែថាគ្រប់តែគ្នាទៅ។ ប៉ុន្ដែមានដែរ វាមិនទទេសោះទេ វាមានធំ មានតូច មានប្រុស មានស្រីដែរពីរបីនាក់ដែរ។ ហើយតាហើយនិងខ្ញុំហ្នឹងបានឆ្លើយនូវសំណួរដែរ។

**លោក ស្រ៊ា រតនៈ៖**

តាមរយៈចម្លើយគាត់ប៉ុននេះ សូមលោកប្រធានពិនិត្យសម្រេចថា តើពិនិត្យថា តើអ្នកជិតខាងភេទស្រីដែលកំពុងឆ្លើយក្នុងនេះជាគាត់ហ្នឹង ឬក៏មានអ្នកណាផ្សេងទៀត? ហើយតើខ្ញុំអាចបន្ដសំណួរ?

[១៤:០៤:១១]

**ប្រធានអង្គជំនុំ៖**

លោកអាចសួរបាន បន្ដសួរបាន។ អានេះគ្រាន់បញ្ជាក់រួចហើយ ដើម្បីឲ្យភាពពាក់ព័ន្ធនៃការផ្ដល់ចម្លើយ ពីព្រោះជាការចម្លែកដែលខាងកិច្ចដំណើរការនីតិវិធីនេះវា យើងវាមិនដែលជួបនៅក្នុងធ្វើតុលាការយូរហើយនេះ។ មានអ្នកដែលចូលរួមផ្ដល់សក្ខីកម្មអីណានៅក្នុងឯកំណត់ហេតុនេះ វាមិនដែលវាចម្លែក។ ហើយត្រូវបានកោះហៅគាត់មកធ្វើសក្ខីកម្មនេះ។ ការស្ដាប់សក្ខីកម្មតាមធម្មតាត្រូវធ្វើដាច់ដោយឡែក ស្ងៀមស្ងាត់រវាងអ្នកសួរនិងអ្នកឆ្លើយ។ ហើយបែរជាច្របូកច្របល់អ៊ីចឹង ហើយស្រាប់ដល់ពេលឥឡូវវាទៅសួរបញ្ជាក់បញ្ហាហ្នឹងឲ្យបានច្បាស់លាស់។ បើថាច្បាស់លាស់ហើយ អាចធ្វើទៅបានកម្រិតណា អាហ្នឹងស្រេចលើបច្ចេកទេស និងវិធីសាស្ត្ររបស់ក្រុមលោក ពីព្រោះក្រុមលោកជាអ្នកស្នើសុំ។

អញ្ជើញលោកស្រីមេធាវី អង់តា ហ្គីសសេ -- មេធាវី គង់ សំអុន បាទ អញ្ជើញ!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំសូមអនុញ្ញាតធ្វើការកត់សម្គាល់ទៅតាមសម្ដីរបស់សាក្សី

ដែលបានបញ្ជាក់អម្បាញ់មិញ ពាក្យថាអ្នកជិតខាងនេះ នៅក្នុងឯកសារ E3/7525នេះ គឺមិនមែនមានន័យថា សំដៅទៅលើតែអ្នកស្រីដែលជាសាក្សីនៅពេលនេះ ម្នាក់ប៉ុណ្ណោះទេ។ តាមសម្តីរបស់អ្នកស្រីបានបញ្ជាក់អម្បាញ់មិញហើយថាមានតាម្នាក់ ហើយនិងមានប្រុសស្រីក្មេងចាស់ជាច្រើនអ្នកទៀត ដែលជាអ្នកផ្តល់យោបល់ និយាយឆ្លើយឆ្លងចូលក្នុងការសម្ភាសនេះផងដែរ។ អ៊ីចឹងពាក្យថា "អ្នកជិតខាង" នេះ គឺទោះបីខាងៗក្រោយឯកសារនេះ បញ្ជាក់ថា អ្នកស្រី អ៊ិន យឿង នេះក៏ដោយក៏មិនមែនមានន័យថាសម្តីទាំងអស់ដែលចេញមកពាក្យថា "អ្នកជិតខាង" នេះគឺជាសម្តីរបស់ អ៊ិន យឿង នេះដែរ។ បានដូច្នេះវាមានភាពច្របូកច្របល់ចំពោះឯកសារនេះ ពិតច្បាស់ណាស់។ អ៊ីចឹងសូមអង្គជំនុំជម្រះមេត្តាពិនិត្យបាទ។ សូមអរគុណ។

[១៤:០៦:២០]

**ប្រធានអង្គជំនុំ៖**

បាទសូមលោកបន្តទៀត ហើយគួរតែត្រូវសួរអំពីម្ចាស់អ្នកដែលស្នើហ្នឹង គឺភាគីដែលស្នើ គួរតែសួរបញ្ជាក់មើល ថាតើគាត់ សរុបមកវិញថាគាត់ដឹងរឿងរ៉ាវអ្វីខ្លះទៅវាពាក់ព័ន្ធនឹងការប្រព្រឹត្តចំពោះជនជាតិវៀតណាមនៅអំឡុងពេលដែលគាត់រស់នៅកម្ពុជាប្រជាធិបតេយ្យនោះ។ ហើយបើគាត់មិនដឹងអីទេទៅហៅសាក្សីដែលមិនដឹងរឿង យកមកស្តាប់សក្ខីកម្មយ៉ាងម៉េចទៅ។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

បាទ លោកប្រធាន ខ្ញុំសូមរំឭកថាសាក្សីនេះជាសាក្សីរបស់អង្គជំនុំជម្រះ។ ដើម្បីឆ្លើយតបទៅនឹងការកត់សម្គាល់របស់មេធាវីការពារក្តីនោះគឺថា សំណួរសុំឲ្យបំភ្លឺ ត្រូវបានសួររួចមកហើយ ហើយគាត់ៗថា ពេលគេសួរហ្នឹង គឺសួរប្តីគាត់ឈ្មោះ ចាន់ គា ហើយអត់មានស្ត្រីណាទៀតមានវត្តមាននៅទីនោះទេ មានតែក្មេងៗ។ ហើយគាត់ ក៏គាត់បានលូកមាត់ឆ្លើយតបផងដែរ នៅពេលសម្ភាសនោះ។ ដូច្នេះយើងគិតថា អ្នកជិតខាងនៅក្នុងកិច្ចសម្ភាសន៍ហ្នឹង គឺពិតជាឈ្មោះ អ៊ិន យឿង ដែលគាត់មានវត្តមាននៅទីនេះហើយ។ ដូច្នេះសូមលោកប្រធានអនុញ្ញាតឲ្យខាងយើងខ្ញុំសួរបន្តទៀត សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

[១៤:០៧:៥៨]

**លោក វ៉ិចទ័រ កូប៉េ៖**

ជាការកត់សម្គាល់តូចមួយទេ មិនមែនជាការជំទាស់ទេ ដែលអនុញ្ញាតឲ្យសហព្រះរាជអាជ្ញាសួរបន្តទៅទៀតនោះ។ បើសិនណាជាមិនច្បាស់ថាគាត់ជា ពិតជាបានឆ្លើយៗយ៉ាងដូច្នេះ សហព្រះរាជអាជ្ញាមិនគួរសួរនូវអ្វីដែលគាត់ឆ្លើយថា គាត់មិនបាននិយាយអំពីចំណុចណាមួយ គាត់អត់បានដឹងអំពីជនជាតិវៀតណាមនៅខាងក្រៅភូមិរបស់គាត់។ ដូច្នេះវាជារឿងមួយនាំឲ្យមានហានិភ័យណាស់ក្នុងការសួរសំណួរណាដែលគាត់ឆ្លើយថាគាត់មិនបានដឹងអីនោះ។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាតបន្តទៅទៀត តំណាងសហព្រះរាជអាជ្ញា ហើយសូមសួរច្បាស់លាស់ ព្រោះបញ្ហាបំណងនៃការស្តាប់សក្ខីកម្មសាក្សី គឺសាក្សីណាដែលដឹងរឿងអង្គហេតុ ដែលមានការពាក់ព័ន្ធនឹងគោលដៅដែលត្រូវសួរ។ ហើយបើវាទំនងជាមានការភ័ន្តច្រឡំទេ គឺអាចបញ្ចប់នៃការតាំងសំណួរដើម្បីជ្រើស អាចបញ្ចប់ត្រឹមហ្នឹង ឬក៏ជ្រើសរើសសាក្សីថ្មីផ្សេងទៀតមកជំនួស ដែលអ្នកណាដែលដឹងរឿងពិតប្រាកដ។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

សូមអរគុណលោកប្រធាន។ ខ្ញុំនឹងព្យាយាមបំភ្លឺបញ្ហានេះជាមួយសាក្សី ដើម្បីឲ្យច្បាស់ទាំងអស់គ្នា។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** លោកស្រីសាក្សី នៅពេលដែលប្ដីរបស់លោកស្រី ចាន់ គា ត្រូវបានគេសម្ភាសនោះ តើលោកស្រីមានបានលូកមាត់និយាយជាមួយលោក អ៊ីសា ឧស្មាន ដែលជាបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាទេ? លោកស្រីមានបានឆ្លើយបន្ថែមទៅលើចម្លើយរបស់ប្ដីលោកស្រី? លោកស្រីផ្ដល់ព័ត៌មានលម្អិតបន្ថែមពីលើចម្លើយប្ដីរបស់លោកស្រីទេនៅពេលនោះ?

[១៤:១០:០២]

**លោកស្រី អ៊ិន យឿង៖**

**ឆ៖** ខ្ញុំភ្លេចអស់ហើយ អត់ដឹងបានឆ្លើយ មិនបានឆ្លើយទេ ខ្ញុំភ្លេចអស់ហើយ។

**ស៖** លោកស្រីសាក្សី នៅចុងបញ្ចប់នៃកិច្ចសម្ភាសន៍ តើលោកស្រីមានចាំទេថា ឧស្មាន ដែលជាអ្នកសម្ភាសប្ដីលោកស្រីហ្នឹង មានសួរឈ្មោះលោកស្រីទេ?

**ឆ៖** មានៗសួរខ្ញុំដែរ។

**ស៖** លោកប្រធាន ប្រហែលជាខ្ញុំព្យាយាមសួរសំណួរមួយចំនួនទៀតដើម្បីពិនិត្យមើល ថាតើយើងទទួលចម្លើយពីសាក្សីបាន ឬក៏មិនបាន។ ខ្ញុំព្យាយាមចាប់ផ្ដើមពីដំបូងមកវិញ។ លោកស្រីឆ្លើយថា លោកស្រីត្រូវបានគេចាត់តាំងឱ្យទៅក្នុងកងចល័ត នៅពេលអាយុ១៥ឆ្នាំ នៅឆ្នាំ៧៥។ តើលោកស្រីអាចជម្រាបបានទេ នៅសម័យនោះ តើមានកងចល័តសម្រាប់យុវជនទេ? ហើយចុះមាន គេមានបែកងចែកជាកងចល័តកុមារ កងចល័តយុវជន ឬក៏កងចល័តអ្នកដែលមានវ័យលើហ្នឹងទៀតទេ?

**ឆ៖** គេបែងចែកយុវជន ក៏ទៅមួយកន្លែងផ្សេង កុមារក៏ទៅមួយកន្លែងផ្សេង ឯចំណែកនារីៗហ្នឹង ក៏ទៅមួយកន្លែងផ្សេងដែរ អត់មានដាក់ច្រឡូកច្រឡាសគ្នាទេ។

**ស៖** តើបើយើងចូលក្នុងចល័តបានហ្នឹង ទាល់តែមានអាយុប៉ុន្មាន លោកស្រីចាំទេ? ខ្ញុំសំដៅលើកងចល័តជំទង់ដែលចាប់ពីមានអាយុប៉ុន្មានទៅ?

**ឆ៖** ចាប់ពីអាយុ១៥ ខ្ញុំសំដៅហ្នឹង គេហៅកម្លាំងពេញហើយ កងចល័ត។

[១៤:១២:៤២]

**ស៖** លោកស្រីចាំបានទេថា លោកស្រីបាននិយាយប្រាប់អ្នកសម្ភាសនៃមជ្ឈមណ្ឌលឯកសារកម្ពុជា គឺនៅទំព័រ១៥ជាភាសាបារាំង, ១៥ជាភាសាអង់គ្លេស គឺឯកសារ E3/7525 ហើយនិងជាភាសាខ្មែរ គឺទំព័រ ERN 00089601។ លោកស្រីចាំទេ លោកស្រីថា សមាជិកកងចល័តហ្នឹង ចាប់ពីអាយុ១២ឆ្នាំឡើង?

**ឆ៖** ១២ឆ្នាំហ្នឹង គេឱ្យលើក មានបង្គី មានចបហ្នឹង គេឱ្យលើកថ្នល់ អាតូចៗហ្នឹង។ ហើយដែលអាយុ១៥ឆ្នាំហ្នឹង គេឱ្យលើកប្រព័ន្ធភ្លឺស្រែ ប្រឡាយ ហ្នឹងអាយុ អាហ្នឹងវ័យមនុស្សកម្លាំង។ ហើយតូចៗហ្នឹង គេឱ្យចប បង្គីហ្នឹង លើកថ្នល់។

**ស៖** ដូច្នេះមានន័យថា អ្នកដែលរៀបការហើយហ្នឹង គឺលែងធ្វើការនៅក្នុងកងចល័តទៀតហើយ មែនទេ?

**ឆ៖** អ្នកដែលនៅកងចល័តរៀបការហ្នឹង គេឱ្យនៅតាមសហករណ៍ អត់មានឱ្យនៅកងចល័តទៀតទេ ឱ្យនៅតាមសហករណ៍។

**ស៖** តើលក្ខខណ្ឌការងារ និងជីវភាពនៅក្នុងកងចល័តហ្នឹង មានលក្ខណៈពិបាកជាងលក្ខខណ្ឌការងារនៅសហករណ៍ មែនទេ?

**ឆ៖** លក្ខខណ្ឌការងារនៅកងចល័តនុំងពិបាកណាស់ មិនមែននៅដូចសហករណ៍ទេ។ សហករណ៍ទៅ វាបានហូបគ្រប់គ្រាន់ នៅកងចល័តបានហូបតិចៗ ហើយសម្ពស្សុទ្ធតែដើមចេក កំណាត់ៗហ្នឹង ដឹងហូបបានដោយសារពិបាកពិបិ ចេះតែហូបទៅ បើមិនហូប មិនបាន ចេះតែហូបទៅ។ គេឱ្យហូប ចេះតែហូបទៅ មិនហ៊ានខ្លាំងទេ គេឱ្យទៅណាទៅនុំងៗ គ្មានហ៊ានប្រឆាំងបានទេ។

[១៤:១៥:១១]

**ស៖** ពាក់ព័ន្ធទៅនឹងបញ្ហានេះដដែល ដោយសារតែនៅក្នុងសហករណ៍ លក្ខខណ្ឌការងារស្រួលជាង។ អ៊ីចឹងមានយុវជនណាដែលស្ម័គ្រចិត្តរៀបការ ដើម្បីចាកចេញពីកងចល័តទៅធ្វើការនៅតាមសហករណ៍វិញព្រោះស្រួលជាង មានអ៊ីចឹងទេ?

**ឆ៖** អត់មានយុវជនដែលចេញពីសហករណ៍ មកការជាមួយកងចល័តហ្នឹង មានច្រើនដែរ ពីរបីគូដែរ ថ្ងៃណាគេស្ម័គ្រចិត្តទៅការបានដែរ។ បើមិនស្ម័គ្រចិត្តហ្នឹង មិនហ៊ានការទេ។

**ស៖** ដើម្បីឱ្យយល់ច្បាស់អំពីចំណុចនេះ ហើយដើម្បីឱ្យបញ្ជាក់ឱ្យច្បាស់ថា លោកស្រីពិតជាអ្នកជិតខាងនៅក្នុងឯកសារសម្ភាសហ្នឹង ឬក៏យ៉ាងម៉េច ខ្ញុំចង់ដកស្រង់ឃ្លាមួយនៃសម្ដីរបស់អ្នកជិតខាង គឺក្នុងឯកសារ E3/7525 ទំព័រ២៦ ជាភាសាបារាំង អង់គ្លេសក៏២៦ដែរ។ ខ្ញុំសូមផ្ដល់ ERN ជាភាសាបារាំងវិញល្អជាង ERNគឺ 00903069, ជាភាសាអង់គ្លេសគឺ 00884999, ជាភាសាខ្មែរ 00089612 រហូតដល់ 613។ នេះជាចម្លើយរបស់អ្នកជិតខាងដែលបានចូលរួមនៅក្នុងការសម្ភាស៖ "អ្នកដែល មានអ្នកចង់ការពីព្រោះថា ក្រោយពីការហើយ គេចេញពីកងចល័តទៅសហករណ៍។ អ៊ីចឹងហើយបានជាមានការលែងលះគ្នាច្រើននោះ។ តើមានអ្នកណាត្រូវបានគេបង្ខំឱ្យរៀបការដោយខ្លួនមិនចង់ទេ? ពេលនោះអ្នកជិតខាងនិយាយថា៖ អត់ទេ។ គាត់ថា៖ គេចង់ការ ព្រោះគេចង់ត្រឡប់ទៅសហករណ៍វិញ។ នៅសហករណ៍ការងារស្រាលជាង គឺគ្រាន់តែជួនកាលទៅ គ្រាន់តែរែកបាយ។ អ៊ីចឹងគេចង់ការដើម្បីទៅធ្វើការនៅតាមសហករណ៍វិញ។" លោកស្រីចាំ ថាលោកស្រីបានឆ្លើយអ៊ីចឹងទេ នៅពេលដែលមជ្ឈមណ្ឌលឯកសារកម្ពុជាមកសម្ភាសប្ដីលោកស្រី ឈ្មោះ ចាន់ គា នោះ?

**ឆ៖** ខ្ញុំបានឆ្លើយអ៊ីចឹងមែន។

[១៤:១៨:១៣]

**ស៖** លោកប្រធាន ជាមួយនឹងចម្លើយអម្បាញ់មិញនេះ គឺយើងគិតថា ច្បាស់ហើយ គឺសាក្សីនេះហើយ គឺជាអ្នកជិតខាងដែលនៅក្នុងឯកសារនោះ ។ ហើយខ្ញុំនឹងព្យាយាមសួរសំណួរពាក់ព័ន្ធទៅនឹងការ

ប្រព្រឹត្តចំពោះជនជាតិវៀតណាម។ លោកស្រីសាក្សី នៅក្នុងកងចល័តរបស់លោកស្រី លោកស្រីថា លោកស្រីធ្វើការនៅកន្លែងផ្សេងៗ។ តើនៅក្នុងកងចល័តរបស់លោកស្រី មានជនជាតិវៀតណាមទេ ឬក៏មានអ្នកណាដែលមានប្ដីខ្មែរទេ?

**ផ៖** មានតែទាហានខ្មែរគេធ្វើយោធា មាននៅជាមួយកងចល័តហ្នឹងមានមែន ទាហានខ្មែរ។ ដូចគ្នាហ្នឹង គេមាននៅជាមួយកងចល័តនៅជាមួយតាមភូមិមានមែន ទាហានខ្មែរ ដែលទាហានវៀតណាមនោះ ខ្ញុំអត់បានឃើញមែន។

**ស៖** លោកស្រីច្រឡំហើយ ខ្ញុំអត់មាននិយាយពីទាហានទេ។ ខ្ញុំនិយាយអំពីនារីអាយុពី១៥ទៅ គឺអាយុប្រហែល ប្រហាក់ប្រហែលលោកស្រីហ្នឹង ដែលធ្វើការជាមួយលោកស្រីហ្នឹង។ ខ្ញុំមិននិយាយពីទាហានទេ ខ្ញុំនិយាយពីជនស៊ីវិល។ ខ្ញុំចង់និយាយថា នារីដែលធ្វើការនៅក្នុងកងលោកស្រីហ្នឹង មានអ្នកណាជាជនជាតិវៀតណាមទេ ឬក៏មានអ្នកណាដែលមានឪពុក ឬក៏ម្ដាយជាជនជាតិវៀតណាមទេ?

**ផ៖** អត់មានទេ។

[១៤:២០:០៧]

**ស៖** ខ្ញុំនឹងដកស្រង់នូវចម្លើយដែលប្រហែលជា ចម្លើយរបស់លោកស្រីឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជា គឺឯកសារ E3/7525 ពាក់ព័ន្ធទៅនឹងគ្រួសារជនជាតិវៀតណាម ដែលត្រូវបានបញ្ជូនពីកំពង់ត្រាច។ ជាភាសាបារាំងគឺ 00903085, ជាភាសាអង់គ្លេសគឺ 00885014 រហូតទៅដល់15, ជាភាសាខ្មែរគឺមានបីទំព័រ 00089628រហូតដល់630។ ពេលនោះគេសួរដូចតទៅ ខ្ញុំសូមអាន៖ “សំណួរ៖ លោកស្រីចាំចំនួនវៀតណាមដែលគេចាប់នៅភូមិទេ? ពេលនោះអ្នកជិតខាងឆ្លើយថា៖ ទេ ខ្ញុំមិនដឹងទេ។ ខ្ញុំដឹងតែវៀតណាមនៅកំពង់ត្រាច ដែលគេចាប់ខ្លួននៅក្នុងភូមិខ្ញុំ។ សំណួររបស់ ឧស្មាន៖ គេបញ្ជូនមកពីកំពង់ត្រាច មែនទេ? អ្នកជិតខាងដែលប្រហែលជាលោកស្រីហ្នឹងហើយ៖ ចាស ផ្លាស់ពីកំពង់ត្រាច គេយកទៅ។”

ខ្ញុំសូមរំលងមួយឃ្លា៖ “ខ្ញុំមិនចាំអំពីចំនួនគ្រួសារហ្នឹង ដែលគេបញ្ជូនមកភូមិខ្ញុំទេ ក៏ប៉ុន្តែខ្ញុំឃើញគ្រួសារបួនត្រូវបានបញ្ជូនមកភូមិខ្ញុំ ភូមិត្រកៀបក្ដាម។ ក្រោយគេបញ្ជូនមកដល់ភូមិភូមិហើយ គេចាប់ហើយ គេយកទៅបាត់។ ខ្ញុំចាំជនជាតិវៀតណាមម្នាក់ដែលយំខ្លាំងមែនទែន ដោយសារតែគេបំបែកពីប្ដី។ បន្ទាប់មកទៀតអ្នកជិតខាងនោះបាននិយាយថា៖ គេចាប់វៀតណាមនោះ មួយខែក្រោយពីគេបញ្ជូនមកដល់ភូមិហ្នឹងហើយ។” តើលោកស្រីធ្លាប់បាននិយាយប្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជាទេ ថាមាន

បួនគ្រួសារវៀតណាមដែលត្រូវបានផ្ទេរពីកំពង់ត្រាច មកភូមិរបស់លោកស្រី ហើយក្រោយមកត្រូវបានគេចាប់ខ្លួន?

**ឆ៖** ខ្ញុំភ្លេចអស់ហើយ មិនដឹងអីណាផង។ ខ្ញុំរកនឹកមិនឃើញ ភ្លេចអស់។

[១៤:២៣:២០]

**ស៖** នៅក្នុងកិច្ចសម្ភាសន៍នេះ លោកស្រីបាននិយាយអំពីឈ្មោះមីងរបស់លោកស្រី ឈ្មោះ មីង ងាំ។ មីងងាំ ហ្នឹងជាសមាជិកគ្រួសារលោកស្រីមែនទេ?

**ឆ៖** មីងងាំ មិនមែនទេ។ មិនមានមីង ងាំ មិនមែនទេ អត់មែនឈ្មោះគ្រួសារខ្ញុំទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធានច្បាស់ណាស់ថា មិនមែនគាត់នោះទេ។ ដូច្នេះគឺថាវាមិនមានមូលហេតុអ្វីដែលត្រូវយោងទៅលើឯកសារនោះទេ ព្រោះថាឯកសារបញ្ជាក់ច្បាស់ថា មិនមែនរបស់គាត់ទេ។ ហើយយើងក៏មិនត្រូវភ្លេចទេ ថានេះជាកិច្ចសម្ភាសន៍ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា។ ហើយយើងក៏មិនមាននីតិវិធីជាក់លាក់ ឬក៏នីតិវិធីជាធរមានក្នុងការកំណត់អំពីអត្តសញ្ញាណ ឬក៏មានលក្ខណៈណាមួយតាមផ្លូវច្បាប់។ ដូច្នេះខ្ញុំស្នើសុំថា យើងគួរតែបញ្ចប់នៅពេលនេះតែម្តងទៅ។

**កញ្ញា អង់តា ហ្គិសសេ៖**

លោកប្រធាន ខ្ញុំសូមផ្តល់មូលដ្ឋានច្បាប់ ដើម្បីគាំទ្រទៅនឹងការលើកឡើងរបស់មេធាវីការពារក្តី គឺនៅក្នុងវិធានផ្ទៃក្នុងបានបញ្ជាក់ច្បាស់ថា សហព្រះរាជអាជ្ញា ឬក៏មេធាវីការពារក្តីអាចបញ្ចប់នូវការសួរសាក្សី ប្រសិនបើគិតថា មិនអាចផ្តល់ -- មិនអាចនាំទៅរកការស្វែងរកការពិតនោះ។ ដូច្នេះសូមឲ្យលោកប្រធានមេត្តាប្រើប្រាស់វិធានផ្ទៃក្នុងរបស់យើង ដើម្បីដោះស្រាយបញ្ហាដែលកំពុងតែជួបប្រទះនេះ។ ចម្លើយរបស់សាក្សីតាំងពីដើមមកដល់ហ្នឹង ដូចជាមើលទៅមិនមានប្រយោជន៍អ្វីដើម្បីស្វែងរកការពិតទេ។

[១៤:២៥:២៥]

**លោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

លោកប្រធាន ខ្ញុំសួរសំណួរមួយចំនួនធំអម្បាញ់មិញនេះ ដើម្បីបង្ហាញឲ្យឃើញច្បាស់ថា តើពិតជាគាត់ ឬក៏មិនមែន។ ហើយចម្លើយរបស់គាត់វាដូចជាស៊ីសង្វាក់គ្នាទៅនឹងចម្លើយដែលមាននៅក្នុងកិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា។ លើកលែងតែបញ្ហាពាក់ព័ន្ធទៅនឹងជនជាតិវៀតណាម

គាត់ដូចជាមិនដឹងអ្វីទេមើលទៅ ពាក់ព័ន្ធទៅនឹងជនជាតិវៀតណាមនេះ។ ខ្ញុំសូមរំឭកថា មជ្ឈមណ្ឌលឯកសារកម្ពុជាបានសម្ភាស ហើយបានថតសំឡេង ហើយបន្ទាប់មកបានធ្វើប្រតិចារឹកដូចដែលយើងបានឃើញទាំងអស់គ្នា។ ដូច្នេះច្បាស់ណាស់គឺថា ស្ត្រីនៅក្នុងបទសម្ភាសន៍នោះគឺជាគាត់ហ្នឹងហើយ។ អ៊ីចឹងខ្ញុំសូមសួរសំណួរពីរបីបន្ថែមទៀតពាក់ព័ន្ធទៅនឹងសមាជិកគ្រួសាររបស់គាត់ ដើម្បីឲ្យដឹងថាតើគាត់មានមីងម្នាក់ជាជនជាតិវៀតណាម ឬចិន ឬក៏អត់។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

ចុះខាងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីមានការកត់សម្គាល់ ឬមានមតិយោបល់អ្វីដែរទេ លើបញ្ហាបន្ត ឬក៏បញ្ឈប់ការស្ដាប់សក្ខីកម្មសាក្សីរូបនេះ។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ ចំពោះខ្លួនខ្ញុំផ្ទាល់ ខ្ញុំមានឯកសារមួយដែលខ្ញុំចង់ប្រើប្រាស់ ដែលមិនមែនជាកិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាទេ គឺឯកសារE3/7816ដែលជាកំណត់ហេតុស្ដាប់ចម្លើយបុគ្គលម្នាក់ ដែលមកពីភូមិតែមួយជាមួយលោកស្រីសាក្សីរូបនេះ។ ខ្ញុំចង់តទល់គាត់ទៅនឹងចម្លើយរបស់បុគ្គលរូបនោះ ដែលបានដឹងអំពីហេតុការណ៍នៅឆ្នាំ៧៧ ពាក់ព័ន្ធទៅនឹងផ្នែកនៃសវនាការរបស់យើងនេះ។ អ៊ីចឹងគឺឯកសារនេះគឺ E3/7816។ ខ្ញុំមិនដឹងថា តើគាត់អាចឆ្លើយអ្វីបានពាក់ព័ន្ធទៅនឹងសក្ខីកម្មរបស់សាក្សីរូបនោះ ក៏ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ខ្ញុំចង់បានប្រតិកម្មតបរបស់សាក្សីរូបនេះពាក់ព័ន្ធទៅនឹងការរៀបការដោយបង្ខំ ព្រោះថាការរៀបការដោយបង្ខំហ្នឹង ក៏មានបញ្ជាក់នៅក្នុងកិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជាដែរ។ ហើយនៅពេលឆ្លើយទៅនឹងសំណួររបស់សហព្រះរាជអាជ្ញា ក៏គាត់និយាយអំពីរឿងនេះដែរ។ ដូច្នេះយើងគោរពទៅតាមការសម្រេចរបស់អង្គជំនុំជម្រះ ទោះជាយ៉ាងណាក៏ដោយ គឺយើងមានសំណួរខ្លះដើម្បីសួរគាត់ លោកប្រធាន។

[១៤:២៨:០៧]

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:២៩:២៥]

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះបញ្ហាករណីនេះ អង្គជំនុំជម្រះសម្រេចដូច្នេះថា ឥឡូវនេះបន្តការស្ដាប់សក្ខីកម្មរបស់គាត់តទៅទៀត ប៉ុន្តែភាគីពាក់ព័ន្ធ ជាពិសេសខាងសហព្រះរាជអាជ្ញារួមទាំងសហមេធាវីនាំមុខ

តំណាងដើមបណ្តឹងរដ្ឋប្បវេណី មិនគួរគប្បីផ្អែកលើមូលដ្ឋាននៃប្រតិចារឹកកំណត់ហេតុដែលគាត់ផ្តល់កិច្ចសម្ភាសន៍ថា អះអាងថាគាត់ផ្តល់កិច្ចសម្ភាសន៍ជាមួយនឹងខាងមជ្ឈមណ្ឌលឯកសារកម្ពុជានៅក្នុងឆ្នាំ ២០១៥នោះឡើយ ពីព្រោះ -- ២០០៥នោះឡើយ ពីព្រោះវាមិនមានភាពមិនច្បាស់លាសទេ។ ប៉ុន្តែសហព្រះរាជអាជ្ញារួមទាំងភាគីដទៃទៀត មិនអាចសួរដេញដោលពាក់ព័ន្ធជាមួយនឹងការដឹងទូទៅរបស់គាត់ដែលបានគាត់បានមកចំពោះមុខហើយ ហើយវាពាក់ព័ន្ធនឹងអង្គហេតុដែលយើងបានកំណត់ធ្វើសវនាការនៅក្នុងវិសាលភាព០០២/០២ ប្រសិនបើអាចធ្វើទៅបាន។ ដើម្បីជាប្រយោជន៍ក្នុងការរួមចំណែកក្នុងការស្វែងរកការពិតក្នុងរឿងក្តីនេះ ដោយសារគាត់វត្តមាននៅចំពោះមុខអង្គជំនុំជម្រះរួចហើយ។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

សូមអរគុណលោកប្រធាន អ៊ីចឹងខ្ញុំមិនសួរអីវែងឆ្ងាយច្រើនទេ។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** លោកស្រីសាក្សី ខ្ញុំចង់សួរជាលក្ខណៈទូទៅ ថានៅចន្លោះឆ្នាំ៧៥ ដល់ឆ្នាំ៧៩ នៅពេលដែលកងកម្លាំងកម្ពុជាប្រជាធិបតេយ្យកាន់កាប់តំបន់របស់លោកស្រី តើលោកស្រីមានស្តាប់ឮអ្វីពាក់ព័ន្ធទៅនឹងជោគវាសនារបស់ជនជាតិវៀតណាមដែរឬទេ? គឺជនជាតិវៀតណាមដែលនៅក្នុងតំបន់របស់លោកស្រី ឬក៏ជនជាតិវៀតណាមដែលកើតចេញពីឪពុក ឬក៏ម្តាយជាជនជាតិវៀតណាមខ្មែរ? លោកស្រីមានដឹងអំពីបញ្ហាហ្នឹងទេ?

[១៤:៣១:៣០]

**លោកស្រី អ៊ិន យឿង៖**

**ឆ៖** ខ្ញុំអត់បានដឹងទេ។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

លោកប្រធាន ខ្ញុំអស់សំណួរហើយ។ ខ្ញុំគិតថាមេធាវីដើមបណ្តឹងរដ្ឋប្បវេណីប្រហែលជាមានសំណួរមួយចំនួន គាត់ចង់ឲ្យសាក្សីរូបនេះតទល់ជាមួយនឹងសក្ខីកម្មរបស់សាក្សីផ្សេងទៀត ដើម្បីធ្វើឲ្យគាត់មានភាពចងចាំឡើងវិញ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទអង្គជំនុំជម្រះអនុញ្ញាត សូមអញ្ជើញ!

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម និងភាគីទាំងអស់។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

**ស៖** ជម្រាបសួរលោកស្រីសាក្សី ខ្ញុំឈ្មោះ ម៉ារី ហ្គីរ៉ូដ៍ ខ្ញុំជាតំណាងក្រុមដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿងនេះ។ ខ្ញុំមានសំណួរមួយចំនួនខ្លីទេដើម្បីសួរលោកស្រី។ ជាដំបូងខ្ញុំចង់សួរថាលោកស្រីស្គាល់ឈ្មោះ ព្រំ យ៉ាន់ ទេ? គាត់រស់នៅក្នុងភូមិជាមួយលោកស្រីដែរ គឺភូមិឈើភ្លើង គាត់ឈ្មោះ ព្រំ យ៉ាន់។

**លោកស្រី អ៊ុន យឿង៖**

**ឆ៖** ខ្ញុំបានស្គាល់ច្បាស់ណាស់ នៅដើរមុខផ្ទះខ្ញុំរាល់ថ្ងៃ គាត់សុំមក។ គាត់ថា៖ "មីអូនឯង មិនបាច់សម្លាសបានឆ្អិនដូចអ៊ំទេ អ៊ំបានសម្លាសឆ្អិន ព្រោះអ៊ំអ្នកបាននិយាយច្បាស់។" ព្រឹកមិញក៏គាត់សុំមកដែរ គាត់ថា បើសុំឲ្យគាត់សុំមក សុំនិយាយបកស្រាយឲ្យអង្គការស្តាប់ឲ្យអស់។ បើគាត់និយាយបីថ្ងៃមិនអស់ផង។ តាហ្នឹងក៏បានមកថានឹងផ្ទះខ្ញុំនៅថ្ងៃសម្លាសហ្នឹង ហើយព្រឹកមិញមកក៏គាត់ថា៖ "មីអូនមិនបាច់ទៅទេ ទុកឲ្យអ៊ំទៅ អ៊ំបានៗសម្លាសច្បាស់ តែអ្នែងគ្រាន់តែបានស្តាប់ស្រពេចស្រពិលអ៊ីចឹងអត់បានច្បាស់ទេ អង្គការមិនដឹងយកធ្វើជាគោលដៅអីទេ។" គាត់បានថាអ៊ីចឹងដែរព្រឹកមិញ។

[១៤:៣៣:៣៩]

**ស៖** សូមអរគុណលោកស្រី។ លោកស្រីស្គាល់បុរសម្នាក់ឈ្មោះ ទេព ទេ នៅក្នុងឃុំរបស់លោកស្រី? គាត់ជាអ្នកឃុំជាមួយលោកស្រី គាត់រៀបការជាមួយស្ត្រីម្នាក់ដែលជាជនជាតិវៀតណាមពាក់កណ្តាល។ លោកស្រីស្គាល់ឈ្មោះ ទេព ហ្នឹងទេ?

**ឆ៖** អត់បានស្គាល់ទេ។ ឈ្មោះ ទេព ហ្នឹងអត់ស្គាល់តែម្តង។ អត់ស្គាល់ ឈ្មោះអត់ស្គាល់តែម្តង។ បើ តាព្រំ យ៉ាន់ ហ្នឹងបានៗស្គាល់ច្បាស់។ បើ ទេព ហ្នឹងអត់ស្គាល់សោះតែម្តង។

**ស៖** សូមអរគុណលោកស្រី។ ខ្ញុំសូមដកស្រង់នូវចម្លើយរបស់ ព្រំ យ៉ាន់ ពាក់ព័ន្ធនឹងឈ្មោះ ទេព និងប្រពន្ធរបស់គាត់។ ខ្ញុំសូមអាននូវសំណួរទី១ នៃឯកសារ E3/7816 គឺសំណួរទី១ តែម្តងនៅក្នុងភាសាទាំងពីរ គឺអង់គ្លេស និងខ្មែរ មិនមានជាភាសាបារាំងទេ។ ព្រំ យ៉ាន់ ដែលលោកស្រីស្គាល់នេះ គាត់

បានឆ្លើយដូចតទៅ៖ "នៅឆ្នាំ១៩៧៧ ខ្ញុំបានឃើញ--

**ប្រធានអង្គជំនុំ៖**

ផ្អាកៗ! ផ្អែកឯកសារនុំងមាន បើផ្អែក បើយោងឯកសារ ឱ្យយោងលេខ និងហើយនិងអត្តសញ្ញាណឯកសារ និងលេខ ERN ច្បាស់លាស់ផង។

អញ្ជើញលោកស្រីៗមេធាវីការពារក្ដីលោក ខៀវ សំផន!

[១៤:៣៥:៤១]

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអភ័យទោសដែលខ្ញុំកាត់ផ្ដាច់។ ឯកសារនេះ មានជាភាសាបារាំងទេតើ លោកស្រីមេធាវី។ បើសិនជាមិនមាន ខ្ញុំអាចផ្ដល់ជូនបាន មានជាភាសាបារាំងគឺERN00339874 នៃឯកសារ E3/7816។ អ៊ីចឹងសូមមន្ត្រីតុលាការប្រគល់ឯកសារជាភាសាបារាំង ទៅឱ្យមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី ដើម្បីកុំឱ្យគាត់មានការលំបាក។

**សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

**ស៖** សូមអរគុណមេធាវី។ ខ្ញុំបានបញ្ជាក់ហើយថា សំណួរចម្លើយទី១ នៃគ្រប់ភាសាតែម្ដង។ អ៊ីចឹងERNគឺ 00277273 ជាភាសាខ្មែរ, 00292838 ជាភាសាអង់គ្លេស ហើយនិងជាភាសាបារាំង 00339874។ លោកស្រីសាក្សី ព្រុំ យ៉ាន់ បានផ្ដល់បទសម្ភាសន៍ជូនការិយាល័យសហចៅក្រមស៊ើបអង្កេត គាត់ថា៖ "នៅឆ្នាំ១៩៧៧ ខ្ញុំបានឃើញស្ត្រីកូនកាត់វៀតណាម (ភ្លេចឈ្មោះ) ដែលមានប្ដីឈ្មោះ ទេព ស្លាប់កាលពី៣ឆ្នាំមុននេះ ព្រមទាំងកូនម្នាក់ត្រូវបានយោធាស្រុកចាប់យកទៅបាត់រហូត។ យោធាស្រុក មិនស្គាល់ឈ្មោះចំនួនបីនាក់ បានភ្ជង់កាំភ្លើងស្ត្រីនោះ នៅម្ដុំភូមិខ្នាលោត ឃុំកំពង់ត្រាច ស្រុករមាសហែក ខេត្តស្វាយរៀង បង្ខំឱ្យដើរទៅទិសខាងមន្ទីរស្រុករមាសហែក ស្ថិតនៅភូមិព្រៃដំឡូង ឃុំកំពង់ត្រាច ស្រុករមាសហែក ខេត្តស្វាយរៀង។ ខ្ញុំមិនបានដឹងអំពីអ្វីដែលបានកើតឡើងចំពោះគ្រួសារវៀតណាមផ្សេងទៀតទេ។"

ខ្ញុំអានសម្រង់នេះ ឱ្យលោកស្រីស្ដាប់ លោកស្រីសាក្សី ដើម្បីចង់ដឹងថាតើរឿងរ៉ាវដែល ព្រុំ យ៉ាន់ បានរៀបរាប់នេះ ពាក់ព័ន្ធនឹងឈ្មោះ ទេព នេះ ធ្វើឱ្យលោកស្រីនឹកឃើញអ្វីឡើងវិញខ្លះទេ ឬក៏លោកស្រីភ្លេចអស់ហើយ មិនចាំអ្វីទាំងអស់?

[១៤:៣៨:១៣]

**លោកស្រី អ៊ិន យឿង៖**

**ឆ៖** បានឮច្បាស់មែន។ គាត់នុំងជាចិនកាត់ មិនមែនជាវៀតណាមទេ។ គេយកទៅព្រៃចក សម្លាប់ចោលមែន។ គាត់នៅខ្លាលោត ប្រពន្ធ តាសឿន ប្រពន្ធប្រធាន សឿន។ គាត់នៅខ្លាលោត ហើយ ទៅយកៗប្តី យកប្តីខ្មែរ ហើយគាត់នុំងចិនកាត់។ គេបានយកគាត់ទៅសម្លាប់មែន នៅព្រៃចកមែន។ ខ្ញុំ បាន អ៊ីចឹងបានដឹងច្បាស់ថា ព្រំ យ៉ាន់ ហ្នឹងបានថាអ៊ីចឹងមែន ថានៅផ្ទះខ្ញុំ។ ហើយតែខ្ញុំហ្នឹង ក៏ឮគាត់ថា អ៊ីចឹង ក៏ខ្ញុំថាតាមគាត់អ៊ីចឹងដែរ។

**ស៖** លោកស្រីនិយាយថា កូនកាត់ចិន ក៏ប៉ុន្តែសំណួរខ្ញុំហ្នឹងវាពាក់ព័ន្ធទៅនឹងកូនកាត់វៀតណាម ដែលរៀបការជាមួយឈ្មោះ ទេព – ប្តីគាត់ឈ្មោះ ទេព ជាខ្មែរ។ លោកស្រីដឹងរឿងហ្នឹងទេ ស្ត្រីកូនកាត់ វៀតណាម មិនមែនកូនកាត់ចិនទេ?

**ឆ៖** មិនមែនកូនកាត់ចិនទេ កូនកាត់វៀតណាមមែន កូនកាត់យកខ្មែរ ប្រពន្ធយួន ប្តីខ្មែរ។ គេ បានយកគាត់ទៅសម្លាប់មែន គាត់ឃើញច្បាស់ គាត់ថាអ៊ីចឹងមែន។

**ស៖** ចុះស្ត្រីកូនកាត់ចិនដែលលោកស្រីនិយាយហ្នឹង មានកូនទេ? ហើយគេនាំទាំងកូនទាំងម្តាយ ហ្នឹងទៅមន្ទីរស្រុកទេ? លោកស្រីដឹងរឿងហ្នឹងទេ?

[១៤:៤០:១៤]

**ឆ៖** គេអត់នាំទៅមន្ទីរស្រុកទេ គេនាំទៅព្រៃចក។ តែមិនដឹងគេនាំទៅធ្វើអីទេ ឃើញតែគេនាំ គាត់ទៅមែន តែមិនដឹងធ្វើអីៗ ខ្ញុំមិនបានដឹងដែរ។

**ស៖** ហេតុការណ៍ហ្នឹងលោកស្រីឃើញផ្ទាល់ភ្នែក ឬក៏ ព្រំ យ៉ាន់ ហ្នឹងជាអ្នករៀបរាប់ហេតុ ការណ៍ហ្នឹងប្រាប់លោកស្រី?

**ឆ៖** ព្រំ យ៉ាន់ ហ្នឹងរៀបរាប់ប្រាប់ខ្ញុំ តែខ្ញុំមិនបានឃើញផ្ទាល់ភ្នែកទេ តែ ព្រំ យ៉ាន់ ហ្នឹងមក ស្រែកប្រាប់ផ្ទះខ្ញុំហ្នឹង ប្រាប់អ្នកបងកត់ក្តីហ្នឹង ព្រំ យ៉ាន់ អ្នកស្រែក ប្រាប់ច្បាស់អ៊ីចឹង។

**ស៖** តើ ព្រំ យ៉ាន់ ហ្នឹងប្រាប់លោកស្រីផ្ទាល់ថា ស្ត្រីហ្នឹងជាកូនកាត់ចិន ឬក៏លោកស្រីដឹងរឿង ស្ត្រីកូនកាត់ចិនហ្នឹងមុនពេលពិភាក្សា ឬក៏ជជែកគ្នាជាមួយ ព្រំ យ៉ាន់ ហ្នឹងទៅទៀត?

**ឆ៖** គាត់បានមកនិយាយផ្ទះខ្ញុំ គាត់ជជែកពីរឿងកូនកាត់វៀតណាមហ្នឹង មកជជែកប្រាប់ថា គេយកគាត់ទៅព្រៃចក គាត់មកស្រែកប្រាប់នឹងផ្ទះខ្ញុំថាអ៊ីចឹង។

**ស៖** ដើម្បីយល់ឲ្យច្បាស់អំពីចម្លើយរបស់លោកស្រី អ៊ីចឹងមានន័យថា មនុស្សពីរនាក់ គឺស្ត្រី

កូនកាត់ចិន ហើយនិងកូនវៀតណាមម្នាក់ដែលត្រូវនាំទៅព្រៃចក មានន័យអ៊ីចឹងមែនទេ?

**ឆ៖** គេនាំម៉ែវាទៅមុន ហើយដល់កូនមួយនៅជាមួយឪពុកវាហ្នឹង គេបានយកទៅក្រោយ។

**ស៖** អ៊ីចឹងលោកស្រីចាំច្បាស់ទេថា ព្រំ យ៉ាន់ ហ្នឹងប្រាប់លោកស្រីថាកូនហ្នឹងជាកូនវៀតណាម មែនទេ?

[១៤:៤៣:១០]

**ឆ៖** គេថាកូនកាត់ៗ ខ្ញុំមិនបានឃើញផ្ទាល់នឹងភ្នែកទេ ដែលគាត់ហ្នឹងបានឃើញផ្ទាល់នឹងភ្នែករបស់គាត់ បានគាត់មកឆ្លើយប្រាប់មេធាវីនៅផ្ទះខ្ញុំអ៊ីចឹង។ តែខ្ញុំមិនបានឃើញច្បាស់ទេ តែគាត់ គាត់ឃើញច្បាស់។ គាត់មកឆ្លើយប្រាប់ថា គាត់ឃើញ គាត់បាន ឃើញគាត់បានថា។

**ស៖** ដើម្បីបំភ្លឺចំណុចនេះ ព្រំ យ៉ាន់ ត្រូវបានគេសម្លាសអំពីហេតុការណ៍នេះ។ អ៊ីចឹងលោកស្រីចង់បញ្ជាក់ថា ព្រំ យ៉ាន់ ហ្នឹងគេសម្លាសដែរមែនទេ នៅពេលដែលគេសម្លាសប្ដីលោកស្រីនោះ?

**ឆ៖** ពេលសម្លាសប្ដីខ្ញុំ ព្រំ យ៉ាន់ ហ្នឹងមក អ្នកសម្លាសនៅនឹងផ្ទះខ្ញុំតែម្ដង។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

លោកប្រធាន ខ្ញុំសូមបញ្ចប់អំពីហេតុការណ៍នេះ ហើយខ្ញុំមានសំណួរមួយចំនួនតូចទៀតពាក់ព័ន្ធទៅនឹងចម្លើយដែលលោកស្រីសាក្សីបានឆ្លើយជូនសហព្រះរាជអាជ្ញា ពាក់ព័ន្ធនឹងការរៀបអាពាហ៍-ពិពាហ៍នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ ខ្ញុំត្រូវការប្រហែលជា១០នាទីទៀត លោកប្រធាន។ អ៊ីចឹងខ្ញុំអាចបន្ត ឬក៏ត្រូវឈប់សម្រាកសិនលោកប្រធាន?

[១៤:៤៤:៥១]

**ប្រធានអង្គជំនុំ៖**

បាទ សម្រាកសិនចុះ។ បញ្ហាអ៊ីចេះ ហើយសូមជម្រាបសួរភាគី អង្គជំនុំជម្រះបានជូនដំណឹងតាមរយៈអ៊ីម៉ែលរបស់មន្ត្រីច្បាប់ទៅភាគីរួចហើយអម្បាញ់មិញនេះ អំពីការគម្រោងផែនការនៃការស្ដាប់សារណាភាគីពាក់ព័ន្ធទៅនឹងសំណើសុំរបស់សហមេធាវីការពារក្ដី នួន ជា ចំនួនពីរដែលស្នើសុំឱ្យអង្គជំនុំជម្រះទទួលយកឯកសារមួយចំនួន ដើម្បីខ្លួនហ្នឹងមានមូលដ្ឋាន -- ដាក់ចូលទៅសំណុំរឿង០០២/០២ ហើយនិងមានមូលដ្ឋានក្នុងការតាំងសំណួរដេញដោលចំពោះអ្នកជំនាញ 2-TCE-95 នៅក្នុងសប្ដាហ៍ក្រោយ។ ហើយអង្គជំនុំជម្រះបានជម្រាបជូននុំង គឺបំណងធ្វើនៅថ្ងៃស្អែក ប៉ុន្តែតាមការប្រមើលមើល ការស្ដាប់សក្ខីកម្មសាក្សីរូបនេះ ទំនងជាចប់មុនពេលកំណត់។ ហើយយើងទំនងជាសេសសល់

ពេលខ្លះនៅរសៀលនេះ។ សំណួរសួរថា តើយើងអាច ភាគីពាក់ព័ន្ធនឹងអាចធ្វើសារណាតបទៅនឹងសំណើសុំដែលអង្គជំនុំជម្រះបាន ទើបតែបានជូនថ្មីៗ ដែលទើបតែទទួលបាននូវសំណើសុំរបស់ នួន ជា កាលពីព្រឹកមិញនោះ មួយជាលាយលក្ខណ៍អក្សរ មួយទៀតមិនទាន់មានជាភាសាខ្មែរនៅឡើយទេ ប៉ុន្តែអង្គជំនុំជម្រះសម្រេចដូច្នេះហើយ។ ថាតើអាចធ្វើបានទេ នៅក្រោយពេលបញ្ចប់សក្ខីកម្មសាក្សីរូបនេះ ប្រសិនបើពេលវេលានៅសេសសល់?

តំណាងសហព្រះរាជអាជ្ញា? យល់ទេ ឥឡូវហ្នឹងបញ្ហាអង្គជំនុំជម្រះជម្រាបជូនហើយថា បំណងស្តាប់នូវសារណាផ្ទាល់មាត់ ពាក់ព័ន្ធនឹងសំណើសុំចំនួនពីរ របស់មេធាវីការពារក្តី នួន ជា សុំឱ្យទទួលយកឯកសារជាភស្តុតាងដាក់ចូលទៅក្នុងសំណុំរឿង០០២/០២ ហើយនិងមានបំណងយកឯកសារទាំងនោះ ជាមូលដ្ឋានសួរដេញដោលសាក្សីអ្នកជំនាញ 2-TCE-95 នៅសប្តាហ៍ក្រោយ ប៉ុន្តែដោយសារទំនងជាការស្តាប់សក្ខីកម្មសាក្សីរូបនេះ បានចប់មុនពេល។ សំណួរសួរថា តើអាចធ្វើសារណាបានទេលើបញ្ហានេះ នៅបន្ទាប់ពីការបញ្ចប់សក្ខីកម្មសាក្សីរូបនេះ នៅរសៀលនេះ ប្រសិនបើចប់មុនពេល?

[១៤:៤៧:៤៤]

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។ យើងបានទទួលសំណើនេះកាលពីម្សិលមិញ ដំបូងអង្គជំនុំជម្រះគ្រោងឆ្លើយតបស្អែក ក៏ប៉ុន្តែដោយសារតែបន្តិចទៀតនេះ យើងមានពេលសម្រាក អ៊ីចឹងខ្ញុំប្រហែលជាអាចឱ្យសហការីខ្ញុំគ្នាខ្ញុំអាចឆ្លើយតបទៅនឹងសំណើនេះបានលោកប្រធាន នៅពេលចប់សក្ខីកម្មរបស់សាក្សីរូបនេះ។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ យើងបានត្រៀមធ្វើនៅព្រឹកស្អែក ក៏ប៉ុន្តែមិនជាបញ្ហាអ្វីទេ យើងអាចត្រៀមពេលសម្រាកបន្តិចទៀតនេះបានលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ មិនបញ្ហាអីទេ អ៊ីចឹងគឺឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពេលនេះតទៅរហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សីដល់សាក្សីរូបនេះ នៅក្នុងអំឡុងពេលសម្រាក និងឱ្យអញ្ជើញគាត់រួមទាំងបុគ្គលិកអង្គការ ធី.ភី.អូ មក

កាន់កន្លែងផ្តល់សក្ខីកម្មក្នុងបន្ទប់សវនាការនេះវិញ នៅវេលាម៉ោងបី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៤៨ នាទី ដល់ម៉ោង ១៥:០៩ នាទី)*

[១៥:០៩:១១]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយផ្តល់វេទិកាជូនទៅក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីបន្តការតាំងសំណួរដេញដោលរបស់ខ្លួនចំពោះសាក្សី។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

**ស៖** លោកស្រីសាក្សី នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ តើលោកស្រីមានបានរៀបការទេ? គឺចន្លោះពីឆ្នាំ៧៥ ទៅដល់៧៩ លោកស្រីមានបានរៀបការទេ?

**លោកស្រី អ៊ិន យឿង៖**

**ឆ៖** ខ្ញុំបានរៀបការអង្កាល់នៅឆ្នាំ ចុងឆ្នាំ៧៧។ បានរៀបការនៅក្នុងឆ្នាំ៧៧ ខ្ញុំបានរៀបការ។

[១៥:១០:២១]

**ស៖** សូមអរគុណ។ ពេលលោកស្រីរៀបការហើយ លោកស្រីនៅបន្តនៅក្នុងកងចល័តទៀត ឬក៏យ៉ាងណា?

**ឆ៖** ចាស រៀបការហើយមិននៅបន្តក្នុងកងចល័ត គេបញ្ជូនមកសហករណ៍។ មិនបានមកតនៅកងចល័តទេ គេរំសាយមកតាមសហករណ៍។

**ស៖** ដូច្នេះការរស់នៅ និងរបបហូបចុកមានលក្ខណៈល្អប្រសើរជាងមុនមែនទេនៅពេលដែលលោកស្រីទៅសហករណ៍នោះ?

**ឆ៖** ពេលទៅសហករណ៍ហ្នឹង របបហូបចុកដូចថា វាបានច្រើនជាងនៅតាមកងចល័ត។ សហករណ៍គេផ្តល់ឲ្យហូបបាន ដូចថាវាល់ទៅវារាងច្រើនតិច។

**សៈ** លោកស្រីស្គាល់ប្តីលោកស្រីមុនថ្ងៃរៀបការទេ?

**ឆ៖** ខ្ញុំបានស្គាល់គាត់នៅធ្វើកងចល័តនៅម្រាមខាងលិចនោះ គាត់នៅប្រចាំការខាងធ្វើត្រី។

**សៈ** លោកស្រីចាំទេ ពេលថ្ងៃដែលលោកស្រីរៀបការនៅឆ្នាំ១៩៧៧ហ្នឹងមានប៉ុន្មានគូដែរ? មានតែលោកស្រីមួយគូទេ ឬក៏មានគូផ្សេងទៀត?

**ឆ៖** ការមួយគូទេ។ ការច្រើនគ្នា មិនមែនគូទេ នៅចុងឆ្នាំ៧៧ហ្នឹង ការច្រើនគ្នាដែរ អង្គាល់ដើមឆ្នាំការច្រើន ដល់ចុងឆ្នាំ៧៧ហ្នឹងការខ្ញុំបង្ហើយក្រោយគេហើយ។

**សៈ** លោកស្រីដូចជាចាំច្បាស់អំពីពេលដែលលោកស្រីរៀបការនៅចុងឆ្នាំ៧៧។ លោកស្រីអាចជម្រាបបានទេ នៅថ្ងៃរៀបការលោកស្រីមានអារម្មណ៍បែបណាដែរ?

[១៥:១៣:០៥]

**ឆ៖** ថ្ងៃរៀបការ ខ្ញុំមានអារម្មណ៍ថា មិនសូវបានឃើញមុខគ្នាច្បាស់ទេ ប៉ុន្តែថាអង្គការគាត់ថាការទៅៗ តែខ្ញុំមិនបានឃើញគាត់ច្បាស់ទេ ឃើញគាត់ម្តងៗ។ ប៉ុន្តែអង្គការគេថាការទៅៗ ខ្ញុំក៏ការទៅតាមគាត់ទៅ។

**សៈ** លោកស្រីអាចប្រកែកមិនព្រមរៀបការតាមបញ្ជារបស់អង្គការបានទេ?

**ឆ៖** ខ្ញុំអាចប្រកែកបានទេ ថាគាត់ឲ្យការៗតែម្តង ទោះបីស្រឡាញ់មិនស្រឡាញ់ ក៏ខ្ញុំការដែរ ទោះយ៉ាងណាគេឲ្យការខ្ញុំការហើយ ខ្ញុំក្រោមបញ្ជាគេដែរ ខ្ញុំស្រឡាញ់ មិនស្រឡាញ់ ក៏ការដែរ។

**សៈ** ក្នុងកងចល័តរបស់លោកស្រីមានអ្នកណាប្រកែកមិនព្រមរៀបការទេ?

**ឆ៖** អត់មានពីណាប្រកែកទេ ឲ្យអង្គការឲ្យការ ការទាំងអស់តែគ្នាទៅ ច្រើនគូ ៥០គូ, ២០គូ, ៣០គូ ចេះតែការបន្តបន្ទាប់គ្នាទៅ។ ដល់បានច្រើនហ្នឹង គេដាក់នៅតាមសហករណ៍ហ្នឹងគេបញ្ជូនទៅលិច បន្ទាប់ៗគ្នាទៅ។

**សៈ** ចុះលោកស្រី បើសិនជា -- ក្នុងករណីលោកស្រីប្រកែកមិនព្រមរៀបការ លោកស្រីខ្លាចអីបានជាមិនហ៊ានប្រកែក?

**ឆ៖** ខ្ញុំមិនហ៊ានប្រកែកទេ ខ្លាចគេយកទៅស្វាយទន្ទឹម។ អង្គាល់ហ្នឹង គេថាតែមិនការមានមុខយកទៅណាទេ មានតែយកទៅស្វាយទន្ទឹមដែលណែនាំ ជម្រៅជ្រៅជ្រះឲ្យដឹង។

**សៈ** ស្វាយទន្ទឹមហ្នឹង ស្អីគេដែរលោកស្រី?

**ឆៈ** ស្វាយទន្ទឹមៗ ឃើញតែគេយកទៅ មិនដឹងកន្លែងអីគេទេ គេថាតែមិនយក បើមិនការហ្នឹង មានតែយកទៅដឹកនាំឯនុ៎ង ហើយខ្ញុំក៏ខ្លាចទៅ។ ទៅកន្លែងមួយៗ ខ្ញុំខ្លាចណាស់ ខ្ញុំទោះស្រឡាញ់ មិនស្រឡាញ់ ក៏ខ្ញុំការដែរ ចេះតែតាមគាត់ទៅ។

[១៥:១៥:៥៥]

**សៈ** លោកស្រីដឹងទេ ចំពោះអ្នកដែលប្រកែកមិនព្រមរៀបការហ្នឹង តើគេធ្វើយ៉ាងម៉េច? ហើយពេលគេនាំយកទៅស្វាយទន្ទឹមហ្នឹង ហើយគេធ្វើយ៉ាងម៉េចទៀត?

**ឆៈ** រៀបការ អ្នកដែលមិនព្រមរៀបការហ្នឹងគេយកទៅអប់រំនៅកន្លែងឃុំសិន បើព្រមការ គេការ បើមិនព្រមការ បានគេយកទៅនុ៎ងទៀត។ គេយកទៅពីរដំណាក់។

**សៈ** លោកស្រីចាំទេ អ្នកណាជាអ្នកដឹកនាំពិធីរៀបការរបស់លោកស្រីហ្នឹង?

**ឆៈ** ខ្ញុំមិនបានស្គាល់ទេ ប៉ុន្តែគេធ្វើការនៅឃុំ ឃើញគេធ្វើការចុះឡើងៗគេសម្រាប់មកដឹកនាំអ្នកការៗហ្នឹង ឲ្យឡើងលើតុ ប្ដេជ្ញាទាំងគូៗទៅ។ គេមិនបានប្រាប់ឈ្មោះគេទេ ប៉ុន្តែឃើញគេធ្វើការនៅឃុំកំពង់ត្រាចនុ៎ង ទៅមកៗ រាល់ថ្ងៃហ្នឹងគេអ្នកចាត់ចែងរឿងការជាគូៗអីចឹង។ ខ្ញុំឃើញគេច្បាស់នៅតែនុ៎ងដែរ គេមិនដឹង គេធ្វើការអីៗ ខ្ញុំអត់បានដឹងដែរ។

**សៈ** តើលោកស្រីមានបានផ្សំដំណេកជាមួយប្ដីលោកស្រីទេ នៅបន្ទាប់ពីការហើយយប់ នៅពេលយប់នោះ?

**ឆៈ** បន្ទាប់ពីការហើយនៅយប់នោះ គេបញ្ជូនមកតាមសហករណ៍ហ្នឹង ដែលយប់គ្មានបានផ្សំដំណេកទេ យប់នុ៎ងវាបែកគ្នា គាត់ទៅផ្ទះម៉ែគាត់ ខ្ញុំមកផ្ទះម៉ែខ្ញុំ។ គ្មានបានផ្សំដំណេកទេយប់នុ៎ង។

**សៈ** តើគេមានបង្គាប់ដាច់ខាតឲ្យរួមដំណេកជាមួយគ្នាទេខ្មែរក្រហម ឬក៏មេកងចល័តលោកស្រីហ្នឹង មានបានប្រាប់ថាការហើយត្រូវតែរួមដំណេកទេ?

[១៥:១៨:២៥]

**ឆៈ** ប្រាប់ គេបានប្រាប់ថា ត្រូវតែរួមដំណេកគ្នា បើមិនរួមដំណេកគ្នា គេយកទៅដាក់កន្លែងឃុំឲ្យដេកជាមួយគ្នា គេតាមដានមើលយើងហ្នឹងទៀត ទាល់តែយើងថាបានទៅរួមដំណេកគ្នាហើយ បានគេឲ្យមកវិញ។

**សៈ** គេមានបានពន្យល់ទេ ថាហេតុអីបានជាលោកស្រីត្រូវរៀបការ? ហើយហេតុអីបានជា

ក្រោយពីរៀបការហើយ ត្រូវតែរួមដំណេកជាមួយគ្នា?

**ឆ៖** គេថាឲ្យបានស្គាល់ជាតិបន្តិចចុះ ឲ្យបានប្រញាប់បញ្ជូនទៅលិច គេថាអ៊ីចឹងដែរ ដែលតាមៗស្តាប់មើល លបស្តាប់មើលគេនិយាយហ្នឹង គេថាឲ្យស្គាល់ជាតិបន្តិចចុះ នឹងអាលបញ្ជូនទៅលិច គេថាអ៊ីចេះ។ ខ្ញុំក៏បានឮអ៊ីចឹងដែរ ឮផ្ទាល់ខ្លួនឯងថាអ៊ីចឹងដែរ។ ហើយខ្ញុំចេះតែធ្វើតាមៗគេទៅ បើមិនធ្វើតាមគេ ខ្ញុំខ្លាចស្លាប់ ខ្ញុំចេះតែធ្វើតាមទៅ គេថាម៉េចធ្វើអ៊ីចុងគេៗទៅ។ ចាំតែអស់កិត្តិយសយ៉ាងម៉េចក៏ដោយ គេថាយ៉ាងម៉េចធ្វើអ៊ីចុងគេទៅ ឲ្យតែរួចខ្លួនទៅ។

**ស៖** លោកស្រីមានកូនទេ ជាមួយប្តីដែលលោកស្រីការនៅចុងឆ្នាំ៧៧ហ្នឹង?

**ឆ៖** ខ្ញុំការហើយបានយូរដែរ បានមានកូន ទម្ងន់ពោះ៣ខែ គេបញ្ជូនទៅលិចហ្នឹង ទម្ងន់ពោះ៣ខែហើយខ្ញុំ។ តែៗខ្ញុំទៅក្រោយគេនុ៎ង ខ្ញុំអត់ទៅធ្វើទៅតែម្តងទេ គឺខ្ញុំទៅដល់តែកន្លែងភ្លឺអាងហ្នឹង ខ្ញុំត្រឡប់មកក្រោយវិញ ព្រោះខ្ញុំឈឺ ខ្ញុំអត់បានទៅ ដើរទៅដល់ទេ ឯកន្លែងគេហៅពោធិ៍សាត់ បាត់ដំបងនុ៎ង ព្រោះខ្ញុំទៅដល់តែភ្លឺអាងបឹងទុំហ្នឹង ខ្ញុំចុះដើរមកវិញ ខ្ញុំភូតថា ខ្ញុំទៅបត់ជើងហើយ។ អ្នកគេបណ្តើរគេថា៖ "ទៅណា? ខ្ញុំថា៖ ទៅបត់ជើងហើយ។" ទៅបត់ជើង ហើយប្តីខ្ញុំហួសពីគេប្រហែល១០ម៉ែត្រហ្នឹង គាត់ចុះទៅបត់ជើងតូចដែរ។ ហើយដល់បត់ជើងហ្នឹង មិនមែនទៅបត់ជើងទេ តែខ្ញុំរត់ទេ ខ្ញុំរត់ត្រឡប់មក--។

[១៥:២១:១០]

**ស៖** លោកស្រីមានកូនហ្នឹង គឺក្នុងរបបខ្មែរក្រហម មែនទេ គឺមុនពេលវៀតណាមវាយចូលនៅឆ្នាំ៧៩ មែនទេ?

**ឆ៖** មុន។ ខ្ញុំមានកូនទម្ងន់៣ខែ បានខ្ញុំថាមិនទៅទេ ឆ្ងាយណាស់ ខ្ញុំសុខចិត្តត្រឡប់មកវិញ ព្រោះម៉ែខ្ញុំគាត់ផ្លាស់ទៅអស់ហើយ បងអីផ្លាស់ទៅអស់ហើយ នៅសល់តែប្តីខ្ញុំមួយហ្នឹង ខ្ញុំថាមិនទៅទេ ទោះបីយ៉ាងណាក៏ខ្ញុំត្រឡប់មកវិញដែរ ខ្ញុំអត់ទៅតែម្តង។

**ស៖** ពេលលោកស្រីនិយាយថា ត្រឡប់មកវិញហ្នឹង គឺលោកស្រីត្រឡប់មកភូមិកំណើតវិញ ឬក៏យ៉ាងម៉េច ឬក៏ត្រឡប់ទៅកន្លែងណា?

**ឆ៖** ពេលត្រឡប់មកវិញហ្នឹង ខ្ញុំរត់ អត់ទាន់ដល់ផ្ទះទេ ខ្ញុំរត់កាត់គ្រោក កាត់ព្រៃ កាត់ផ្សារហ្នឹង ប្តីរត់ផ្សេង ប្រពន្ធរត់ផ្សេង។ រត់ៗៗទៅ ដល់ភូមិគេស្ងាត់ យប់ហ្នឹងខ្ញុំចូលដេកតាមសៀរបងគេ ខ្ញុំអត់ហ៊ានចូលដេកផ្ទះគេទេ ខ្លាចគេចាប់វាយអារកចោល។ ដល់ហើយក៏ឈប់ដេកហ្នឹងទៅ។ ដល់ឈប់ដេកទៅ

ទៅដល់មួយយប់ទៀត បានទៅដល់សហករណ៍វិញ កន្លែងចាស់វិញ។ ដល់សហករណ៍កន្លែងចាស់វិញ គេថា របបដែលឲ្យទៅ ទៅហើយ គ្មានរបបណានៅហូបបាយក្រោយទៀតទេ។ ហើយខ្ញុំក៏អត់ទ្រាំថា គេឲ្យហូបមិនហើយក៏ដោយ ម៉ែគាត់ចេះតែច្បិចឲ្យបន្តិចៗទៅ។ ហើយចេះតែធ្វើការឲ្យគេទៅ ចេះតែធ្វើការទៅ យូរៗទៅ គេអាណិតទៅ គេឲ្យហូបបន្តិចៗទៅ ហូបបានវៀតណាមហ្នឹងទៅ យូរៗទៅ វៀតណាមទៅរំដោះមកពីពោធិ៍សាត់ បាត់ដំបងហ្នឹង ក៏បានសម្បូរសប្បាយទៅ មកបាន -- វារាងមានកម្លាំងឡើងវិញ។

**ស៖** សូមអរគុណលោកស្រីសាក្សី។ សំណួរចុងក្រោយ តើលោកស្រីចាំច្បាស់អំពីពិធីរៀបការនុំងទេ? ហើយពេលរៀបការហ្នឹង លោកស្រីមានឡើងប្ដេជ្ញាអ្វីទេ? ហើយប្រសិនជាឡើងប្ដេជ្ញាមែននុំង លោកស្រីបាននិយាយអ្វីខ្លះ ក្នុងពេលនោះ?

**ឆ៖** ខ្ញុំបានឡើងប្ដេជ្ញាមែនថា ប្ដេជ្ញាចិត្តយកប្ដីខ្ញុំអស់មួយជីវិត មិនៗងាករេទេ។ បានឲ្យឡើងប្ដេជ្ញាចិត្តអ៊ីចឹង តែមួយម៉ាត់ហ្នឹង ខ្ញុំក៏មិនចេះ ខ្ញុំក៏ឈប់ទៅ។ បានឡើងអី គ្រាន់ថាឡើងប្ដេជ្ញាចិត្ត យកប្ដីខ្ញុំឲ្យអស់មួយជីវិត តែប៉ុណ្ណឹង ខ្ញុំក៏លែងឈប់ត្រឹមហ្នឹងទៅ។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកស្រីសាក្សី ដែលបានឆ្លើយទៅនឹងសំណួររបស់ខ្ញុំ។ លោកប្រធាន ខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្តទៅនេះ អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្ដី។ ហើយដំបូងនេះ សហមេធាវីការពារក្ដីលោក នួន ជា ដើម្បីមានឱកាសសួរដេញដោលចំពោះសាក្សីរូបនេះ ប្រសិនបើមាន។ បាទ សូមអញ្ជើញ!

[១៥:២៤:៣០]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយសហមេធាវីការពារក្ដី**

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ជម្រាបសួរលោកស្រីសាក្សី។ ខ្ញុំមានសំណួរតិចតួចទេ។ ជាសំណួរដែលសួរទាក់ទងទៅ

នឹងការរៀបការរបស់លោកស្រី។ សព្វថ្ងៃនេះ លោកនៅតែយកប្ដីដែលបានរៀបការនៅក្នុងឆ្នាំ១៩៧៧ ហ្នឹងដដែលឬ?

**លោកស្រី អ៊ិន យឿង៖**

**ឆ៖** ខ្ញុំនៅយកបានដល់សព្វថ្ងៃហ្នឹង ខ្ញុំមិនបានលែងទេខ្ញុំយករហូតរបស់ខ្ញុំ រហូតដល់មានកូនមានចៅរាល់ថ្ងៃហ្នឹង។ ខ្ញុំអត់លែងមែន ខ្ញុំយករបស់ខ្ញុំរហូតមែន។

**ស៖** លោកស្រីប្រហែលជាឆ្លើយសំណួរនេះរួចហើយ ក៏ប៉ុន្តែតើក្រោយរៀបការមកហ្នឹង លោកស្រីមានកូនប៉ុន្មាននាក់ដែរ?

**ឆ៖** ខ្ញុំមានកូនបួននាក់។

**ស៖** សំណួរទាក់ទងទៅនឹងសំណួរសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី លោកស្រីបានឆ្លើយថា ព្រំ យ៉ាន់ បានទៅសម្លាសនៅផ្ទះរបស់លោកស្រី។ តើត្រឹមត្រូវដែរទេ?

**ឆ៖** ខ្ញុំបានដឹងត្រឹមត្រូវ ខ្ញុំអត់មានភូតកុហកអីទេ តាយ៉ាន់ គាត់នៅថារាល់ថ្ងៃ គាត់ថា បើគាត់មកបានស្រេច តែអូនឯងមកមិនស្រេចទេ។ គាត់ថាព្រឹកមិញ ខ្ញុំមក ខ្ញុំលាគាត់ដែរ។ តាទៅហើយតា ចាំគេយកគាត់ គាត់មក។

[១៥:២៦:៤០]

**ស៖** ហើយនៅពេលដែលគេសម្លាស ព្រំ យ៉ាន់ នៅក្នុងផ្ទះរបស់លោកស្រី តើនៅពេលនោះឬដែលលោកស្រីបានឮពីរឿងរ៉ាវរបស់ឈ្មោះ ទេព នោះ?

**ឆ៖** ទេព នោះក្រែងតែបងប្អូន តាយ៉ាន់ មិនដឹង។ បើខ្ញុំអត់មានទេ បងប្អូនខ្ញុំគ្មានឈ្មោះ ទេពទេ។ ក្រែង តាព្រំ យ៉ាន់ នោះមិនដឹង ទេព១ ខ្ញុំមិនបានដឹងដែរ ក៏មិនបានស្គាល់ដែរ។

**ស៖** ឥឡូវខ្ញុំសួរតាមរបៀបនេះវិញ។ មុននេះលោកស្រីត្រូវបានសួរ ស្ត្រីខ្មែរដែលមានឈាមជ័រជាវៀតណាម និងចិន ដែល ព្រំ យ៉ាន់ ជាអ្នកបានរៀបរាប់ តើលោកស្រីដឹងរឿងនេះ តាមរយៈគេសម្លាស ព្រំ យ៉ាន់ នៅផ្ទះលោកស្រីហ្នឹង ឬក៏លោកស្រីដឹងរឿងនេះ តាំងពីមុនសម្លាសនោះ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

លោកប្រធាន មេធាវីការពារក្តីដូចជាសួរនាំមុខហើយ ពីព្រោះថា មិនមែនជាការសម្លាស ព្រំ យ៉ាន់ នៅផ្ទះរបស់គាត់ទេ គឺពេលនោះគេសម្លាសប្តីរបស់សាក្សី ហើយគ្រាន់តែ ព្រំ យ៉ាន់ គាត់នៅក្បែរហ្នឹង ហើយគាត់គ្រាន់តែឆ្លើយលូកមាត់តែប៉ុណ្ណោះ។ ហើយ ព្រំ យ៉ាន់ នោះបាននិយាយអំពីកូនកាត់វៀតណាមទេ ហើយសាក្សីរូបនេះ គាត់និយាយអំពីស្ត្រីកូនកាត់ចិន។ អ៊ីចឹងវាមនុស្សពីរនាក់ផ្សេងគ្នា មិនមែន ព្រំ យ៉ាន់ ហ្នឹងជាអ្នកប្រាប់រឿងហ្នឹងទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

ប្រហែលជាសហព្រះរាជអាជ្ញារងមិនស្តាប់ខ្ញុំទេមើលទៅ។ ខ្ញុំស្តាប់ឮសួរខាងសហមេធាវីនាំមុខសួរថា ព្រំ យ៉ាន់ ហ្នឹងត្រូវបានគេសម្លាសនៅផ្ទះរបស់លោកស្រីសាក្សីនេះ។ អ៊ីចឹងហើយទើបខ្ញុំសួរសំណួរនេះ។ គាត់បានឆ្លើយយ៉ាងដូច្នេះ លោកប្រធាន បានខ្ញុំសួរសំណួរនេះទៅតាមក្រោយ។

[១៥:២៩:១៧]

**ប្រធានអង្គជំនុំ៖**

បាទ សំណួរនេះអាចសួរបាន។ បដិសេធនូវសេចក្តីជំទាស់របស់សហព្រះរាជអាជ្ញារងអន្តរជាតិ។ សាក្សីឆ្លើយតបនូវសំណួរ ប្រសិនបើលោកស្រីនៅចងចាំនូវសំណួរ។

**លោកស្រី អ៊ុន យឿង៖**

**ឆ៖** កូនវៀតណាម កូនខ្មែរប្តីខ្មែរហ្នឹង ខ្ញុំថា ព្រំ យ៉ាន់ ហ្នឹងគាត់បានឆ្លើយ តែខ្ញុំមិនបានដឹងទេព្រោះ ព្រំ យ៉ាន់ គាត់មកឆ្លើយច្បាស់អ៊ីចឹងមែន។ គាត់ឆ្លើយហើយ គាត់ឆ្លើយទៀត។ គាត់អ្នកដឹង គាត់អ្នកឮ ហើយខ្ញុំ ខ្ញុំមិនបានដឹងទេ ត្រង់កន្លែងកូនកាត់ហ្នឹង កូនកាត់ កូនចិនហ្នឹង ខ្ញុំអត់បានថាទេ ព្រោះតាយ៉ាន់ ហ្នឹងគាត់ច្បាស់របស់គាត់មែន។ គាត់បាននិយាយស្រែកឃ្វាងៗនៅកន្លែងបងទៅចុះទៅពិនិត្យហ្នឹង។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ហើយ តើនេះជាលើកទី១ឬ ដែលលោកស្រីបានស្តាប់ឮរឿងនេះនៅពេលដែលគេសម្លាសគាត់នៅផ្ទះរបស់លោកស្រី?

**ឆ៖** បើទៅសម្លាសនុំងគាត់មិនខ្លាចអី គាត់ទៅសម្លាសតែម្តង ខ្ញុំបានស្តាប់ឮច្បាស់អ៊ីចឹងតែម្តងព្រោះគាត់ ហៅគាត់មកក៏គាត់មិនថាអ៊ីចឹងដែរឥឡូវ។ គាត់ថារបស់គាត់មែន គាត់មានខ្លាចអីទេ គាត់ថា

គាត់ឃើញច្បាស់ គាត់ថាច្បាស់អ៊ីចឹងតែម្ដង គាត់ថាអ៊ីចឹង។

[១៥:៣០:៥១]

**ស៖** ខ្ញុំយល់ហើយ ក៏ប៉ុន្តែខ្ញុំសួរលោកស្រីនេះ ថានេះជាលើកទី១ឬ ដែលលោកស្រីបានស្ដាប់ឮ សួរ ព្រំ យ៉ាន់ រៀបរាប់អំពីរឿងនេះ?

**ឆ៖** ខ្ញុំភ្លេចហើយ មិនដឹងលើកទី១ មិនដឹងលើកទី២ទេ ព្រោះឮគាត់ថាៗមែន តែលើកទី១ លើកទី២ ខ្ញុំមិនចាំទេ ខ្ញុំភ្លេចហើយ។

**ស៖** សំណួរចុងក្រោយទៅលើប្រធានបទមួយនេះ។ នៅពេលដែលគេសម្លាសគាត់នៅផ្ទះរបស់លោកស្រី តើអ្នកសម្លាសនោះមានតែម្នាក់ឯងទេឬ ឬក៏អ្នកដែលទៅសម្លាស ព្រំ យ៉ាន់ នុ៎ងមានជនបរទេស មានបារាំងទៅជាមួយដែរ?

**ឆ៖** ភ្លេចអស់ហើយ មិនដឹងមានអ្នកណាទៅជាមួយៗទេ ព្រោះខ្ញុំមិនបានចាំទេ ដល់យូរពេកអ៊ីចឹង ខ្ញុំភ្លេច។ ខ្ញុំភ្លេចអស់ហើយ មិនដឹងបារាំង អីមិនដឹងទេ ប៉ុន្តែខ្ញុំវាភ្លេចៗលែងមិននឹកឃើញផង ភ្លេចបាត់តែម្ដង ប៉ុន្តែនឹកឃើញថា តាយ៉ាន់ ថា នឹកឃើញមែន តែបារាំងអីៗទៅ អត់បាននឹកឃើញទេ ភ្លេចបាត់អស់ហើយ។

**ស៖** មិនថ្វីទេលោកស្រី។ សំណួរចុងក្រោយមួយនូវអ្វីដែល តាយ៉ាន់ អាចនិយាយចុងក្រោយនៅពេលសម្លាសនុ៎ង។ តើលោកស្រីនៅនឹកឃើញថា គាត់បាននិយាយអំពីខ្មែរ-ស ដែលដឹកនាំដោយ សូ ផល ជាលេខាស្រុករមាសហែក? លោកស្រីនៅចាំថា លោកស្រីបានឮគាត់និយាយដូច្នេះទេ ថាអ្នកភូមិនុ៎ងបានចូលរួមជាមួយខ្មែរ-ស ដែលដឹកនាំដោយ សូ ផល ដែលជាលេខាស្រុករមាសហែក?

[១៥:៣៣:២០]

**ឆ៖** ឮមែន បានឮថា ស្រែកខ្វងៗមែន តាយ៉ាន់ ហ្នឹងបាននិយាយច្បាស់មែន គាត់អត់មែនភូតទេ គាត់និយាយច្បាស់ ខ្ញុំឮគាត់ស្រែកអ៊ីចឹងមែន។ តែខ្ញុំវាមិនបានចងចាំថ្ងៃណាខែណា ខ្ញុំអត់ចងចាំទេ តែគាត់និយាយៗច្បាស់របស់គាត់មែន។

**ស៖** ហើយថាតើនេះជាលើកដំបូងដែលលោកស្រីឮអំពីខ្មែរ-សនេះ ឮតាមរយៈ សូ ផល ហ្នឹងនិយាយ ឬក៏លោកស្រីដឹងអំពីខ្មែរ-សនេះតាំងពីមុននោះមក?

**ឆ៖** មិនបានដឹងទេ។ ដឹងឮ តាយ៉ាន់ និយាយបានខ្ញុំដឹងទៅ ខ្ញុំមិនបានដឹង ខ្ញុំមិនបានស្ដាប់ ព្រោះខ្ញុំមិនបានដឹងតាមដានអីដែរ ប៉ុន្តែដល់ឮ តាយ៉ាន់ និយាយអ៊ីចឹង ក៏ចេះតែឮតាមតែគាត់និយាយទៅ ខ្ញុំវា

មិនបានដឹងខ្មែរក្រហម ខ្មែរ-សអីទេ ខ្ញុំវាភ្លេចអស់ហើយនោះ។

**ស៖** លោកប្រធាន ខ្ញុំសូមយោងទៅឯកសារពីរគឺ E3/1132 ជាពិសេស ERN អង់គ្លេស 00 548772, បារាំង00807139, ខ្មែរ00160076។ លោកស្រីខ្ញុំសួរសំណួរមួយ ដែលលោកស្រីមិនដឹងទេ អំពីឯកសារនេះ ប៉ុន្តែខ្ញុំយកឯកសារនេះមកយោង ពាក់ព័ន្ធទៅនឹងហេតុការណ៍ដែលកើតនៅថ្ងៃទី២៩ ធ្នូ ឆ្នាំ១៩៧៦។ គ្រាន់តែការរំឭកការចងចាំរបស់លោកស្រី ដែលឯកសារនេះនិយាយដូចតទៅ៖ “នៅថ្ងៃទី ២៤ ធ្នូ ១៩៧៦ នៅពេលយប់ គឺកងវរសេនាតូចវៀតណាមមួយបានចូលមក ហើយបានបាញ់ផ្ដោងមក លើកងទ័ពរបស់យើង នៅជិតវត្តដូងចាស់។ សារី គឺថាដែលជាយុទ្ធជនហ្នឹងយើង គឺត្រូវបានគេបាញ់ សម្លាប់ ជាទាហានមកពីស្រុករមាសហែក។” លោកស្រី តើនៅក្នុងស្រុករបស់លោកស្រីស្រុករមាស ហែកនេះ លោកស្រីធ្លាប់ដែលឮការបាញ់គ្នានេះដែរទេ នៅក្នុងឆ្នាំ១៩៧៦?

[១៥:៣៦:២៦]

**លោក វ៉ាំងសង់ វ៉ាយឌ៍ ដេស្សាឯល៖**

លោកប្រធាន នេះជាបញ្ហាវិធីសាស្ត្រ។ គាត់មិនគួរអានពីសម្រង់ចេញពីឯកសារផ្សេងទៀត ដោយមិនបានសួរសំណួរបើកទេ។ ខ្ញុំមិនយល់ពីវិធីសាស្ត្រអីទេ។ វិធីសាស្ត្រនេះ ធ្វើឲ្យសាក្សីគាត់ទទួល រងនូវឥទ្ធិពលនៃចម្លើយរបស់សាក្សីផ្សេង។ អ៊ីចឹងអង្គជំនុំជម្រះបានហាមឃាត់នូវវិធីសាស្ត្របែបនេះ ហើយ គឺត្រូវសួរសំណួរបើកជាមុនសិន ទើបអានឯកសារជាមុន។ មិនត្រូវយកសក្ខីកម្មខាងក្រៅ ហើយ យកមកអាន ហើយមិនពាក់ព័ន្ធនឹងសាក្សីរូបនេះ ហើយសួរសំណួរដើម្បីឲ្យសាក្សីឆ្លើយទៅតាមអ្វីដែល គាត់ចង់បានទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

មិនជាបញ្ហាអ្វីទេលោកប្រធាន ខ្ញុំរៀបសំណួរឡើងវិញ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកស្រីសាក្សី តើលោកស្រីធ្លាប់ឮថាកងទ័ពវៀតណាមនេះ បានចូលមកក្នុងស្រុករបស់ លោកស្រីនៅក្នុងខែធ្នូ ឆ្នាំ១៩៧៦ ហើយក៏ធ្វើការបាញ់ប្រហារនៅក្នុងស្រុករបស់លោកស្រីហ្នឹងតែម្ដង លោកស្រីធ្លាប់ឮទេ?

**លោកស្រី អ៊ិន យឿង៖**

**ឆ៖** មិនឮទេ។ ក៏មិនបានដឹងដែរ ភ្លេចតែម្ដងខ្ញុំ។

[១៥:៣៧:៤៧]

**ស៖** តើលោកស្រីធ្លាប់ឃើញ ឬធ្លាប់ឮកងទ័ពវៀតណាមបាញ់ផ្លោងកាំភ្លើងធំ? ឧទាហរណ៍ដូចជា នៅពេលដែលលោកស្រីធ្វើការនៅក្បែរៗភូមិហ្នឹង ធ្លាប់ឮសូរកងទ័ពវៀតណាមហ្នឹងបាញ់ផ្លោងចូលមកទេ?

**ឆ៖** ផ្លោងចូលមកតែនៅក្នុងក្រុមកងចល័តហ្នឹង បានបាញ់ផ្លោងចូលមក ចូលមកពីខាងកើតហ្នឹង កន្លែងដូងហ្នឹង បានបាញ់ផ្លោងទៅមកលិច មិនមកដល់ប្រជាជនទេ ដល់តែត្រឹមកងចល័តហ្នឹងដែលកងចល័តជីកប្រព័ន្ធភ្លឺស្រែប្រឡាយហ្នឹង បានៗផ្លោងមកដល់មែនទេ ចេះតែនាំគ្នាខ្លាចៗចេះតែមើលទៅកើត។ ប៉ុន្តែខ្លាចៗហ្នឹង វាមិនសូវបានផ្លោងប៉ុន្មានទេ គេមកឆ្នាក់ម្ដងៗ។ ដូចថាមកផ្លោងមកចូលបន្តិចបន្តួចអ៊ីចឹងទៅ មិនមែនបានខ្លាំងណាស់ណាទេ។

**ស៖** ហើយតើការបាញ់ផ្លោងនេះ ជាការបាញ់ផ្លោងពីសំណាក់កងទ័ពវៀតណាមឬ? ហើយបើមានបាញ់ផ្លោងអ៊ីចឹងមែន តើគេមានបាញ់ផ្លោងហ្នឹងញឹកញាប់ទេ?

**ឆ៖** គេមិនបាញ់ផ្លោងញឹកញាប់ទេ យូរៗម្ដង ដូចថាមួយខែពីរខែទៅបានឆ្នាក់ម្ដង។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកស្រីសាក្សី។ សូមអរគុណលោកប្រធាន អស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

បាទ តទៅនេះផ្ដល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្ដីលោក ខៀវ សំផន។

[១៥:៣៨:៣៤]

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ជម្រាបសួរលោកស្រីសាក្សី ខ្ញុំមានសំណួរខ្លីពីរ ដើម្បីសុំឲ្យលោកស្រីបំភ្លឺ។ ជាដំបូងខ្ញុំសូមណែនាំខ្លួនសិន ខ្ញុំឈ្មោះ អង់តា ហ្គីសសេ។ ខ្ញុំជាសហមេធាវីអន្តរជាតិ ការពារក្ដីលោក ខៀវ សំផន។ អម្បាញ់មិញនេះ នៅពេលដែលលោកស្រីឆ្លើយទៅនឹងសំណួររបស់សហព្រះរាជអាជ្ញា លោកស្រីថា នៅក្នុងកងចល័តរបស់លោកស្រី មានយុវជនស្ម័គ្រចិត្តរៀបការ ដើម្បីអាចទៅរស់នៅតាមសហករណ៍ ពីព្រោះថា នៅសហករណ៍ស្រួលជាងក្នុងកងចល័ត។ ខ្ញុំយល់អ៊ីចឹងត្រឹមត្រូវទេ?

E1/387.1/Old-1

**លោកស្រី អ៊ិន យឿង៖**

**ឆ៖** ចាស ត្រឹមត្រូវហើយ។ ព្រោះនៅៗកងចល័ត វាពិបាក ដល់មកនៅតាមសហករណ៍ គេតាមមូលដ្ឋានវា សហករណ៍គេគ្រាន់បើជាងកងចល័ត។ កងចល័តដូចនៅវាខ្លាំង ដូចថាប្រយុទ្ធក្ដៅទៅបាយទឹកអីដូចថា មិនៗបរិបូរទេ ស្លហូបដូចៗ បើសម្លដូចជ្រូក បើបាយទៅ បបរបិ បបរបៀក បបរបន្ដិចៗ វាមិនសូវមានកម្លាំងទេ។ ធ្វើការអីដូចថា ធ្វើដោយពិបាក ធ្វើទាំងហេវ ទាំងហត់ ទាំងពិបាកទៅទេ នៅកងចល័តនុ៎ង វាពិបាកមឹតមែនទែននុ៎ង។

**ស៖** សំណួរបន្ទាប់ទៅទៀត។ លោកស្រីឆ្លើយថា លោកស្រីរៀបការនៅចុងឆ្នាំ៧៧ ជាមួយនឹងប្ដីសព្វថ្ងៃលោកស្រីនេះ ហើយគាត់ គាត់ធ្វើនៅខាងធ្វើត្រី ប្ដីលោកស្រី។ ដូច្នេះពេលរៀបការហ្នឹង គឺលោកស្រីរៀបដោយស្ម័គ្រចិត្ត ដើម្បីបានទៅនៅសហករណ៍មែនទេ?

[១៥:៤១:៣០]

**ឆ៖** ចាស ខ្ញុំសុខចិត្តស្ម័គ្រចិត្ត រៀបការទៅនៅបានតាមសហករណ៍ មិននៅកងចល័តទេពិបាកណាស់។ ខ្ញុំសុខចិត្ត ស្រឡាញ់ មិនស្រឡាញ់ ក៏ខ្ញុំសុខចិត្តការដែរ បានទៅនៅតាមសហករណ៍។

**កញ្ញា អង់តា ហ្គិសសេ៖**

លោកប្រធាន ខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ដល់ពេលនេះសវនាការស្ដាប់សក្ខីកម្ម អ៊ិន យឿង បានដល់ទីបញ្ចប់ហើយ។ អង្គជំនុំជម្រះអរគុណលោកស្រី អ៊ិន យឿង ដែលបានចំណាយពេលវេលាដ៏មានតម្លៃមកផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ ក្នុងឋានៈជាសាក្សី អស់រយៈពេលពីរថ្ងៃកន្លងមក ហើយសក្ខីកម្មរបស់លោកស្រីនឹងអាចរួមវិភាគទានក្នុងការស្វែងរកការពិតនៅរឿងក្ដីនេះ។ ហើយវត្តមានរបស់លោកស្រីនៅ អ.វ.ត.កនេះលែងមានភាពចាំបាច់ទៀតហើយ លោកស្រីអាចវិលត្រឡប់ទៅកាន់លំនៅដ្ឋានរបស់លោកស្រី ឬក៏លោកស្រីគោលដៅណាដែលលោកស្រីមានបំណងចង់ទៅបានហើយ។ ហើយសូមលោកស្រីជួបតែសំណាងល្អ បានសេចក្ដីសុខ សេចក្ដីចម្រើន។ ហើយអង្គជំនុំជម្រះក៏សូមអរគុណលោកស្រី ឆាយ ម៉ារីដែត បុគ្គលិកអង្គការ ធី.ភី.អូ ដែលនាពេលនេះ លោកស្រីអាចសម្រាកបានហើយ។

បង្គាប់ឲ្យមន្ត្រីរដ្ឋបាលតុលាការ សម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនលោកស្រី អ៊ិន យឿង វិលត្រឡប់ទៅកាន់លំនៅដ្ឋានរបស់គាត់ ឬក៏គោលដៅណា

ដែលគាត់មានបំណងចង់ទៅបានហើយ។ សូមអញ្ជើញ សូមចាកចេញទៅចុះ!

*(សាក្សីចាកចេញពីបន្ទប់សវនាការ)*

[១៥:៤៣:១២]

បាទ ជាបន្តទៅនេះ អង្គជំនុំជម្រះធ្វើសវនាការស្តាប់សារណាផ្ទាល់មាត់ភាគី ពាក់ព័ន្ធទៅនឹងសំណើរបស់ក្រុមមេធាវីការពារក្តី នួន ជា ដែលបានស្នើសុំឲ្យអង្គជំនុំជម្រះទទួលយកឯកសារមួយចំនួនអនុលោមវិធាន៨៧(៤)នៃវិធានផ្ទៃក្នុង សម្រាប់សួរដេញដោលសាក្សីអ្នកជំនាញ 2-TCE-95។ ហើយកាលពីថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៦ សហមេធាវីកាពារក្តី នួន ជា បានដាក់សំណើមួយសុំឲ្យអង្គជំនុំជម្រះសម្រេចទទួលយកជាឯកសារភ័ស្តុតាងនូវឯកសារចំនួន១៥ អនុលោមវិធាន៨៧(៤)នៃវិធានផ្ទៃក្នុង ដើម្បីសួរដេញដោលអ្នកជំនាញ ដែលមានរហស្សនាម 2-TCE-95 ដែលគ្រោងនឹងស្តាប់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ នៅសប្តាហ៍ក្រោយ (ឯកសារ E367/4)។

ហើយនៅថ្ងៃដដែលនោះក្រុមមេធាវីការពារក្តី នួន ជា ក៏បានដាក់សំណើសុំឲ្យទទួលយកឯកសារចំនួន១៤ផ្សេងទៀត ដែលសំណើនោះមានតែជាភាសាអង់គ្លេស ដោយសារការបកប្រែមិនអាចធ្វើទាន់ពេល។ ហើយនៅព្រឹកមិញនេះ អង្គ មន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូង បានជូនដំណឹងដល់ភាគីថា អង្គជំនុំជម្រះបានអនុញ្ញាតឲ្យលោក ក្រុមមេធាវីការពារក្តី នួន ជា ដាក់សំណើនោះជាភាសាអង់គ្លេសជាមុន ហើយដាក់ភាសាខ្មែរតាមក្រោយ បន្ទាប់ពីបានទទួលការបកប្រែ។

[១៥:៤៤:៣៩]

ហើយអង្គជំនុំជម្រះក៏សូមជូនដំណឹង១ដល់ភាគីនានាផងដែរថា អង្គជំនុំជម្រះមានចេតនាក្នុងស្តាប់នូវសារណាផ្ទាល់មាត់របស់ភាគីនានា ប្រសិនបើមាន។ ហើយបន្ទាប់ពីការស្តាប់សក្ខីកម្ម អ៊ិន យឿង បានបញ្ចប់នៅថ្ងៃស្អែក ប៉ុន្តែដោយសារការស្តាប់សក្ខីកម្មលោកស្រី អ៊ិន យឿង បានចប់ពេលមុនកំណត់។ ហើយភាគីនានាបានជម្រាបអង្គជំនុំជម្រះរួចហើយថា ខ្លួនបានត្រៀមរួចរាល់ហើយ ដើម្បីឆ្លើយតបទៅនឹងសំណើសុំខាងលើ។

អង្គជំនុំជម្រះនាពេលនេះ សម្រេចស្តាប់សារណាផ្ទាល់មាត់របស់ភាគី។ ហើយដំបូងនេះ អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញា ដើម្បីមានឱកាសធ្វើការសារណាឆ្លើយតបទៅនឹងសំណើសុំរបស់ក្រុមសហមេធាវីការពារក្តី នួន ជា ដែលបានដាក់សំណើចំនួនពីរខាងលើនេះ។

សូមអញ្ជើញ!

បាទ ៗអរគុណឥឡូវផ្តល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្តីលោក នួន ជា ជាមុន។ សូមអញ្ជើញលោកសហមេធាវីការពារក្តីលោក នួន ជា! តើលោកចង់បង្ហាញនូវ បំណងបង្ហាញនូវសំណើសុំរបស់លោក ហើយនិងសម្អាងហេតុ និងមូលហេតុទាំងឡាយដែលនាំឲ្យលោកដាក់ស្នើសុំ ឬក៏យ៉ាងម៉េច?

**លោក វ៉ិចទ័រ កូប៉េ៖**

ដោយសារតែមានពេលវេលា ខ្ញុំគិតថា ជាការល្អគួរតែលើកយកខ្លឹមសារនៃសំណើទាំងពីរតែម្តង។ ហេតុផលដែលខ្ញុំងើបឡើង គឺថាដើម្បីបញ្ជាក់ឲ្យច្បាស់ ព្រោះមានឯកសារមួយត្រូវបានទទួលយក ដោយអង្គជំនុំជម្រះសាលាដំបូងរួចហើយ គឺឯកសារដែលជាឧបសម្ព័ន្ធសាធារណៈ គឺឯកសារមានឯកសារសាធារណៈចំនួនប្រាំបី គឺដូចជាអត្ថបទរបស់ភ្នំពេញប៉ុស្តិ៍ របស់ ហ្វីលីព ស្សូត។ ហើយប្រសិនបើខ្ញុំនិយាយមិនខុសទេគឺ E367/4.1.8។ ហើយខ្ញុំគិតថា ឯកសារនេះបានទទួលយករួចទៅហើយ។ ដូច្នេះខ្ញុំគ្រាន់តែចង់បញ្ជាក់ ឯកសារហ្នឹងបានទទួលយក ប៉ុន្តែដកចេញមកវិញ។ ដូច្នេះគ្រាន់តែ--

[១៥:៤៧:១១]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ខ្ញុំចង់ដឹងថា តើនេះជាសាធារណៈដែលថាលោកគ្រាន់តែចង់បញ្ជាក់អំពីហេតុផលដែលដាក់យឺត ឬមួយក៏យ៉ាងម៉េច?

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ ជាការពិត។ ហេតុផល នេះគឺជាហេតុផលដែលខ្ញុំដាក់សំណើនៅពេលនេះ ព្រោះថា មានឯកសារមួយចំនួន គឺវាមានរួចទៅហើយ តាំងពីមុនពេលបើកសវនាការមកម្ល៉េះ ហើយឯកសារខ្លះទៀតមិនទាន់ទេ។ ប៉ុន្តែយ៉ាងណាក៏ដោយ អ្នកជំនាញរូបនេះ គាត់នឹងមកផ្តល់សក្ខីកម្ម ហើយខ្ញុំស្នើសុំការអនុញ្ញាតពីអង្គការសហប្រជាជាតិ ដើម្បីឲ្យគាត់មកផ្តល់សក្ខីកម្ម។ ខ្ញុំគួរតែដាក់សំណើនេះ មុនពេលនេះបន្តិច ប៉ុន្តែដោយសារតែបញ្ហាធនធាន ទើបយើងដាក់នៅពេលនេះ។ ខ្ញុំគិតថា ខ្ញុំដឹងថា ការជូនដំណឹងរបស់ខ្ញុំគឺជូនដំណឹងឆាប់រហ័សពេក ប៉ុន្តែយ៉ាងណាក៏ដោយ យើងបានដាក់សំណើដទៃទៀតទាក់ទងទៅនឹងឯកសារដែលស្នើសុំឲ្យទទួលយក។ ហើយយើងមានសំណើមួយដែលរហូតមកដល់ពេលនេះ អង្គជំនុំជម្រះមិនទាន់សម្រេចនៅឡើយ។ ទោះជាយ៉ាងណាក៏ដោយ ដោយផ្អែកទៅលើសក្ខីកម្មដែលអាចនឹងនិយាយអំពីខ្មែរ-ស ទើបយើងដាក់សំណើនៅពេលនេះ ទោះបីថាវាយឺត ប៉ុន្តែបានទទួលយករួចទៅ

ហើយ។ ដូច្នេះវាមិនមែនជាការដាក់ដែលយឺតហួសហេតុពេកនោះទេ។ ខ្ញុំគិតថាឯកសារនេះ គួរតែបានទៅយក ដោយសារតែវាបានឆ្លុះបញ្ចាំងអំពីអនាគតិ និងភាពមិនលម្អៀងរបស់សាក្សីរូបនេះ។ ដូច្នេះទើបខ្ញុំគិតថា សំណើទាំងពីរនេះ គួរតែអាចទទួលយកបាន។

[១៥:៤៩:១៦]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ តទៅនេះ ផ្តល់វេទិកាជូនទៅក្រុមសហព្រះរាជអាជ្ញា។

**លោក នីកូឡាស គូមជែន៖**

សូមអរគុណលោកប្រធាន លោក លោកស្រីចៅក្រម។ ជាដំបូង ខ្ញុំសូមពន្យល់បន្តិចថាខ្ញុំហាក់ដូចជាមានគុណវិបត្តិដោយសារតែឯកសារទាំងពីរនេះ ព្រោះថា យើងទើបតែបានទទួលទាំងអស់នេះនៅថ្ងៃនេះ ហើយខ្ញុំកំពុងតែ -- ការបង្ហាញនេះ គឺខ្ញុំទើបព្រីននៅថ្ងៃនេះ ហើយវាមានទំព័ររាប់រយទំព័រ។ ហើយឯកសារមួយចំនួនទៀតគឺមានអក្សរតូចៗមែនទែន។ ខ្ញុំទើបតែបានមើលមួយត្រួសទៅលើឯកសារទាំងអស់នេះ។ ហើយខ្ញុំសូមលើកយកនូវមតិមួយចំនួន ហើយខ្ញុំគិតថាមតិខ្ញុំខ្លះអាចមានន័យ ប៉ុន្តែយ៉ាងណាក្តី ខ្ញុំនឹងព្យាយាមពិនិត្យលើកម្តងមួយ។ គឺឯកសារ E361/4.1.1 គឺជាការសម្ភាសជាមួយសាក្សីអ្នកជំនាញ។ ហើយមានឯកសារដទៃទៀតមួយចំនួនដែលជាចម្លើយរបស់សាក្សី យើងមិនជំទាស់ទេ ហើយយើងឃើញអំពីភាពពាក់ព័ន្ធផងដែរ។ ហើយសាក្សីទាំងអស់នេះអាចជួយដល់អង្គជំនុំជម្រះក្នុងការស្វែងរកការពិត យើងមិនជំទាស់ទេ។ ឧបសម្ព័ន្ធទី២ ដែលយើងឃើញនៅក្នុងការជូនដំណឹង គឺយើងឃើញថាវាមានភាពពាក់ព័ន្ធដែរ។ ឧបសម្ព័ន្ធ៣ គឺឯកសារដែលមានបញ្ជីសាក្សី ដែលសាក្សីអ្នកជំនាញបានធ្វើការសម្ភាសនៅពេលវេលាជាក់លាក់ ក៏ដូចជាមួយការិយាល័យសហចៅក្រមស៊ើបអង្កេត។

[១៥:៥១:០៦]

ខ្ញុំយល់ថានៅក្នុងសារណាបែបនេះ គឺត្រូវបានការិយាល័យសហចៅក្រមស៊ើបអង្កេតអនុញ្ញាតឲ្យដាក់បង្ហាញ។ ខ្ញុំគិតថាទាំងអស់នេះ គឺវាអាស្រ័យថា តើយើងប្រើប្រាស់ឯកសារនេះដោយរបៀបណា។ ខ្ញុំចង់បញ្ជាក់ច្បាស់ថា យើងមិនគិតថា អង្គជំនុំជម្រះកោះហៅសាក្សីនេះ មកក្នុងនាមជាអ្នកស៊ើបអង្កេត ឬក៏អ្នកដែលបានចូលរួមនៅក្នុងស្ថាប័នដទៃទៀតមួយនោះឡើយ។ គាត់មកទីនេះ គឺដើម្បីផ្តល់មតិជាអ្នកជំនាញរបស់គាត់ ហើយវាអាចមានកាលៈទេសៈ ដែលមេធាវីការពារក្តីអាចនិយាយ ឬក៏អាចទាញបានថា មតិជំនាញរបស់គាត់អាចទទួលឥទ្ធិពល ដោយសារតែការងាររបស់គាត់ជាអ្នកស៊ើប

អង្កេត។ ដូច្នេះខ្ញុំមិនចង់និយាយថា តើសាក្សីហ្នឹងគាត់ទទួលឥទ្ធិពលបែបណាពីការស្តាប់ឮរបស់គាត់ជាមួយនឹងការងារនៅក្នុងការិយាល័យសហចៅក្រមស៊ើបអង្កេតនោះឡើយ។

ចំពោះឧបសម្ព័ន្ធទី៤ គឺជាឯកសារដែលផ្តល់សិទ្ធិអនុញ្ញាត គឺជាឯកសារដែលគាត់សម្ភាសជាមួយសាក្សី ហើយខ្ញុំគិតថា វាអាចជួយដល់អង្គជំនុំជម្រះផងដែរ។ បន្ទាប់មកទៀត យើងមានឯកសារជាច្រើនទៀត គឺឧបសម្ព័ន្ធទី៥។ បន្ទាប់គឺជាឯកសារដែលមានចំណងជើងថា "អំពើប្រល័យពូជសាសន៍នៅកម្ពុជា" ហើយគាត់បានភ្ជាប់នូវមតិរបស់បុគ្គលជាច្រើនអំពីបញ្ហា ថាតើកម្ពុជាប្រជាធិបតេយ្យអាចចាត់ទុកថាជាអំពើប្រល័យពូជសាសន៍ចាមបាន ឬក៏អត់? ហើយអ្នកដែលគេសម្ភាសហ្នឹងក៏មិនបានដកស្រង់អំពីយុត្តិសាស្ត្រណាមួយទាក់ទងទៅនឹងអំពើប្រល័យពូជសាសន៍នោះឡើយ។ ក៏ដូចជាមិនបាននិយាយអំពីចេតនា ឬក៏អំពើសកម្ម ឬអកម្មក្នុងការបំផ្លាញពូជសាសន៍មួយទាំងស្រុង ឬក៏ដោយផ្នែកនោះទេ។

[១៥:៥៣:១៩]

ប្រាកដណាស់ថា មេធាវីការពារក្តីអាចដកស្រង់នូវទឡ្ហីករណ៍ទាំងអស់នេះ ឬក៏ធាតុផ្សំនៃអំពើប្រល័យពូជសាសន៍នានា ក៏ដូចជាភ័ស្តុតាងនៅក្នុងសំណុំរឿងទាំងអស់នេះ។ អានេះគឺជាៗវិធីសាស្ត្ររបស់មេធាវីការពារក្តី ហើយខាងព្រះរាជអាជ្ញាក៏រីករាយនឹងឆ្លើយតបនៅពេលនោះដែរ។ ហើយយើងក៏អាចនឹងដកស្រង់នូវយុត្តិសាស្ត្រជាតិអំពីអំពើប្រល័យពូជសាសន៍ ដែលៗនិយាយអំពីចេតនាក្នុងការសម្លាប់ជនជាតិចាមនៅក្នុងប្រទេសកម្ពុជាផងដែរ។

ដូច្នេះមិនមែនជាការសមស្របនោះទេ ដែលថាយើងដកស្រង់មតិរបស់អ្នកដទៃ ទោះបីថាគាត់ជា ប៊ែន ឃៀរនិន ឬក៏ជាស្អីក៏ដោយ ដែលនិយាយថា ទោះបីថាជាអ្នកជំនាញដូចជា ដេវីដ ឆេនដ៍ល័រ ឬក៏ ដេគ្រី និយាយអំពីទាក់ទងនឹងរឿងប្រល័យពូជសាសន៍ក៏ដោយ ក៏ពួកគាត់ទាំងអស់នោះ ពួកអ្នកជំនាញទាំងអស់នោះមិនមានព័ត៌មានអំពីភ័ស្តុតាង ដែលយើងកំពុងតែជជែកដេញដោលនៅក្នុងតុលាការនេះឡើយ។ ដូច្នេះខ្ញុំជំទាស់ទៅនឹងឯកសារនេះ។

ឯកសារបន្ទាប់មួយទៀត គឺជាព្រឹត្តិបត្ររបស់សារព័ត៌មានអាស៊ីមួយចំនួន មានរបស់ ប៊ែន ឃៀរនិន ជាដើម។ ហើយខ្ញុំឃើញថា ឯកសារភាគច្រើនគឺជាអង្គហេតុដែលនិយាយអំពីប្រវត្តិរបស់ជនជាតិចាម អំពីអង្គហេតុនៃប្រជាជនចាម ហើយខ្ញុំគិតថា វាអាចមានភាពពាក់ព័ន្ធ។ ដូច្នេះខ្ញុំមិនជំទាស់ទេ។ ហើយឯកសារមួយទៀត គឺជារបស់ ប៊េក យឺរី យើងឃើញថា វាមានបញ្ហាទាក់ទងទៅនឹងចំនួនមនុស្សដែលត្រូវគេសម្លាប់ ក៏ដូចភាគរយនៃអ្នកដែលត្រូវបានសម្លាប់។ ហើយយុត្តិសាស្ត្រអន្តរជាតិក៏

បញ្ជាក់ច្បាស់ វាមិនសំខាន់ថាតើមានចំនួនប៉ុន្មានត្រូវបានសម្លាប់នោះទេ គឺសំខាន់បំផុតគឺអាស្រ័យទៅលើចេតនា ប៉ុន្តែយ៉ាងណាក៏ដោយចំនួននោះវាអាចជួយផងដែរ។ ដូច្នេះខ្ញុំមិនជំទាស់ទៅលើឯកសារនេះទេ ដោយសារឯកសារនេះ វាបានបង្ហាញអំពីចំនួនប្រជាជនចាម មុន និងក្រោយរបបកម្ពុជាប្រជាធិបតេយ្យ ដើម្បីជួយដល់អង្គជំនុំជម្រះជួយក្នុងការស្វែងរកការពិត។ ហើយ ម៉ែខល វីកឃើរី ក៏គាត់បាននិយាយច្បាស់ បង្ហាញច្បាស់អំពីចំណុចទាំងអស់នេះ។ ហើយគាត់ក៏បាន -- ហើយគាត់ជាអ្នកនិពន្ធទៅលើសៀវភៅនេះ ខ្ញុំមិនជំទាស់នោះទេ។ ខ្ញុំគិតថាវាមានតម្លៃគួរសមដែរ។

[១៥:៥៥:៥៥]

ឯកសារបន្ទាប់ទៀត ខ្ញុំដឹងថា មេធាវី គាត់និយាយហើយវាមាននៅក្នុងសំណុំរឿង ប៉ុន្តែវាអត់មានទេ ប៉ុន្តែយ៉ាងណាក៏ដោយ យើងមិនជំទាស់នោះទេ។ វាគ្រាន់តែជាមតិរបស់គាត់ របស់អ្នកនិពន្ធដែលនិយាយអំពីអំពើប្រល័យពូជសាសន៍ដែលយើងមាននៅក្នុងសំណុំរឿង។ ហើយនេះជាសំណួរទាក់ទងទៅនឹងអង្គច្បាប់។

ឯកសារបន្ទាប់មួយទៀត ដែលយើងជំទាស់ដូចគ្នាដោយសារហេតុផលតែមួយ គឺដោយសារតែមានហេតុផលដូចគ្នា។ ហេតុអ្វីបានជាគេសម្លាប់វា? គឺជាការបង្ហាញមតិអំពីធាតុផ្សំនៃអំពើប្រល័យពូជសាសន៍ ថាតើវាកើតឡើងប្រឆាំងជនជាតិចាម ឬក៏អត់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ហើយមេធាវីការពារក្តីបានថតចម្លង ហើយបានដាក់ជូនទៅអង្គជំនុំជម្រះ។ ហើយខ្ញុំគិតថា ខ្ញុំនឹងបង្ហាញថាហេតុអ្វីបានជាវាខុសនៅពេលដែលយើងយកឯកសារនេះមកពិភាក្សា។

ហើយចំណុចបន្ទាប់មួយទៀត គឺជាឯកសារដែលមិនមាននិយមន័យអំពើប្រល័យពូជសាសន៍ ហើយក៏ឯកសារទាក់ទងនឹងនិយមន័យនៃប្រល័យពូជសាសន៍ យើងជំទាស់។ ឯកសារមួយទៀត គឺជាឯកសាររបស់ ប៉ែន យៀវនិន ទាក់ទងទៅនឹងការគណនាចំនួន ឬក៏ទាក់ទងទៅនឹងបរិមាណនៃការសម្លាប់។ ហើយខ្ញុំគិថា ឯកសារនេះវាមានភាពពាក់ព័ន្ធដែរ ដូច្នេះយើងអាចទទួលយក។ ឯកសារមួយទៀត គឺជាសារព័ត៌មានទាក់ទងទៅនឹងអំពើប្រល័យពូជសាសន៍។ ដូច្នេះហើយខ្ញុំគិតថា វាជាបញ្ហាផ្លូវច្បាប់នៃអំពើប្រល័យពូជសាសន៍។ ដូច្នេះអាស្រ័យទៅលើអង្គជំនុំជម្រះសម្រេចថា ទទួលឬមិនទទួល។ វាគ្រាន់តែជាការបង្ហាញអំពីទឡ្ហីករណ៍ទៅតាមពាក្យសម្ដីអ្នកនិពន្ធនោះ។

[១៥:៥៧:៤២]

ឯកសារបន្តទៀត គឺមានចម្លើយជាច្រើនពីសាក្សីអ្នកជំនាញ។ ដូច្នេះខ្ញុំគិតថាវាពាក់ព័ន្ធ យើងមិន

ជំទាស់នោះទេ។ អត្ថបទមួយទៀត គឺនិយាយអំពីជនជាតិចាម ដែលគេបានដកស្រង់នូវរដ្ឋអាជ្ញា ក៏ដូចជា ហើយខ្ញុំគិតថាដូចជាមិនមានអ្វីភាពពាក់ព័ន្ធទេ ទោះបីថាវាមិនពាក់ព័ន្ធ ប៉ុន្តែវាក៏មិនប៉ះពាល់អីដល់យើងដែរ។ ដូច្នេះដោយសារតែយើងគិតទៅដល់ពេលវេលាដែលគេដាក់សារណា គួរតែកុំទទួលយក។

ឯកសារបន្តទៀត គឺជាឯកសារ សុទ្ធតែឯកសារជាភាសាខ្មែរ ខ្ញុំអានមិនដាច់ទេ។ ខ្ញុំគិតថាទាំងអស់នេះគឺជាអ្វីដែលយើងបានទទួលបានជំទាស់។ ហើយខ្ញុំគិថា អង្គជំនុំជម្រះប្រហែលជាបានអាននូវសេចក្តីសម្រេចរបស់តុលាការកំពូល ទាក់ទងទៅនឹងភ័ស្តុតាងដែលទទួលបានដោយការធ្វើទារុណកម្ម។ ដូច្នេះខ្ញុំគិតថា យើងអាចផ្អែកទៅលើសេចក្តីសម្រេចទាំងអស់នេះ។ ដូច្នេះការសម្ភាសដែលទទួលបានពីមន្ទីរស-២១ គឺជាការទទួលបានភ័ស្តុតាងដោយការធ្វើទារុណកម្ម។ ដូច្នេះខ្ញុំគិតថាវាជា យើងអាចចាត់ថ្នាក់ជាការធ្វើទារុណកម្មតាមផ្លូវកាយ ឬក៏ផ្លូវចិត្ត ដោយសារតែអ្នកទាំងអស់នោះត្រូវគេដាក់ច្រវាក់ដាក់ខ្នោះឃ្នាង គេធ្វើទារុណកម្ម ហើយត្រូវទុកដល់ស្លាប់។ ដូច្នេះខ្ញុំគិតថាគឺពួកគាត់ទទួលរងនូវព្យសនកម្មយ៉ាងខ្លាំង។ ដូច្នេះខ្ញុំគិតថា ឯកសារទាំងអស់នេះ អាចទទួលបានតែក្នុងករណីដែលមិនមានភ័ស្តុតាង ឬក៏ឯកសារដទៃទៀតដែលអាចបង្ហាញអំពីការពិតបាននោះ។

[១៥:៥៩:៤០]

ឯកសារមួយទៀត គឺជាឯកសារវែងអំពីមហន្តរាយរបស់ជនជាតិចាម យើងមិនជំទាស់ទេ ខ្ញុំគិតថា យើងអាចត្រូវការឯកសារបែបនេះ។ វាគ្រាន់តែជាបញ្ហាអង្គហេតុទាក់ទងនឹងប្រវត្តិជនជាតិចាម។ ឯកសារមួយទៀត គឺចលនាខ្មែរសេរី។ វាជាឯកសារគួរឲ្យចាប់អារម្មណ៍ផងដែរ ដោយសារតែវាមានមនុស្សជាច្រើន រួមទាំងបុគ្គលនៅក្នុងទីនេះផងដែរ យល់ច្រឡំអំពីចលនាខ្មែរសេរី ហើយខ្ញុំគិតថា ជាការល្អហើយ ដែលយើងអាចអានឯកសារនេះ ប៉ុន្តែខ្ញុំគិតថា ដូចជាមិនមានពាក់ព័ន្ធនឹងជនជាតិចាមនោះទេ។ វាគ្រាន់តែជាភ័ស្តុតាង ហើយខ្ញុំដឹងថា ភ័ស្តុតាងនេះ វា -- ខ្ញុំដឹងអំពីភ័ស្តុតាង ទោះបីថាយ៉ាងណាក្តី យើងមានការជជែកគ្នាថា ចាម គាត់ចូលរួមនៅក្នុងចលនាខ្មែរសេរី ប៉ុន្តែខ្មែរក្រោម ក៏គាត់ចូលរួមនៅក្នុងចលនាខ្មែរសេរី។ ដូច្នេះហើយខ្ញុំគិតថា ឯកសារនេះ អាចពាក់ព័ន្ធទៅនឹងសាក្សីរូបនេះផងដែរ។

ហើយឯកសារមួយទៀត ដូចជាមិនពាក់ព័ន្ធទៅនឹងជនជាតិចាម ឬក៏សាក្សីនោះឡើយ។ ហើយខ្ញុំគិតថា ឯកសារភាគច្រើន គឺពាក់ព័ន្ធទៅនឹងបុគ្គលម្នាក់ដែលខ្ញុំអានឈ្មោះគាត់មិនត្រឹមត្រូវ មិនច្បាស់ គឺថា យើងមិនច្បាស់ ព្រោះគាត់ជាមេទ័ពជនជាតិចាមនៅក្នុងរបប លន់នល់ ហើយខ្ញុំឃើញថា ឯកសារនេះ វាហាក់ដូចជា មានភាពពាក់ព័ន្ធទៅនឹងបញ្ហាដែលយើងកំពុងតែជំនុំជម្រះ។ ដូច្នេះឯកសារទាំងអស់

-- ឯកសារមួយនេះ គឺឯកសារទី៥។

ហើយឥឡូវនេះឯកសារទី៦ មេធាវីការពារក្ដីបានបញ្ជាក់ថា សំខាន់ ដោយសារតែបង្ហាញអំពីទំនាក់ទំនងអាមេរិក-លន់នល់។ ប៉ុន្ដែខ្ញុំគិតថា យើងទាំងអស់គ្នាដឹងច្បាស់ថា អាមេរិកមានទំនាក់ទំនងជាជិតស្និទ្ធជាមួយលន់នល់។ ដូច្នេះខ្ញុំគិតថា ដូចជាមិនមានតម្លៃអ្វី ក្នុងការបន្ថែមឯកសារនេះចូលឱ្យ។

ហើយឯកសារទី៧ គឺយើងជំទាស់ ដោយសារហេតុផលដូចគ្នា អំពីជនជាតិចាម។ ខ្ញុំ នេះគឺខ្ញុំយល់ ខ្ញុំលុបពាក្យខ្ញុំចោលវិញសិន ដោយសារតែឯកសារនេះ ខ្ញុំមើល ប៉ុន្ដែមើលមួយភ្លែតទៅ ដូចជាមិនមានអ្វីនិយាយអំពីចាមទេ។

[១៦:០២:១៩]

ឯកសារទី៨ គឺជាតារាងអំពីទំនាក់ទំនងអាមេរិកជាមួយលន់នល់ ដូចជាមិនមានអ្វីពាក់ព័ន្ធទៅនឹងបញ្ហាកំពុងទាក់ទងក្នុងសំណុំរឿងនេះឡើយ។

ហើយឯកសារទី៩គឺដូចគ្នា គឺជាឯកសាររបស់អ្នកណាម្នាក់ដែលខ្ញុំមិនច្បាស់ ដែលគាត់ព្យាយាមចង់ឱ្យមានការគាំទ្រ ឬក៏ស្វែងរកការគាំទ្រពីប្រទេសអ៊ីស្លាមនានា នៅក្នុងរបបលន់នល់នោះ។

ដូច្នេះឯកសារទី១០ យើងជំទាស់។ ឯកសារ១១ យើងជំទាស់។ ឯកសារ១២វិញ ឯកសារ១៣វិញ គឺនិយាយអំពីកងកម្លាំងរបស់ខ្មែរសេរី ដែលចង់បះបោរប្រឆាំងស្ដេច សីហនុ។ យើងគិតថា ដូចជាមិនពាក់ព័ន្ធ ហើយបញ្ហានេះ អាចអ្នកសាក្សីអ្នកជំនាញគាត់និយាយ។

ឯកសារ១៤ ទោះបីថា មានបញ្ហាអង្គហេតុមួយចំនួន ប៉ុន្ដែដូចជាគ្មានអីថ្មីនោះទេ។ ខ្ញុំគិតថា វាមិនចាំបាច់ ហើយវាមិនពាក់ព័ន្ធទៅនឹងសាក្សីមួយនេះ។

ប្រហែលជាខ្ញុំបាត់ឯកសារចុងក្រោយហើយ នៅសល់ឯកសារមួយទៀត យ៉ាងម៉េចដែរ? ខ្ញុំគិតថា អស់ហើយ ខ្ញុំបាននិយាយអំពីឯកសារទាំងអស់ហើយ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ ហើយជាបន្ដទៅនេះ ផ្ដល់វេទិកាជូនទៅក្រុមសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ដើម្បីមានឱកាសធ្វើសារណាតបទៅនឹងសំណើសុំរបស់លោក ក្រុមសហមេធាវីការពារក្ដីលោក នួន ជា។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ ក្រៅពីចម្លើយសារភាពដែលអង្គជំនុំជម្រះត្រូវបដិសេធនោះ ខ្ញុំ

គោរពទៅតាមការសម្រេចរបស់អង្គជំនុំជម្រះ យើងអត់មានការជំទាស់ទៅលើឯកសារផ្សេងទៀតទេដែលមាននៅក្នុងសំណើរបស់ នួន ជា ផ្អែកតាមវិធាន៨៧(៤)នោះ លើកលែងតែឯកសារចម្លើយសារភាពមួយតែប៉ុណ្ណោះ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ខ្ញុំសូមការបំភ្លឺមួយពីមេធាវី កូប៉េ។ លោកមេធាវី កូប៉េ លោកអាចបញ្ជាក់បានទេ ហេតុអ្វីបានជាលោកសុំឲ្យអង្គជំនុំជម្រះទទួលយកចម្លើយសារភាពចេញមកពីស-២១ នោះ?

**លោក វ៉ិចទ័រ កូប៉េ៖**

ជាដំបូងគឺថា យើងដឹងថា មានចម្លើយសារភាពជាច្រើនដែលបានទទួលយកចូលទៅក្នុងសំណុំរឿង ខ្ញុំមិនចាំថាមានប៉ុន្មានទេ ប៉ុន្តែអាចមានចម្លើយស-២១ ដល់រាប់រយដែលបានដាក់ចូលទៅក្នុងសំណុំរឿង។ ដូច្នេះសំណើសុំដាក់នូវចម្លើយសារភាពទាក់ទងទៅនឹងជនជាតិចាម គឺមិនមែនជារឿងចម្លែកនោះទេ មិនមែនជាសំណើប្លែកនោះទេ។ យើងដាក់សំណើទាក់ទងទៅនឹងចម្លើយសារភាពទាំងអស់នេះ ព្រោះថាអ្នកជំនាញគាត់ផ្អែកជាច្រើនទៅលើចម្លើយ ទៅលើការវិភាគ ទៅលើចម្លើយសារភាពនេះ ហើយគាត់ប្រើចម្លើយសារភាពនេះ នៅក្នុងសៀវភៅរបស់គាត់ ដូចជាចម្លើយសារភាពរបស់មេបះ បោរចាម។ ហើយខ្ញុំគិតថា អង្គជំនុំជម្រះបានសម្រេចជាច្រើនដងថា យើងមិនអនុញ្ញាតឲ្យប្រើប្រាស់ឯកសារបែបនេះ មកសួរដេញដោលនោះទេ។ ប៉ុន្តែចម្លើយសារភាពបែបនេះ គឺជាផ្នែកមួយនៅក្នុងសំណុំរឿង។ ហើយខ្ញុំជឿជាក់ថា ចម្លើយសារភាពបែបនេះ គួរតែដាក់នៅក្នុងសំណុំរឿងផងដែរ ដោយសារតែចម្លើយសារភាពនេះ វាមានភាពពាក់ព័ន្ធ។

[១៦:០៧:១៨]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ប្រសិនបើខ្ញុំយល់មិនច្រឡំទេ គឺលោកចង់ប្រើប្រាស់ខ្លឹមសារនៃចម្លើយសារភាពយកមកសួរសំណួរទៅលើអ្នកជំនាញមែនទេ? តើលោកចង់ប្រើប្រាស់ខ្លឹមសារនៃចម្លើយសារភាពដើម្បីសួរអ្នកជំនាញមែនទេ?

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំច្បាស់ហើយថា ខ្ញុំមិនអាចធ្វើបែបនេះបានទេ ប៉ុន្តែមិនមែនមានន័យថា មេធាវីការពារក្តីមិនអាចដឹងអំពីខ្លឹមសារនៃចម្លើយសារភាពនោះឡើយ ទោះបីថាឥឡូវនេះមានតែភាសាខ្មែរ ក៏ដោយប៉ុន្តែអ្នកនិពន្ធ ក៏ដូចជាសាក្សីអ្នកជំនាញ គាត់បានប្រើប្រាស់ជាច្រើន ទាក់ទងទៅនឹងចំណុចទាំងអស់នេះ។ ដូច្នេះហើយដើម្បីឲ្យយើងមានសមត្ថភាពប្រហែលនឹងអ្នកនិពន្ធហ្នឹង ខ្ញុំគិតថា វាគួរតែអនុញ្ញាតឲ្យយើងមើលក៏ដូចជាប្រាប់ ពិនិត្យទៅលើឯកសារនេះ។ ប៉ុន្តែខ្ញុំមិនប្រើប្រាស់ចម្លើយសារភាពនេះ ដើម្បីសួរសំណួរជាក់លាក់ណាមួយទៅលើអ្នកទោសជាក់លាក់ណាមួយ ឬក៏លើកជាសម្តីជាក់លាក់ណាមួយ របស់អ្នកទោសចាមនៅ ស-២១ នោះទេ។ ខ្ញុំគិតថា យើងគួរតែដូចដែលខ្ញុំនិយាយ ព្រោះថាវាមានចម្លើយជាច្រើន ចម្លើយសារភាពជាច្រើននៅក្នុងសំណុំរឿងបច្ចុប្បន្ននេះ។

[១៦:០៨:៤៥]

**លោក នីកូឡាស គូមជែន៖**

លោកប្រធាន ទាក់ទងទៅនឹងឯកសារជាភាសាខ្មែរ ខ្ញុំគិតថា វាជាការចាំបាច់ដែលយើងគួរតែដឹងថា ថាតើមេធាវីការពារក្តីបានស្នើឲ្យដាក់បកប្រែហើយឬនៅ ហើយនេះគឺជាការស្តាប់ចម្លើយរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ក៏ដូចជាចម្លើយសារភាព។ ដូច្នេះខ្ញុំគិតថា វាជាការល្អ ប្រសិនបើយើងដឹងថា តើមេធាវីការពារក្តីបានស្នើឲ្យមានការបកប្រែហើយឬនៅ? ហើយថាតើការបកប្រែហ្នឹងបញ្ចប់នៅពេលណា ឬក៏រួចរាល់ហើយ?

**លោក វ៉ិចទ័រ កូប៉េ៖**

យើងមិនទាន់បានស្នើសុំឲ្យមានការបកប្រែនៅឡើយទេ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

សំណួរដដែលចំពោះឯកសារដែលមានតែជាភាសាអង់គ្លេស។

**លោក វ៉ិចទ័រ កូប៉េ៖**

មិនទាន់ទេ លោកចៅក្រម ឡាវែន៍ យើងមិនទាន់បានស្នើសុំនោះទេ។ ប៉ុន្តែនៅពេលដែលឯកសារនោះត្រូវបានទទួល គឺថា យើងនឹងស្នើឲ្យមានការបកប្រែ ប៉ុន្តែឯកសារហ្នឹងមានតែមួយភាសាទេ។

**ប្រធានអង្គជំនុំ៖**

បាទ តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមសហមេធាវីការពារ--។

**លោក វ៉ិចទ័រ កូប៉េះ៖**

ខ្ញុំសូមអនុញ្ញាតឆ្លើយតបដោយសង្ខេបទៅនឹងអ្វីដែលព្រះរាជអាជ្ញាបានលើកឡើង។

[១៦:១០:២១]

**ប្រធានអង្គជំនុំ៖**

មិនទាន់មានសហមេធាវី ខៀវ សំផន មិនទាន់បានលើកឡើងអីផង។ លោកចាំមានឱកាសឆ្លើយចុងក្រោយ អង្គជំនុំជម្រះមិនទាន់ផ្តល់វេទិកាជូនលោកទេ។

**កញ្ញា អង់តា ហ្គីសសេះ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំគិតថា ប្រហែលជាលោកប្រធានភ្លេចខ្ញុំមើលទៅ។ ខ្ញុំលើកឡើងដោយខ្លីទេ។ យើងបានដឹងអំពីឯកសារទាំងអស់នេះមុននឹងនិយាយនៅថ្ងៃនេះ។ ទោះជាយ៉ាងណាក៏ដោយ យើងកំពុងតែប្រឈមមុខនឹងសំណើរបស់មេធាវី នួន ជា ដែលគាត់គិតថាមានសារៈសំខាន់នៅក្នុងសំណុំរឿងយើងនេះ។ យើងដឹងច្បាស់ថា ឯកសារទាំងអស់នេះគឺជាឯកសារសម្រាប់សួរលោកអ៊ីសា ឧស្មាន ដែលជាអ្នកជំនាញរបស់អង្គជំនុំជម្រះ។ ដូច្នេះឯកសារទាំងអស់នេះនឹងជាប្រទីបបំភ្លឺក្នុងការសម្រេចរបស់អង្គជំនុំជម្រះ។ ដូច្នេះក្នុងលក្ខខណ្ឌទាំងអស់នេះ យើងគិតថា រាល់ឯកសារទាំងអស់ដែលអាចឲ្យសក្ខីកម្មរបស់គាត់មានលក្ខណៈស៊ីជម្រៅ និងដើម្បីអាចបំភ្លឺអំពីបញ្ហាផ្សេងៗបាននុ៎ង យើងគិតថា ឯកសារជាឯកសារសំខាន់។ ដូច្នេះប្រសិនបើឯកសារទាំងអស់នេះមានសារៈសំខាន់សម្រាប់មេធាវីការពារក្តី នួន ជា សម្រាប់ការពារកូនក្តីរបស់គាត់នោះ យើងមិនជំទាស់អ្វីទេ។ យើងខ្ញុំគោរពទៅតាមការសម្រេចរបស់អង្គជំនុំជម្រះ។

[១៦:១២:១៤]

**លោក វ៉ិចទ័រ កូប៉េះ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមានមតិសង្ខេបបីទេ។ ទី១ចំពោះព្រះរាជអាជ្ញា យើងយល់ថាអ្នកជំនាញមិនអាចសួរអំពីនិយមន័យផ្លូវច្បាប់នៃអំពើប្រល័យពូជសាសន៍នោះឡើយ ប៉ុន្តែយើងចាំហើយ ខ្ញុំគិតថា អ្នកជំនាញ ហ្វីលីព ស្បូត គាត់បានផ្តល់ភ័ស្តុតាង ថាតើអំពើប្រល័យពូជសាសន៍បានកើតឡើង ឬក៏អត់។ ហើយទៅតាមដែលខ្ញុំចាំមិនខុសនោះ គឺចៅក្រម ខាតរ៉ាយថ៍ ក៏បាននិយាយថា យើងមិនមាននោះទេ។ ក៏ប៉ុន្តែយើងបានជ្រើសរើសសាក្សីមួយរូបនេះ ហើយគាត់គឺជាមនុស្សតែមួយក្រៅពី ប៊ែន ឃៀរនិន ដែលគាត់បាននិយាយថា អំពើប្រល័យពូជសាសន៍បានកើតឡើង មែនហើយគាត់និយាយ

ច្បាស់។ ដូច្នេះវាការចាំបាច់ដែលមេធាវីការពារក្ដីត្រូវតែសួរដេញដោលអំពីទស្សនៈរបស់អ្នកជំនាញដទៃទៀតដូចជា ប៉េក ឃើរី ក៏ដូចជាអ្នកជំនាញរបស់តុលាការដូចជា ឆេនដ៍ល័រ, ស្បួត ជាដើម ដែលពួកគាត់និយាយថា មិនមានអំពើប្រល័យពូជសាសន៍លើជនជាតិចាមនោះឡើយ។ ខ្ញុំប្រាកដណាស់ថា មិនសួរដេញដោលអំពីនិយមន័យផ្លូវច្បាប់នៅសប្តាហ៍ក្រោយទេ ប៉ុន្តែខ្ញុំចង់ឱ្យមានតុល្យភាពដែលថា មេធាវីការពារក្ដីអាចពិភាក្សាបន្តិចបន្តួច ទើបខ្ញុំស្នើសុំឱ្យដាក់ឯកសារបែបនេះទៅក្នុងសំណុំរឿង។

ហើយមតិបន្ទាប់ទៀតទាក់ទងទៅនឹង លី កូសេន ទោះបីថាគាត់ធ្វើអ្វីក៏ដោយនៅក្នុងរបប លន់ នល់ គឺថាយើងស្នើសុំឱ្យដាក់ឯកសារទាក់ទងទៅនឹងគាត់ហ្នឹង ព្រោះគាត់ជាមេទ័ពមួយ។ ហើយជាច្រើនដងដែលយើងប្រឈមជាមួយសាក្សីដែលមកផ្ដល់សក្ខីកម្មទាក់ទងទៅនឹង អ៊ុក ប៊ុនឈឿន និយាយអំពីការបះបោរជនជាតិចាមឆ្នាំ៧៥។ ហើយនៅក្នុងបរិបទនោះ គឺគាត់បាននិយាយអំពីក្រុមជនជាតិចាមដែលចង់បះបោរ ហើយចង់បង្កើតអង្គការមួយឈ្មោះថា "ហ្វុលរ៉ូ"។ ឯកសារទាំងអស់នេះគឺឯកសារដែលយើងស្នើសុំឱ្យដាក់ទទួល ដែលបង្ហាញពីទំនាក់ទំនងរវាងមេទ័ព លី កូសេន និងការបង្កើតចលនាហ្វុលរ៉ូ។ ខ្ញុំប្រាកដណាស់ថា អ្នកជំនាញគាត់ដឹងច្បាស់អំពីចំណុចទាំងអស់នេះ អំពីបុគ្គលរូបនេះ ហើយនិងតួនាទីរបស់គាត់។ ដូច្នេះខ្ញុំគិតថា វាគ្រាន់តែជាការបន្ថែមទៅលើការសួរដេញដោលឱ្យយើងមានឯកសារមួយទៀត។

[១៦:១៥:០៥]

ហើយមតិចុងក្រោយ គឺជាមតិ អាចជាការសាកសួរ ថាតើយើងអាចមានឯកសារមួយពីរដែរឬទេទាក់ទងទៅនឹងតួនាទីរបស់អ្នកជំនាញនៅ អ.វ.ត.ក នេះ ប៉ុន្តែយ៉ាងណាក៏ដោយ ខ្ញុំទទួលស្គាល់ថាគាត់តែជាអ្នកនិពន្ធសៀវភៅម្នាក់ ហើយគាត់មានព័ត៌មាន ឬក៏គាត់មានចំណេះដឹងអំពីជោគវាសនាជនជាតិចាម។ ប៉ុន្តែយ៉ាងណាក៏ដោយ យើងត្រូវចាំថាគាត់បានចូលរួមយ៉ាងខ្លាំងក្លានៅក្នុងការស៊ើបអង្កេតរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតនៅក្នុងសំណុំរឿងជាច្រើន។ ដូច្នេះមេធាវីការពារក្ដីសង្ស័យថាតើអង្គជំនុំជម្រះអនុញ្ញាតឱ្យមេធាវីការពារក្ដីអាចសួរសំណួរទៅដល់អ្នកជំនាញ ថាតើគាត់ធ្វើការសម្ភាសមួយចំនួនហ្នឹងដោយរបៀបណានៅក្នុងសំណុំរឿង០០៤។ ជាពិសេសគឺថា អង្គជំនុំជម្រះប្រហែលជាបានកត់សម្គាល់រួចមកហើយ ថាមានភាពខុសគ្នាយ៉ាងច្រើនដែលថាសាក្សីមួយនិយាយនៅក្នុងកំណត់ហេតុស្ដាប់ចម្លើយរបស់គាត់កាលពីមួយសប្ដាហ៍ ឬក៏ពីរសប្ដាហ៍មុន នៅពេលគេសម្ភាសគាត់ដោយអសាធារណៈ ហើយនិងអ្វីដែលគាត់និយាយនៅក្នុងតុលាការ។ ដូច្នេះខ្ញុំគិតថាយើងគួរតែរក

E1/387.1/Old-1

ឲ្យឃើញថាតើអ្នកជំនាញនេះ ក្នុងនាមគាត់ជាអ្នកស៊ើបអង្កេត ថាតើគាត់មានអ្វីពាក់ព័ន្ធដែរទៅនឹងការសម្ភាស ទៅនឹងការស្តាប់ចម្លើយនេះ? ដូច្នេះថាតើគាត់នាំមុខសាក្សី ឬក៏អត់?

[១៦:១៦:៤៥]

ខ្ញុំគិតថានេះជាអ្វីមួយដែលខ្ញុំគួរតែអាចមានឱកាសដើម្បីស្វែងរកឲ្យឃើញ។ ដូច្នេះហើយទើបយើងដាក់បញ្ចូលនូវការពណ៌នាការងាររបស់គាត់ ក៏ដូចជាឈ្មោះមនុស្សដែលគាត់បានសម្ភាស ក៏ដូចជាតួនាទីសំខាន់របស់គាត់នៅក្នុងសំណុំរឿង០០៤ ក៏ដូចតួនាទីសំខាន់ក្នុងការស៊ើបអង្កេតក្នុងសំណុំរឿង០០២។ ខ្ញុំជឿជាក់ថាយើងអាចនឹងមានឱកាសដើម្បីរុករកទៅលើបញ្ហានេះ ហើយអាចនឹងកំណត់ឲ្យបានច្បាស់ ថាតើគាត់ជាអ្នកជំនាញដែលមានភាពមិនលំអៀង ឬក៏អ្វីដូចដែលគាត់អះអាងឬក៏អត់នោះ។

**លោក នីកូឡាស គូមជែន៖**

លោកប្រធាន ខ្ញុំមានមតិបន្តិចបន្តួចទាក់ទងទៅនឹងអ្វីដែលមេធាវីការពារក្តីបានលើកឡើង។ ទី១ សាក្សីត្រូវបានកោះហៅក្នុងនាមជាអ្នកជំនាញលើផ្នែកជនជាតិចាម។ ដូច្នេះយើងគួរតែបញ្ជាក់ឲ្យបានច្បាស់ ហើយយើងចាំឲ្យបានច្បាស់ថា គាត់មិនមែនជាសាក្សីនៃកិច្ចដំណើរការនីតិវិធីរបស់ ក.ស.ច.ស នោះទេ។ គឺថា ទោះបីថាសាក្សីមានការងារជាមួយ ក.ស.ច.ស ក៏ដោយ ប៉ុន្តែនេះវាមិនមែននោះទេ ប៉ុន្តែយើងទាំងអស់គ្នាគួរតែចាត់ទុកគាត់ ហើយយើងឲ្យតម្លៃទៅលើមតិ ឬក៏ទស្សនៈរបស់គាត់។ ដូច្នេះគឺថាគាត់គួរតែ យើងគួរតែគិតថាមតិរបស់គាត់ជាមតិអព្យាក្រឹត។ ចំពោះកិច្ចដំណើរការនីតិវិធីរបស់ ក.ស.ច.ស អាហ្នឹងជារឿងមួយផ្សេង។ ខ្ញុំគិតថាវាចាកប្រធានដែលយើងមកនិយាយអំពីបញ្ហានេះ។

បន្ថែមពីលើនេះទៀត ខ្ញុំចង់បន្ថែមចំណុចកែតម្រូវមួយទៅលើមេធាវី កូសិន ព្រោះគាត់និយាយថាមានភស្តុតាងនៅក្នុងសំណុំរឿងដែលនិយាយថា អ៊ុក ប៊ុនឈឿន បាននិយាយថាមានភស្តុតាង ដូចថាចាមចង់បង្កើតរដ្ឋផ្តាច់ខ្លួនមួយ។ យើងដឹងច្បាស់ថាភស្តុតាងនេះត្រូវបានអង្គជំនុំជម្រះបដិសេធ ដោយសារតែមានការទទួលស្គាល់។ ហើយអ្វី -- ព្រោះដោយសារតែមេធាវីការពារក្តីផ្អែកទៅលើការនិយាយ អ៊ុក ប៊ុនឈឿន ដែល អ៊ុក ប៊ុនឈឿន ដកស្រង់ចម្លើយសារភាព។ ចំពោះមតិជាច្រើនទាក់ទងទៅនឹងអំពើប្រល័យពូជសាសន៍ អ្នកជំនាញដទៃទៀត ទោះបីថាគាត់ស្ថិតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ឬក៏អត់ គឺថាយើងយល់ស្របជាមួយមេធាវីការពារក្តីដែលថា អ្នកជំនាញមិនអាចផ្តល់មតិផ្លូវច្បាប់ ហើយយើងក៏មិនគួរសួរអ្នកជំនាញមួយនេះ គឺ TCE-95 អំពីទស្សនៈរបស់គាត់ ថាតើវាជាអំពើប្រល័យពូជសាសន៍ ឬក៏អត់។ គឺថាមេធាវីការពារក្តីអាចលើកយកការយល់ដឹងអំពីអង្គហេតុជាច្រើន ដូច្នេះដូចដែល

ខ្ញុំបញ្ជាក់អ៊ីចឹង យើងមិនជំទាស់ទៅនឹងអត្ថបទរបស់ ម៉ៃខល វីកឃើរី ទាក់ទងទៅនឹងការគណនាចំនួនជនជាតិចាម ដែលត្រូវបានសម្លាប់នៅក្នុងរបបនោះនៅឡើយ។ ហើយម្យ៉ាងទៀត មតិ ឬក៏ទស្សនៈរបស់អ្នកជំនាញទៅលើអង្គហេតុដទៃទៀត ក៏យើងមិនជំទាស់ដែរ។

ដូច្នេះដូចគ្នានឹងអ្វីដែលមេធាវីការពារក្តីបានលើកឡើង អ៊ីចឹងគឺយើងមិនសួរអំពីទស្សនៈរបស់គាត់ ទាក់ទងទៅនឹងនិយមន័យ អង្គច្បាប់នៃអំពើប្រល័យពូជសាសន៍នោះឡើយ។ ដូច្នេះហើយ ខ្ញុំគិតថា វាមិនមានហេតុផលអ្វីដែលមេធាវីការពារក្តីចាំបាច់ត្រូវមានតុល្យភាព ដែលលើកយកទស្សនៈរបស់អ្នកដែលមិនមែនជា មិនជាៗៗអ្នកច្បាប់នៅតុលាការអន្តរជាតិអ្វីនោះឡើយ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ!

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមានការកត់សម្គាល់ខ្លីមួយ។ បញ្ហាដែលចង់ដឹងថា តើអ្នកជំនាញអាចផ្តល់សក្ខីកម្មពាក់ព័ន្ធនឹងអ្វីដែលកើតឡើងក្នុងសំណុំរឿង០០២នោះបានដែរឬទេ? បញ្ហានេះ ត្រូវបានសម្រេចរួចមកហើយ គឺវាពាក់ព័ន្ធទៅនឹងលិខិតរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ។ ខ្ញុំយោងទៅលើឯកសារ E337/1 ដែលក្នុងនោះបានបញ្ជាក់ច្បាស់ថា អ៊ីសា ឧស្មាន មិនអាចផ្តល់សក្ខីកម្មពាក់ព័ន្ធទៅនឹងអ្វីដែលបានកើតឡើងនៅក្នុងសំណុំរឿង០០៤នោះទេ។ ដូច្នេះវាចាកប្រធានបទ នៅពេលដែលនិយាយអំពីរឿងនេះនោះ។

**លោក នីកូឡាស គូមជែន៖**

ខ្ញុំសូមអភ័យទោស ខ្ញុំបារម្ភអំពីភាពសាធារណៈ ប៉ុន្តែឥឡូវអត់អីទេ មិនមានបញ្ហាអីនោះទេ។ សូមអភ័យទោស។ ខ្ញុំសូមអភ័យទោសផងដែរដែលខ្ញុំឡើងកាត់ ដូច្នេះសូមអភ័យទោស។

[១៦:២២:១៥]

**ប្រធានអង្គជំនុំ៖**

មានភាគីណាចង់មានមតិយោបល់អ្វីទៀតទេ សូមអញ្ជើញ!

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំមានមតិខ្លីមួយទេ ក្នុងការឆ្លើយទៅនឹងព្រះរាជអាជ្ញា ទាក់ទងទៅនឹងហ្សូលរ៉ូ ហើយនិង អ៊ុក ប៊ុនឈឿន។ នេះគឺជាការពិត ដែលថាអង្គជំនុំជម្រះបានសម្រេចទៅលើចំណុចទាំងអស់នេះ ទៅលើការ

សម្ភាសដែលគាត់បានផ្តល់ ប៉ុន្តែគាត់បាននិយាយអំពីហេតុការណ៍មួយដែលកើតនៅក្នុងឆ្នាំ៧៥។ ដូច្នេះគឺគាត់មិននិយាយអំពីចម្លើយសារភាពនៅ ស-២១ទេ ដោយសារឆ្នាំ៧៥ មិនទាន់មានស-២១ទេ។ ហើយគាត់ក៏មិនបាននិយាយយោងទៅលើចម្លើយសារភាពរបស់មន្ទីរសន្តិសុខក្រូចឆ្មារមួយនោះឡើយ ព្រោះថាអង្គជំនុំជម្រះមិនបានសម្រេច ថាតើមានការធ្វើទារុណកម្មនៅមន្ទីរសន្តិសុខក្រូចឆ្មារ ឬក៏អត់នោះ។ ដូច្នេះយើងមិនអាចនិយាយបានថា អ្វីដែល អ៊ុក ប៊ុនឈឿន បាននិយាយអំពីហ្វូលរ៉ូ គឺមិនអាចយកមកពិភាក្សាដេញដោលបាននោះទេ។

**លោក នីកូឡាស គូមជែន៖**

ខ្ញុំគ្រាន់តែចង់បង្ហាញថា ចម្លើយសារភាព ស-២១ គឺបាននិយាយអំពីបញ្ហាដែលកើតឡើងឆ្នាំ៧៥ផងដែរ។

**ប្រធានអង្គជំនុំ៖**

បាទ កិច្ចពិភាក្សាលើសំណើសុំរបស់សហមេធាវីការពារក្តី នួន ជា បានចប់ហើយ។ អង្គជំនុំជម្រះសាលាដំបូងសូមថ្លែងអំណរគុណដល់ភាគីទាំងអស់ ដែលបានលើកឡើងនូវសារណាផ្ទាល់មាត់លើបញ្ហានេះ ដែលវាជាមូលដ្ឋានសម្រាប់អង្គជំនុំជម្រះយកទៅពិភាក្សាសម្រេច លើសំណើសុំនេះ ឲ្យបានឆាប់ និងចេញសេចក្តីសម្រេចនៅចុងសប្តាហ៍នេះ ហើយធ្វើយ៉ាងណាឲ្យបានមុនស្តាប់សក្ខីកម្មសាក្សីអ្នកជំនាញ 2-TCE-95។

ហើយសវនាការនៅថ្ងៃនេះ ដល់ពេលឈប់សម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ ត្រឹមនេះ ហើយសវនាការលើកទៅបន្តធ្វើនៅថ្ងៃចន្ទ ទី០៨ ខែកុម្ភៈ ឆ្នាំ២០១៦ ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។ សវនាការនៅថ្ងៃចន្ទ និងថ្ងៃបន្តបន្ទាប់នៅដើមសប្តាហ៍ក្រោយនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សក្ខីកម្មអ្នកជំនាញ 2-TCE-95 សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាបានកំណត់នេះ។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំង នាំខ្លួនជនជាប់ចោទទាំងពីររូប នួន ជា និង ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការ នៅថ្ងៃចន្ទ ទី០៨ ខែកុម្ភៈ ឆ្នាំ២០១៦ ឲ្យបានមុនម៉ោងប្រាំបួន ជាកំណត់។

សម្រាកចុះ!

*(សវនាការផ្អាកនៅម៉ោង ១៦:២៤ នាទី)*